**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# សិទ្ធិអនីតិជនតាមការកំណត់ក្នុង ក្រមរដ្ឋប្បវេណី

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ៖ **សំម ឫទ្ធីរដ្ឋា**
**កែវ វុទ្ធី**

សាស្ត្រាចារ្យណែនាំ
**លោក ហ៊ីង គីមឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **សំម ឫទ្ធីរដ្ឋា** និងឈ្មោះ **កែវ ឧុទ្ធី** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៥-២០១៩ ជំនាន់ទី១៩។

**សូមថ្លែងអំណរគុណដោយក្តីគោរពស្រលាញ់ដ៏ជ្រាលជ្រៅក្រៃលែងជាទីបំផុតចំពោះ៖**

- លោកឪពុក **សំម ស៊ីថាត** និងអ្នកម្តាយ **អ៊ុំ សារីវណ្ណា**
- លោកឪពុក **កែវ អូន** និងអ្នកម្តាយ **សែម ណើន**

លោកអ្នកមានគុណបានផ្តល់កំណើតដល់កូន និងបានខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ លើកទឹកចិត្ត ផ្គត់ផ្គង់គ្រប់បែបយ៉ាង ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត ទាំងមធ្យោបាយ និងជំរុញកូនឱ្យបានសិក្សារៀនសូត្រចាប់តាំងពីថ្ងៃចាប់កំណើតរហូតដល់សព្វថ្ងៃនេះ។ គុណូបករៈរបស់អ្នកមានគុណទាំងពីរ មានទំហំធំធេងគ្មានអ្វីប្រៀបផ្ទឹមបានប្រដូចបាន។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរ ចំពោះ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស_ព្រឹទ្ធបុរសរង ព្រមទាំងលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការបំពេញតួនាទីរបស់ខ្លួនដើម្បីដឹកនាំនិស្សិតទទួលបាននូវអនាគតដ៏ល្អ។

សូមថ្លែងអំណរគុណដល់លោកសាស្ត្រាចារ្យ **ហ៊ីង គមឡេង** ដែលជាសាស្ត្រាចារ្យដឹកនាំ ដែលបានខិតខំអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ព្រមទាំងចំណាយពេលវេលាដ៏មានតម្លៃរបស់ខ្លួន ណែនាំ ត្រួសត្រាយផ្លូវ ដើម្បីបង្កើតនូវវណ្ណកម្មនេះឡើង ។

ចំពោះរៀមច្បង សិស្សប្អូន មិត្តភក្តិ និងក្រុមការងារទាំងអស់ដែលតែងតែផ្តល់ជាពុទ្ធិ និងលើកទឹកចិត្ត ដើម្បីឱ្យការងារនេះបានបញ្ចប់ដោយជោគជ័យ ។

ជាទីបញ្ចប់ ខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណជាថ្មីម្តងទៀត និងសូមបួងសួងដល់វត្ថុសក្តិសិទ្ធទាំងអស់ក្នុងលោក ជួយតាមថែរក្សាដល់អ្នកទាំងអស់គ្នាឱ្យជួបតែពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ ។

# អារម្ភកថា

ក្រោយពីបានបន្តការសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច អស់រយៈពេលប្រមាណជា ៤ ឆ្នាំមកនេះ។ យើងខ្ញុំបានសិក្សាស្រាវជ្រាវនូវមុខវិជ្ជាជាច្រើន ទាំងផ្នែកឯកជន និងសាធារណៈ ហើយដើម្បីឱ្យស្របតាមកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ យើងខ្ញុំបានធ្វើការសម្រេចចិត្តសរសេរសារណាសម្រាប់បញ្ចប់ការសិក្សា ដោយជ្រើសរើសយកប្រធានបទមួយដែលស្តីពី «**សិទ្ធិអនីតិជនតាមកំណត់ក្រមរដ្ឋប្បវេណី**» ។

ការសិក្សាស្រាវជ្រាវនេះក្នុងគោលបំណង ដើម្បីយល់ដឹងកាន់តែស៊ីជម្រៅថែមទៀត អំពីបទដ្ឋានគតិយុត្តទាក់ទងទៅនឹង សិទ្ធិរបស់អនីតិជនដែលក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្ររបស់យើងបានផ្តល់ឱ្យ ឱ្យបានកាន់តែច្បាស់។ ហើយដើម្បីទទួលបានគតិយកមកអប់រំដល់ខ្លួនឯង និងអ្នកដទៃសម្រាប់ធ្វើការស្វែងយល់ ធ្វើយ៉ាងណាឱ្យសង្គមមួយនេះ សម្បូរទៅដោយប្រជាពលរដ្ឋដែលមានលក្ខណៈសម្បត្តិជាអ្នកដឹកនាំ និងជាអ្នកមានចំណេះដឹង ព្រមដោយសីលធម៌ គុណធម៌ និងសុជីវធម៌ ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់បំផុតរបស់មនុស្ស ក៏ដូចជាខ្លឹមសារស្នូលនៃសង្គមជាតិទាំងមូល ក្នុងការដឹកនាំសង្គមជាតិមួយនេះឆ្ពោះទៅកាន់វឌ្ឍនភាព និងជានិរន្តរភាព។

ថ្វីត្បិតតែសារណាមួយនេះបានបញ្ចប់ក៏ពិតមែន ប៉ុន្តែនៅចំណុចខ្លះ យើងខ្ញុំមិនអាចធ្វើការវិភាគឱ្យបានគ្រប់ជ្រុងជ្រោយ ជាពិសេសទាក់ទងទៅនឹងច្បាប់ ក៏ដូចជានីតិវិធីនៃការអនុវត្តផងដែរ។ ហេតុដូច្នេះ យើងខ្ញុំទាំងពីរនាក់នឹងធ្វើការសិក្សាបន្ថែមទៀតអំពីប្រធានបទមួយនេះ និងធ្វើការកែតម្រូវនូវចំណុចខ្វះខាតដែលកើតមាននៅក្នុងអត្ថបទមួយនេះ។

យើងខ្ញុំសង្ឃឹមថា សារណាមួយនេះនឹងបានចូលរួមជាគំនិតខ្លះៗ ដល់និស្សិតជំនាន់ក្រោយក្នុងការសិក្សាស្រាវជ្រាវ និងចូលរួមចំណែកមួយផ្នែកជាទ្រឹស្តី ទាក់ទងនឹងសិទ្ធិរបស់អនីតិជន ក្នុងការយល់ដឹងពេញលេញឱ្យមានភាពល្អប្រសើរឡើង និងក្លាយទៅជាពលរដ្ឋល្អ កូនល្អ សិស្សល្អ ដែលជាទំពាំងស្នងឫស្សី នៅក្នុងសង្គមគ្រួសារ និងសង្គមជាតិទាំងមូល ឱ្យសាកសមទៅនឹងអច្ឆរិយប្រទេសមួយនេះ។

ជាទីបញ្ចប់យើងខ្ញុំរង់ចាំជានិច្ច ចំពោះមតិរិះគន់ក្នុងគោលបំណងស្ថាបនា ដែលជាកញ្ចក់ឆ្លុះបញ្ចាំងពីភាពអវិជ្ជមានណាមួយ ដើម្បីធ្វើការសិក្សាស្រាវជ្រាវបន្ថែម បង្កើនការយល់ដឹង និងពង្រីកចំណេះដឹងថែមទៀត ពីសំណាក់ លោក លោកស្រី សាស្ត្រាចារ្យ មិត្តនិស្សិត សិស្សច្បង អ្នកវិជ្ជាជីវៈ ព្រមទាំងពីសំណាក់មិត្តអ្នកអាន ទាំងអស់ជាទីគោរព និងរាប់អានដ៏ជ្រាលជ្រៅបំផុត។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១ សញ្ញាណទូទៅនៃអនីតជន**

**១.១ លក្ខណៈនៃអនីតជន** ........ ៥

**១.២ អគ្គាធីនភាព** ........ ៥

១.២.១ លក្ខខណ្ឌទទួលបានអគ្គាធីនភាព ........ ៦

១.២.២ នីតិវិធីនៃការទទួលអគ្គាធីនភាព ........ ៦

១.២.៣ អានុភាពនៃអគ្គាធីនភាព ........ ៧

**ជំពូកទី២ សិទ្ធិអនីតជននៅក្នុងកិច្ចសន្យា**

**២.១ ស្វ័យភាពនៃសិទ្ធិអនីតជន** ........ ៨

២.១.១ សិទ្ធិទាក់ទងនឹងជីវភាពប្រចាំថ្ងៃ ........ ៩

២.១.២ សិទ្ធិដែលមិនជាប់កាតព្វកិច្ច ........ ៩

២.១.៣ សិទ្ធិទាក់ទងនឹងកិច្ចសន្យាការងារ ........ ១០

**២.២ សិទ្ធិអនីតជនដែលទទួលបានដោយអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតជន** ........ ១១

២.២.១ សិទ្ធិចាត់ចែងទ្រព្យសម្បត្តិដោយការកំណត់គោលបំណង ........ ១១

២.២.២ សិទ្ធិចាត់ចែងទ្រព្យសម្បត្តិដោយមិនកំណត់គោលបំណង ........ ១២

២.២.៣ សិទ្ធិក្នុងការប្រកបអាជីវកម្ម ........ ១២

**២.៣ ការលុបចោល និងការរំលាយកិច្ចសន្យារបស់អនីតជន** ........ ១៤

២.៣.១ ការលុបចោលកិច្ចសន្យារបស់អនីតិជន ........ ១៥

២.៣.២ ការរំលាយកិច្ចសន្យាការងាររបស់អនីតិជន ........ ១៦

២.៣.៣ ការការពារភាគីម្ខាងទៀតនៃអនីតិជន ........ ១៧

**ជំពូកទី៣ សិទ្ធិអនីតជនក្នុងអំពើអនីត្យានុកូល**

**៣.១ ករណីអំពើអនីត្យានុកូលបង្កឡើងដោយអនីតជន** ........ ២១

៣.១.១ អនីតិជនក្រោមអាយុ ១៨ឆ្នាំ ........ ២៤

៣.១.២ អនីតិជនចាប់ពីអាយុ ១៤ឆ្នាំ ........ ២៥
**៣.២ ករណីអនីតិជនជាជនរងគ្រោះនៃអំពើអនីត្យានុកូល** ........ ២៦
៣.២.១ អ្នកតំណាងសម្រាប់អនីតិជន ........ ២៧
៣.២.២ អនីតិជនដែលទទួលបានអត្តាធីនភាព និងការដល់នីតិភាព ........ ២៨
**ជំពូកទី៤ សិទ្ធិអនីតិជនទៅក្នុងសន្តតកម្ម**
**៤.១ លក្ខណៈសម្បត្តក្លាយជាសន្តតជន** ........ ៣០
៤.១.១ លក្ខខណ្ឌទូទៅ ........ ៣០
៤.១.២ លក្ខណៈមិនអាចក្លាយជាសន្តតិជន ........ ៣៥
**៤.២ អ្នកតំណាងស្របច្បាប់ក្នុងរបបសន្តតកម្មរបស់អនីតជន** ........ ៣៨
៤.២.១ ការចាប់ផ្តើម និងការប្រព្រឹត្តទៅនៃរបបអាណាព្យាបាលសម្រាប់អនីតិជន ........ ៣៩
៤.២.២ ករណីយកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ........ ៤១
៤.២.៣ ការរលត់នៃរបបអ្នកអាណាព្យាបាលសម្រាប់អនីតិជន ........ ៤២
**សេចក្តីសន្និដ្ឋាន** ........ ៤៤
**អនុសាសន៍** ........ ៤៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ដោយសារការផ្លាស់ប្តូររបបនយោបាយជាច្រើនសន្ទឹកសន្ទាប់ និងការជួបប្រទះសង្គ្រាមស៊ីវិលជាច្រើន ព្រះរាជាណាចក្រកម្ពុជាបានបាត់បង់នូវរចនាសម្ព័ន្ធសឹងតែទាំងអស់។ ក្រោយពីទទួលបានសន្តិភាពពេញញ ការសិក្សាវិភាគទៅលើច្បាប់ត្រូវបានធ្វើភ្លាមៗទៅតាមវិវត្តន៍នៃសង្គម ដើម្បីជាគោលការណ៍នៃការកំណត់នូវសិទ្ធិ និងសេរីភាពដល់ប្រជាពលរដ្ឋ។ ក្រមរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា បានអនុម័ត នៅឆ្នាំ២០០៧ ក្នុងគោលបំណងដើម្បីដោះស្រាយនូវបញ្ហាឯកជននានា ដោយមាន ៩ គន្ថី ចាប់ពីបទប្បញ្ញត្តិទូទៅ រហូតទៅដល់ គន្ថីស្តីពី អវសានប្បញ្ញត្តិ។ ការសិក្សាទៅលើបញ្ញត្តិនីមួយៗ មានភាពលំបាក ដូចនេះទើប ក្រសួងយុត្តិធមិបានបង្កើតនូវ សេចក្តីកំណត់ និងសេចក្តីពន្យល់ក្រមរដ្ឋប្បវេណីថែមទៀត។ ក្នុងនោះដែរ យើងឃើញមានសិទ្ធិដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីភាគច្រើន គឺសំដៅទៅលើនីតិជន។ រីឯអនីតិជន វិញត្រូវបានចាត់ទុកជាជនស្ថិតក្រោមការកម្រិតសមត្ថភាព ដូចនេះ សិទ្ធិ កាតព្វកិច្ច និងសេរីភាពរបស់អនីតិជន គឺមានភាពខុសគ្នាពីនីតិជន ត្រូវបានបញ្ញត្តជាលក្ខណៈទូទៅ។ ការកម្រិតសមត្ថភាពរបស់អនីតិជននេះ គឺធ្វើឡើងក្នុងគោលបំណងដើម្បីការពារអនីតិជន ដោយហេតុ អនីតិជនគឺស្ថិតនៅក្នុងស្ថានភាពក្មេងខ្ចី ងាយស្រួលក្នុងការបញ្ចុះបញ្ចូល ពុំទាន់មានបទពិសោធន៍គ្រប់គ្រាន់ក្នុងការធ្វើសកម្មភាពសំខាន់ៗ ដែលសកម្មភាពទាំងនោះអាចជាកាតព្វកិច្ច ឬជាសកម្មភាពដែលធ្វើឱ្យខូចនូវប្រយោជន៍របស់អនីតិជននោះ។

នៅក្នុងបញ្ញត្តិនៃក្រមរដ្ឋប្បវេណី យើងឃើញថា បញ្ញត្តិស្តីពីអនីតិជន គឺស្ថិតនៅក្នុង កថាភាគទី១ ផ្នែកទី ៤ ជំពូក ១ គន្ថីទី ២ ដែលមានពីមាត្រា ១៧ ដល់ មាត្រា ២៣ សរុបទៅគឺចំនួន ៧ មាត្រា។ ប៉ុន្តែ បញ្ញត្តិដែលទាក់ទងទៅនឹងអនីតិជន មានលើសពីអ្វីដែលបានចែងនៅក្នុងកថាភាគនេះ ដូចនេះធ្វើឱ្យការយល់ដឹងពីអនីតិជន មានភាពស៊ាំញ៉ាំ តម្រូវឱ្យមានការពិនិត្យ និងសិក្សាដិតដល់។

ដើម្បីដោះស្រាយបញ្ហាខាងលើនេះ សំណេរសារណានេះ បានផ្តោតទៅលើផ្នែកសំខាន់ៗ ដូចជាកិច្ចសន្យា អំពើអនីត្យានុកូល និងសន្តតិកម្ម ដែលក្រមរដ្ឋប្បវេណីបានកំណត់ឡើង ដោយរួមផ្សំនឹងការសិក្សាស្រាវជ្រាវនូវទិន្នន័យពាក់ព័ន្ធផ្សេងៗទៀត ដើម្បីឱ្យវិសាលភាពនៃការយល់ដឹងពីសិទ្ធិអនីតិជនមានភាពច្បាស់លាស់ និងជំរុញវិស័យច្បាប់ឱ្យកាន់តែប្រសើរឡើង។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

ដូចដែលបានលើកឡើងជាទូទៅខាងលើ អនីតិជនក៏ជារូបវន្តបុគ្គលមួយរូបដែលអាចមាន

សិទ្ធិ និងកាតព្វកិច្ច ដូចនីតិជនដែរ។ ដូចនេះហើយទើបនាំឱ្យមានការលើកឡើងជាចំណោទបញ្ហានៃប្រធានបទនេះថា តើអនីតិជនមានសិទ្ធិអ្វីខ្លះ? ហើយបើសកម្មភាពមួយត្រូវបានកម្រិត តើភាគីទាំងសងខាងត្រូវមានទំនួលខុសត្រូវយ៉ាងដូចម្តេច? តើអនីតិជនអាចទាមទារនូវសិទ្ធិរបស់ខ្លួន ឬក៏ត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលដែរ ឬទេ? ហើយម្យ៉ាងទៀតនោះ តើអនីតិជនអាចមានសិទ្ធិអ្វីខ្លះនៅក្នុងដំណើរការសន្តតិកម្ម?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាអំពី សិទ្ធិអនីតិជនតាមការកំណត់ក្នុងក្រមរដ្ឋប្បវេណី គឺមានគោលបំណងបកស្រាយនូវលក្ខខណ្ឌ និងអានុភាពនានា ដែលទាក់ទងទៅនឹងសកម្មភាពរបស់អនីតិជន ពីព្រោះអនីតិជន ក៏ជាប្រជាពលរដ្ឋដែលមានសិទ្ធិ និងសេរីភាពដែរ។ លើសពីនេះ ការសិក្សាស្រាវជ្រាវ មានគោលដៅ ផ្តល់ជាសំណោរមួយដល់ទៅនិស្សិតជំនាន់ក្រោយឱ្យទទួលបាននូវភាពងាយស្រួលក្នុងសិក្សាយល់ដឹងពីសិទ្ធិនានារបស់អនីតិជនដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

សំណោរសារណានេះ មានគោលបំណងក្នុងការរៀបរាប់ឱ្យបានច្បាស់លាស់អំពី សិទ្ធិអនីតិជនដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី។ ដូចនេះ ការស្រាវជ្រាវរបស់យើងខ្ញុំ គឺផ្អែកទៅលើ ក្រមរដ្ឋប្បវេណីផ្ទាល់ ដែលមានចាប់តាំងពី ការជនដែលត្រូវបានកម្រិតសមត្ថភាព ក៏ដូចជា អំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន កិច្ចសន្យា អំពើអនីត្យានុកូល និងសន្តតិកម្ម។ អ្វីដែលអាចជាខ្វះខាតចំពោះការស្រាវជ្រាវនេះ គឺផ្នែកដែលពាក់ព័ន្ធនឹងអនីតិជនអាចមានវិសាលភាពធំជាងអ្វីដែលបានស្រាវជ្រាវ។ ចំពោះដែនកំណត់នៃការស្រាវជ្រាវ ដោយផ្អែកទៅតាមពេលវេលាកំណត់ គឺសិក្សាទៅលើតែឯកសារច្បាប់ដែលទាក់ទងទៅនឹងអនីតិជននៅប្រទេសកម្ពុជាតែប៉ុណ្ណោះ ដែលអាចមានដូចជា ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ការងារ ជាអាទិ៍។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

តាមការសិក្សាស្រាវជ្រាវសិក្សាកន្លងមើល យើងខ្ញុំឃើញថា មានសំណោរជាច្រើនបានលើកនូវបញ្ញត្តិនានាក្នុងក្រមរដ្ឋប្បវេណី ដូចជាសន្តតិកម្ម ការលែងលះ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ជាដើម ដោយក្នុងមានការលើកឡើងបន្តិចបន្តួច ជាចំណុចផ្សេងៗ ទៅលើការពិភាក្សាចំពោះអនីតិជន។ អនីតិជនជាជនត្រូវបានកម្រិតសមត្ថភាព ប៉ុន្តែដូចគ្នាក៏បានត្រូវផ្តល់សិទ្ធិដើម្បីប្រាស្រ័យទាក់ទងសម្រាប់ជីវភាពប្រចាំថ្ងៃដែរ នេះហើយជាហេតុធ្វើឱ្យការយល់ដឹងពីសិទ្ធិរបស់អនីតិជន មានលក្ខណៈមិនច្បាស់។ ហេតុនេះទើបសំណោរសារណាទាក់ទងនឹង សិទ្ធិអនីតិជនតាមកំណត់ក្នុងក្រមរដ្ឋប្បវេណី មានសារៈសំខាន់ ក្នុងការចែករំលែកចំណេះដឹង និងពន្យល់ឱ្យបានច្បាស់នូវសិទ្ធិអ្វីខ្លះ

ដែលបានកំណត់ ហើយនីតិវិធីក្នុងការធ្វើសកម្មភាពជាមួយអនីតិជន ត្រូវគោរពតាមគោលការណ៍អ្វីខ្លះ ដើម្បីការពារទាំងអនីតិជន ក៏ដូចជាជនដែលពាក់ព័ន្ធនឹងអនីតិជន។ លើសពីនេះ សំណេរសារណានេះ ក៏អាចនឹងសម្រួលទៅដល់ការសិក្សារបស់និស្សិតជំនាន់ក្រោយ ក្នុងការសិក្សាទៅលើអនីតិជន ដោយហេតុបញ្ញត្តិស្តីពីអនីតិជន ត្រូវបានកំណត់ជាចំណុចតូចៗ ក្នុងផ្នែកនានា ក្នុងក្រមរដ្ឋប្បវេណី។ ដូចនេះ និស្សិត អាចនឹងស្វែងរកបណ្តុំតែមួយ ដែលទ្បើកលើងតែពីអនីតិជន ជាមួយសារណានេះ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការប្រមូលឯកសារ ព័ត៌មាន និងទិន្នន័យនានា គឺជាកត្តាចាំបាច់ណាស់សម្រាប់ការស្រាវជ្រាវ និងចងក្រងនូវសំណេរសារណានីមួយៗ។ ដូចគ្នាដែរ ចំពោះសំណេរសារណានេះ គឺផ្តោតសំខាន់ទៅប្រភពទិន្នន័យសំខាន់ៗចំនួនពីរ គឺ៖

### ទិន្នន័យចម្បង

ដោយហេតុតែប្រធានបទផ្តោតទៅលើការកំណត់ក្នុងក្រមរដ្ឋប្បវេណី ដូចនេះ ទិន្នន័យចម្បងរបស់យើងខ្ញុំ គឺបានស្រង់គោលគំនិត និងព័ត៌មានពីច្បាប់សារធាតុ ពោលគឺក្រមរដ្ឋប្បវេណីផ្ទាល់ អមនឹងសេចក្តីកំណត់មាត្រា និងសេចក្តីពន្យល់ក្រមរដ្ឋប្បវេណី។

### ទិន្នន័យបន្ទាប់បន្សំ

ចំណែកឯទិន្នន័យបន្ទាប់បន្សំវិញ គឺយើងខ្ញុំបានប្រមូលយកព័ត៌មាន ទិន្នន័យ និងឯកសារចេញពីសៀវភៅមេរៀនរបស់សាស្ត្រាចារ្យផ្សេងៗ និក្ខេបបទនានា គេហទំព័រ និងឯកសារទាក់ទងពីបទបង្ហាញដែលជាកម្មវិធីរបស់សាកលវិទ្យាល័យផ្ទាល់។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវទៅលើប្រធានបទ សិទ្ធិអនីតិជនតាមកំណត់ក្នុងក្រមរដ្ឋប្បវេណី យើងខ្ញុំបានបែងចែកចេញជាបួនជំពូក។ ជំពូកទី១ មានចំណងជើង **សញ្ញាណទូទៅនៃអនីតិជន** ដែលធ្វើការរៀបរាប់អំពីគោលការណ៍ផ្សេងៗ ចំពោះការកំណត់ថាជនដូចម្តេចដែលត្រូវបានចាត់ទុកជាអនីតិជន។ ជំពូកទី២ គឺយើងខ្ញុំនឹងធ្វើការបកស្រាយទៅលើ **សិទ្ធិរបស់អនីតិជននៅក្នុងកិច្ចសន្យា** ដែលសំដៅទៅលើ សិទ្ធិ និងការកម្រិតសិទ្ធិផ្សេងៗ ដែលអនីតិជនបានធ្វើឡើងជាមួយភាគីម្ខាងទៀតនៃកិច្ចសន្យា។ រីឯជំពូកទី៣ **សិទ្ធិអនីតិជនក្នុងអំពើអនីត្យានុកូល** នឹងបកស្រាយពីនីតិវិធី ក្នុងការធ្វើបណ្តឹង និងការការពារខ្លួនពីបណ្តឹងដែលកើតឡើងពីអំពើអនីត្យានុកូល។ ចំពោះជំពូកទី៤ **សិទ្ធិអនីតិជនក្នុងសន្តតិកម្ម** ដែលជាជំពូកចុងក្រោយនៃសំណេរសារណា នឹងធ្វើការសំរាយទៅលើការធ្វើសន្តតិកម្ម ការទទួលយកអច្ច័យទាន ជាអាទ៏។

# ជំពូកទី ១
# សញ្ញាណទូទៅនៃអនីតិជន

ដើម្បីយល់ច្បាស់អំពីប្រធានបទនេះ យើងត្រូវយល់ច្បាស់អំពីនិយមន័យនៃពាក្យសិទ្ធិ និង អនីតិជនជាមុនសិន។ យោងតាមវចនានុក្រមរបស់សម្តេចសង្ឃរាជ ជួន ណាត បានឱ្យនិយមន័យពាក្យសិទ្ធិថា គឺជា សេចក្តីសម្រេច ឬផលសម្រេច ការសម្រេចប្រយោជន៍ ការសមតាមបំណង សេចក្តីសម្រេចតាមអំណាចច្បាប់។ ចំណែកពាក្យថាអនីតិជន គឺជាពាក្យពេចន៍នៃវិស័យច្បាប់ ដែលគឺជាគោលការណ៍មួយ ក្នុងចំណោមគោលការណ៍ទូទៅនៃបញ្ញត្តិទូទៅ ដែលជាការកំណត់នូវអាយុរបស់រូបវន្តបុគ្គលណាម្នាក់ ដែលត្រូវបានគិតថាពុំមានសមត្ថភាពក្នុងការវិនិច្ឆ័យ ទៅលើសកម្មភាពរបស់ខ្លួន ដូចនេះនឹងត្រូវបានការពារដោយច្បាប់។

ជាកំណត់សម្គាល់ផងដែរថា ពាក្យអនីតិជននៅក្នុងបរិបទនៃការស្រាវជ្រាវនេះ គឺសំដៅទៅលើការអនុវត្តនៅក្នុងវិសាលភាពនៃក្រមរដ្ឋប្បវេណីប៉ុណ្ណោះ។ ការកំណត់ន័យ និងសិទ្ធិក្នុងវិសាលភាពរបស់ក្រមព្រហ្មទណ្ឌ គឺមិនត្រូវបានយកមកបកស្រាយឡើយ។

ចំពោះការសិក្សាទៅសិទ្ធិអនីតិជននេះ យើងក៏ត្រូវស្គាល់នូវពាក្យគន្លឹះដែលពាក់ព័ន្ធទៅនឹងសិទ្ធិរបស់អនីតិជន ដូចជាអ្នកមានសិទ្ធិអំណាចមេបា និងអ្នកអាណាព្យាបាលសម្រាប់អនីតិជន។

- អ្នកមានសិទ្ធិអំណាចមេបា គឺជាអ្នកដែលមានសិទ្ធិ និងករណីយកិច្ច ត្រូវបីបាច់រក្សារូបកាយរបស់កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ។[1] ជាធម្មតា អ្នកមានសិទ្ធិអំណាចមេបានេះ គឺសំដៅទៅឪពុកម្តាយបង្កើត ប៉ុន្តែ មានករណីខ្លះពុំដូចនេះទេ។ ករណីនេះអាចមានដូចជា ឪពុកម្តាយចិញ្ចឹមដែលទទួលនូវទំនាក់ទំនងគតិយុត្តតាមរយៈការសុំកូន ក៏ដូចជាបញ្ញត្តិទាំងឡាយដែលមានចែងក្នុងក្រមរដ្ឋប្បវេណីក្នុងគន្ថី ៧ ជំពូកទី ៥ មាត្រា ១០៣៤ ដល់ មាត្រា ១០៦៦។
- អ្នកអាណាព្យាបាលសម្រាប់អនីតិជន គឺសំដៅទៅលើបុគ្គលដែលត្រូវបានជ្រើសតាំងសម្រាប់ការពារអនីតិជន ក្នុងករណីដែលអ្នកមានអំណាចមេបាត្រូវបានទទួលមរណភាព ឬ អ្នកមានអំណាចមេបាត្រូវបានព្យួរ ឬ ដកហូតអំណាចមេបា។ អ្នកអាណាព្យាបាលសម្រាប់អនីតិជន នឹងត្រូវបានជ្រើសតាំងដោយអនុលោមតាមនីតិវិធីដែលបានចែងនៅក្នុងក្រមរដ្ឋប្បវេណី។

ចំពោះសញ្ញាណទូទៅនៃអនីតិជន មានគោលការណ៍ពីរ សំខាន់ៗ គឺ **លក្ខណៈនៃអនីតិជន** (១.១) និង**អត្តាធីនភាព (១.២)**។

[1] មាត្រា ១០៣៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## ១.១ លក្ខណៈនៃអនីតិជន

ដើម្បីកំណត់សិទ្ធិរបស់អនីតិជនបាន ការបង្ហាញនូវលក្ខណៈសំខាន់ៗដែលក្រមរដ្ឋប្បវេណី បានកំណត់គឺជាការចាំបាច់។ ជាទូទៅ ការកំណត់នូវលក្ខណៈរបស់អនីតិជន គឺតែងតែមានការ កំណត់ខុសៗគ្នា ទៅតាមបរិបទសង្គមនៃរដ្ឋនីមួយៗ។

**ឧទាហរណ៍** យោងតាមច្បាប់រដ្ឋប្បវេណីជប៉ុន គេបានកំណត់អាយុនៃអនីតិជនត្រឹម អាយុ ២០ (ម្ភៃ) ឆ្នាំ[2] រីឯប្រទេសកាណាដាវិញ គឺកំណត់ពី ១៨ ទៅ ១៩ ផ្សេងៗគ្នាទៅតាមផ្នែកនៃតំបន់របស់ ប្រទេសនោះ[3]។

ចំពោះក្រមរដ្ឋប្បវេណីនៃព្រះរាជាណាកម្ពុជាវិញ បានកំណត់ និងផ្តល់អត្ថន័យថា អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ[4]។ ទោះបីជាការកំណត់នេះ បានបញ្ជាក់ ច្បាស់លាស់ពីលក្ខណៈនៃអនីតិជនក៏ដោយ ប៉ុន្តែការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពចំពោះ អនីតិជន មានអញ្ញត្រកម្មផ្សេងៗ ដែលអត្ថបទនេះនឹងលើកនៅផ្នែកក្រោយៗ។ ក្នុងចំណោមអញ្ញត្រ កម្មទាំងនោះ អនីតិជនក៏អាចចៀសផុតពីការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពផងដែរក្នុងករណី ដែលអនីតិជននោះបានទទួលនូវ **អត្តាធីនភាព (១.២)**។

ក្នុងនោះដែរ អនីតិជនក៏អាចនឹងក្លាយជាជននៅក្រោមអាណាព្យាបាលទូទៅដែរ ប៉ុន្តែ ប្រសិនបើអនីតិជននោះ គឺជាអនីតិជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ បញ្ញត្តិដែលត្រូវអនុវត្ត គឺស្ថិតនៅក្រោមអត្ថិភាពបញ្ញត្តិស្តីពី ជននៅក្រោមអាណាព្យាបាលទូទៅ។ ដូចនេះ កិច្ចការ ស្រាវជ្រាវនេះ នឹងមិនលើកអនីតិជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅមកបកស្រាយឡើយ ដោយ ហេតុ ការសិក្សានេះផ្តោតទៅលើសិទ្ធិរបស់អនីតិជនធម្មតា រីឯអនីតិជននៅក្រោមអាណាព្យាបាល ទូទៅ គឺស្ថិតនៅក្រោមបទប្បញ្ញត្តិស្តីពី ជននៅក្រោមអាណាព្យាបាលទូទៅ។

## ១.២ អត្តាធីនភាព

ដោយសារតែបរិបទសង្គម អនីតិជនមួយចំនួន ត្រូវចាំបាច់តម្រូវឱ្យមានការទទួលខុសត្រូវ និងមានសិទ្ធិដូចនីតិជន។ ដោយហេតុនេះ ក្រមរដ្ឋប្បវេណី បានចែងនូវបញ្ញត្តិតម្រូវឱ្យស្របទៅ សង្គម ដោយអនុញ្ញាតឱ្យ អនីតិជនអាចទទួលបាននូវអត្តាធីនភាព។

អនីតិជន ដែលទទួលអត្តាធីនភាព ត្រូវបានចាត់ទុកថាបានដល់នីតិភាព[5] ។ ដូចនេះ អនីតិជន ដែលទទួលអត្តាធីនភាព នឹងមានសិទ្ធិ និងកាតព្វកិច្ចដូចនីតិជន ដែលមានអាយុចាប់ពី ១៨ ឆ្នាំ ឡើង

---

[2] សៀវភៅណែនាំសិក្សា ច្បាប់រដ្ឋប្បវេណី ករណីប្រទេសជប៉ុន

[3] ដកស្រង់ចេញពី គេហទំព័រ www.thoughtco.com

[4] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[5] មាត្រា ២២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ទៅ ស្របតាមសេចក្ដីកំណត់របស់ក្រមរដ្ឋប្បវេណី។ ដូចគ្នាដែរ អនីតិជនដែលទទួលអត្តាធីនភាព នឹងរួចផុតពីអំណាចមេបា ឬ អាណាព្យាបាល។

អនីតិជន អាចទទួលអត្តាធីនភាព បានលុះត្រាតែអនីតិជននោះ គោរពលក្ខខណ្ឌមួយចំនួន ដែលនឹងត្រូវបានបកស្រាយនូវចំណុច **១.២.១ (លក្ខខណ្ឌទទួលបានអត្តាធីនភាព)**។

### ១.២.១ លក្ខខណ្ឌទទួលបានអត្តាធីនភាព

យោងតាមមាត្រា ២១ នៃក្រមរដ្ឋប្បវេណី ការទទួលអត្តាធីនភាព កើតឡើងតាមរយៈ ពីរបែប គឺតាមរយៈ ការដាក់ពាក្យសុំអត្តាធីនភាពទៅតុលាការ និងការរៀបអាពាហ៍ពិពាហ៍។

ជម្រើសទីមួយ ដែលអាចនាំឱ្យអនីតិជនទទួលអត្តាធីនភាព គឺតាមការប្រកាសរបស់តុលាការ។ ចំពោះការស្នើសុំត្រូវគោរពទៅតាម **នីតិវិធីនៃការដាក់ពាក្យសុំអត្តាធីនភាព (១.២.២)**។

លក្ខខណ្ឌម្យ៉ាងទៀត ដែលអាចនាំឱ្យ អនីតិជនអាចទទួលអត្តាធីនភាព គឺតាមរយៈការរៀបអាពាហ៍ពិពាហ៍។ យោងតាមក្រមរដ្ឋប្បវេណី អនីតិជន ដែលជាបុរស ឬ នារី អាចនឹងរៀបអាពាហ៍ពិពាហ៍បាន ប្រសិនបើ អនីតិជននោះមានអាយុមិនតិចជាង ១៦ ឆ្នាំ ហើយភាគីម្ខាងទៀតបានដល់នីតិភាព និងដោយមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ[6]។ ក្រោយពី រៀបអាពាហ៍អាពាហ៍ស្របច្បាប់រួច អនីតិជននោះគឺនឹងទទួលអត្តាធីនភាពដោយពុំចាប់បាច់មានការប្រកាសរបស់តុលាការឡើយ។

គួរកត់សម្គាល់ផងដែរថា ដោយសារ នៅក្នុងមាត្រា ៩៤៨ បានចែងថា ក្នុងករណីដែលភាគីម្ខាង បានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន និងនៅក្នុងមាត្រា ២២ ចែងថា អនីតិជនដែលទទួលអត្តាធីនភាព ត្រូវបានចាត់ទុកថា បានដល់នីតិភាព ដូចនេះ អនីតិជនអាចរៀបអាពាហ៍ពិពាហ៍ជាមួយភាគីម្ខាងទៀតដែលជាអនីតិជនទទួលអត្តាធីនភាពតាមប្រកាសរបស់តុលាការបាន ហើយនឹងធ្វើឱ្យ អនីតិជនដែលពុំមានអត្តាធីនភាពនោះ ទទួលអត្តាធីនភាពបានដែរ ព្រោះយោងតាមមាត្រា ២២ ឱ្យតែអាពាហ៍ពិពាហ៍នេះ គោរពទៅតាមបញ្ញត្តិច្បាប់។

### ១.២.២ នីតិវិធីនៃការដាក់ពាក្យសុំអត្តាធីនភាព

ដើម្បីទទួលអត្តាធីនភាពបានតាមការដាក់ពាក្យស្នើសុំទៅតុលាការ អនីតិជនចាំបាច់ត្រូវមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ឡើង។ ក្រោយពីការដាក់ពាក្យរួច តុលាការនឹងពិនិត្យមើលទៅលើស្ថានភាពនៃជីវភាពរបស់អនីតិជន និងភាពចាំបាច់ ក៏ដូចជាប្រយោជន៍នៃការទទួលអត្តាធីនភាពរបស់អ្នកស្នើនោះ។

[6] មាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ប្រសិនបើតុលាការពិនិត្យទៅឃើញថា ការស្នើសុំនេះសមស្របហើយ តុលាការអាចនឹងប្រកាសនូវអត្តាធីនភាពរបស់បុគ្គលនោះ ដោយមុននឹងប្រកាសត្រូវមានការសួរយោបល់ពីសំណាក់ជនដែលមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន។[7]

### ១.២.៣ អានុភាពនៃអត្តាធីនភាព

#### ក. សិទ្ធិ និងករណីយកិច្ចនៃជនដែលទទួលបានអត្តាធីនភាព

ដូចបានលើកឡើងខាងលើ អនីតិជនដែលទទួលអត្តាធីនភាព នឹងត្រូវបានទទួលនូវសិទ្ធិ និងកាតព្វកិច្ច ដូចទៅនឹងនីតិជនដែលមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ។ ក្នុងករណីនេះមានន័យថា អនីតិជនដែលទទួលអត្តាធីនភាព អាចមានសមត្ថភាពក្នុងការបង្កើតកិច្ចសន្យា និងសកម្មភាពឯកតោភាគីដោយមានសុពលភាពតែម្នាក់ឯងបាន ដោយពុំចាំបាច់មានការយល់ព្រមពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនឡើយ។ ក៏ដូចគ្នាដែរ អនីតិជនដែលទទួលអត្តាធីនភាព នឹងត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ច ដែលបានកើតឡើងចាប់តាំងពីពេលទទួលនូវអត្តាធីនភាពមក ដោយគោរពអនុលោមដូចគ្នាទៅនឹងនីតិជន។

#### ខ. ភាពមិនរលត់នៃអត្តាធីនភាព

យោងតាមការបកស្រាយខាងលើ អនីតិជនអាចទទួលអត្តាធីនភាពតាមរយៈអាពាហ៍ពិពាហ៍ស្របច្បាប់ ប៉ុន្តែចុះបើអនីតិជននោះ ត្រូវបានលែងលះនៅក្នុងអំឡុងពេលអាយុ ចាប់ពី១៦ ទៅក្រោម១៨ តើសិទ្ធិ និងកាតព្វកិច្ចរបស់អនីតិជននោះ នឹងត្រូវបញ្ញត្តដូចម្តេច? ចំពោះករណីនេះ អត្តាធីនភាពរបស់អនីតិជននោះ ពុំត្រូវរលត់ឡើយ យោងតាមមាត្រា ២១ កថាខណ្ឌទី៣[8]។ ដូចនេះ បានន័យថា ក្រោយលែងលះហើយ អនីតិជននោះនៅតែត្រូវបានចាត់ទុកថា ទទួលអត្តាធីនភាព និងមានសិទ្ធិ និងកាតព្វកិច្ចដូចនីតិជន ដូចបានលើកឡើងក្នុងចំណុច ក ខាងលើ។

[7] មាត្រា ២១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[8] មាត្រា ២១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# ជំពូកទី ២
# សិទ្ធិអនីតិជនក្នុងកិច្ចសន្យា

ជាធម្មតា យើងបានដឹងថា អនីតិជន គឺជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ពោលគឺ អនីតិជន ត្រូវបានកម្រិតនូវសិទ្ធិ និងកាតព្វកិច្ច ដើម្បីការពារទៅដល់ប្រយោជន៍របស់អនីតិជន។ ចំពោះជំពូកនេះ ការបកស្រាយចំពោះសិទ្ធិ និងកាតព្វកិច្ចរបស់អនីតិជន ចំពោះសកម្មភាពនៅក្នុងការបង្កើតកិច្ចសន្យានឹងត្រូវបានធ្វើឡើង។ ដូចនេះ យើងត្រូវយល់ថាអ្វីទៅជាកិច្ចសន្យា។

កិច្ចសន្យាត្រូវបានឱ្យនិយមន័យថា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើតកែប្រែ ឬ រំលត់កាតព្វកិច្ច។[9] អាចនិយាយម៉្យាងទៀតបានថា គឺជាអានុភាពដែលកើតឡើងដោយសារ សំណើ និងស្វីការត្រូវគ្នា។[10] សំណើ គឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមាន ឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ។ រីឯស្វីការ គឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើ។[11]

ដូចនេះ បានន័យថា ទោះបីជាបុគ្គលពីរ ឬ ច្រើននាក់ បានព្រមព្រៀងគ្នាចំពោះការបង្កើត ឬ រំលត់កាតព្វកិច្ចហើយក៏ដោយ សកម្មភាពទាំងនេះ ត្រូវយកបញ្ញត្តិពីការកម្រិតសកម្មភាពរបស់អនីតិជនមកអនុវត្ត បើសិទ្ធិភាគីនៃការព្រមព្រៀងនោះជាអនីតិជន។

នៅក្នុងជំពូកនេះ សិទ្ធិរបស់អនីតិជនដែលពាក់ព័ន្ធនឹងការធ្វើការព្រមព្រៀង ឬ កិច្ចសន្យាត្រូវលើកឡើងមកបកស្រាយ ដូចជា **ស្វ័យភាពនៃសិទ្ធីអនីតិជន (២.១) សិទ្ធិអនីតិជនដែលទទួលបានដោយអ្នកមានអំណាចមេបា (២.២)** និង**ការលុបចោល និងការរំលាយកិច្ចសន្យារបស់អនីតិជន (២.៣)**។

## ២.១ ស្វ័យភាពនៃសិទ្ធិអនីតិជន

ស្វ័យភាពនៃសិទ្ធិអនីតិជន គឺសំដៅទៅលើសកម្មភាពមួយចំនួន ដែលក្រមរដ្ឋប្បវេណីបានអនុញ្ញាតដល់អនីតិជនក្នុងការធ្វើសកម្មភាពដោយខ្លួនឯង ដោយពុំចាំបាច់ត្រូវមានការអនុញ្ញាតពីសំណាក់ អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនទេ។ សិទ្ធិទាំងនេះមានដូចជា **សិទ្ធិទាក់ទងនឹងជីវភាពប្រចាំថ្ងៃ (២.១.១) សិទ្ធិដែលមិនជាប់កាតព្វកិច្ច (២.១.២)** និង**សិទ្ធិទាក់ទងនឹងកិច្ចសន្យាការងារ (២.១.៣)**។

---

[9] មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[10] មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[11] មាត្រា ៣៣៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ២.១.១ សិទ្ធិទាក់ទងនឹងជីវភាពប្រចាំថ្ងៃ

គោលបំណងនៃការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព គឺធ្វើឡើងដើម្បីការពារទៅដល់ជនដែលពុំមានការពិចារណាគ្រប់គ្រាន់។ ប៉ុន្តែបើការកម្រិតសកម្មភាពគ្រប់យ៉ាងនោះ អនីតិជននឹងមានការលំបាកនៅក្នុងការប្រាស្រ័យទាក់ទង និងការរស់នៅក្នុងសង្គម។ ឧទាហរណ៍ បើអនីតិជនចង់ទិញម្ហូបអាហារដើម្បីបរិភោគ ដែលសកម្មភាពនេះត្រូវបានចាត់ទុកជាកិច្ចសន្យាទិញលក់ ហើយចាំបាច់ត្រូវមានការយល់ព្រមពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលរបស់អនីតិជននោះ ការទិញម្ហូបអាហារដើម្បីបរិភោគនឹងផ្តល់នូវផលលំបាក និងធ្វើឱ្យខូចដល់ផលប្រយោជន៍របស់អនីតិជន។ ដោយហេតុនេះ នៅក្នុងមាត្រា ១៨ បានលើកឡើងនូវអញ្ញត្រកម្មចំពោះសកម្មភាពទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។[12]

សកម្មភាពទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ជាសកម្មភាពដែលមានភាពងាយស្រួលក្នុងការវិនិច្ឆ័យជាទូទៅមានតម្លៃទឹកប្រាក់ទាប ដែលមិនមានការព្រួយបារម្ភអំពីការខូចខាតផលប្រយោជន៍របស់អនីតិជន។[13] ដូចនេះ សកម្មភាពទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ សំដៅទៅលើសកម្មភាពដូចជា ការទិញសំលៀកបំពាក់ ការទិញបរិភោគ ការបង់ទឹកភ្លើង ជាអាទិ៍។

ដោយឡែកការវិនិច្ឆ័យថា សកម្មភាពអ្វីខ្លះ ជាសកម្មភាពទាក់ទងនឹងជីវភាពប្រចាំថ្ងៃ មានសារៈសំខាន់ណាស់។ ដូចបានលើកឡើងថា ជាសកម្មភាពងាយស្រួលក្នុងការវិនិច្ឆ័យជាទូទៅមានតម្លៃទឹកប្រាក់ទាប ដូចនេះ ការទិញសំលៀកបំពាក់ដែលមានតម្លៃទាប គឺអាចធ្វើបាន ប៉ុន្តែចំពោះសំលៀកបំពាក់ ដែលមានតម្លៃថ្លៃហួសហេតុ គឺមិនអាចធ្វើបានឡើយ។

### ២.១.២ សិទ្ធិដែលមិនជាប់កាតព្វកិច្ច

សិទ្ធិដែលមិនជាប់កាតព្វកិច្ច គឺសំដៅទៅលើសិទ្ធិក្នុងការធ្វើសកម្មភាពដែលទទួលសិទ្ធិ ឬឱ្យរួចផុតពីកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា ១៨ នៃក្រមរដ្ឋប្បវេណី។ សកម្មភាពដែលទទួលសិទ្ធិ គឺជាសកម្មភាពដែលអនីតិជនទទួលនូវសិទ្ធិអ្វីមួយ ដែលពុំមានជាប់បន្ទុក។ ឧទាហរណ៍ អនីតិជនបានទទួលនូវប្រទានកម្មនូវវត្ថុ នៅថ្ងៃខួបកំណើតរបស់ខ្លួន។ ការទទួលបាននេះ គឺជាកិច្ចសន្យាទទួលសិទ្ធិទៅលើវត្ថុនោះ ដោយពុំមានបន្ទុកអ្វីឡើយ។ រីឯ សកម្មភាពដែលឱ្យរួចផុតពីកាតព្វកិច្ច គឺជាសកម្មភាពទាំងឡាយណាដែលធ្វើឡើង ដើម្បីឱ្យអនីតិជន រួចផុតពីកាតព្វកិច្ចដែលធ្វើឱ្យខូចប្រយោជន៍ខ្លួន។ ឧទាហរណ៍ ការរំលាយនូវកិច្ចសន្យាទិញលក់របស់អនីតិជនដោយពុំមានការបង់ថ្លៃដែលជាកាតព្វកិច្ចនៃកិច្ចសន្យានោះ។

[12] មាត្រា ១៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[13] ទំព័រ ១៥ នៃឯកសាររបស់ក្រុមការងារសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវទ្យាសាស្ត្រសេដ្ឋកិច្ច នៃ មេរៀន ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ របស់ក្រសួងយុត្តិធម៌

ការបញ្ញត្តនូវលក្ខខណ្ឌនេះ គឺដោយហេតុឃើញថា សកម្មភាពទាំងនេះ គឺមានគោលបំណង ដែលផ្តល់នូវផលប្រយោជន៍ដល់អនីតិជន ពុំមែនជាសកម្មភាពដែលធ្វើឱ្យខាតដល់ប្រយោជន៍របស់អនីតិជន ដែលលក្ខខណ្ឌគ្រឹះនៃគោលការណ៍ការពារដល់ជនកង្វះសមត្ថភាពក្នុងការវិនិច្ឆ័យ។

### ២.១.៣ សិទ្ធិទាក់ទងនឹងកច្ចសន្យាការងារ

ជាធម្មតា ជនដែលអាចប្រកបការងារបាន ត្រូវបានបញ្ញត្តឱ្យមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ដោយហេតុតែ មានជនខិលខូចប្រើប្រាស់នូវការកង្វះសមត្ថភាពក្នុងការវិនិច្ឆ័យរបស់អនីតិជន ដើម្បីផលប្រយោជន៍ខ្លួន និងកត្តាកាយសម្បទានរបស់អនីតិជនផងដែរ។ ប៉ុន្តែ ប្រសិនបើយើងពិនិត្យមើលទៅក្នុងសង្គមសព្វថ្ងៃ ភាពកង្វះខាតហិរញ្ញវត្ថុគឺជាបញ្ហាមួយ ដែលត្រូវបង្ខំឱ្យអនីតិជនត្រូវរកការងារដើម្បីចិញ្ចឹមជីវិត។ ដើម្បីសម្រួលទៅដល់ជីវិតរបស់ពលរដ្ឋ ជាពិសេសអនីតិជន ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានសម្រេចឱ្យ អនីតិជនមានស្វ័យភាពក្នុងការបង្កើតនូវកិច្ចសន្យាការងារ ប៉ុន្តែត្រូវគោរពលក្ខខណ្ឌមួយចំនួន[14] ក៏ដូចជាមានចែងនៅក្នុងច្បាប់ពិសេស គឺច្បាប់ស្តីពី ការងារ របស់ព្រះរាជាណាចក្រកម្ពុជា។

កិច្ចសន្យាការងារ គឺជាកិច្ចសន្យាដែលបង្កើតឱ្យមានការទាក់ទងផ្នែកការងារ រវាងកម្មករនិយោជិត និងនិយោជក[15]។ មានន័យថា ជនដែលបានចុះកិច្ចសន្យាការងារហើយ នឹងទទួលបាននូវសិទ្ធិ និងកាតព្វកិច្ច ជាមួយនឹងនិយោជក ដូចមានចែងក្នុងកិច្ចសន្យា។

យោងតាមច្បាប់ស្តីពីការងាររបស់ព្រះរាជាណាចក្រកម្ពុជា គេបានកំណត់អាយុអប្បបរមាសម្រាប់ការប្រកបការងារត្រឹម ១៥ (ដប់ប្រាំ) ឆ្នាំ[16] ដោយក្នុងនោះក៏បានចែងផ្សេងៗទៀតនូវអាយុសម្រាប់ប្រភេទការងារដែលមានផលប៉ះពាល់មួយចំនួន។

សម្រាប់ក្រមរដ្ឋប្បវេណីវិញ អនីតិជនត្រូវបានការពារចំពោះការចុះកិច្ចសន្យាការងារ ដោយបញ្ញត្តថា អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនអាចធ្វើកិច្ចសន្យាការងារជំនួសអនីតិជនបានឡើយ។ បើពិនិត្យទៅមើលលើ មាត្រា ១០៥៣ និងមាត្រា ១០៨០ ការងារចុះកិច្ចសន្យា អាចធ្វើបានតាមរយៈអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ប៉ុន្តែ ដើម្បីការពារនូវការកេងប្រវ័ញ្ចនូវពលកម្មកុមារ មាត្រា ២៣ បានចងនូវលក្ខខណ្ឌដែលតម្រូវឱ្យអនីតិជន ជាអ្នកចុះកិច្ចសន្យាផ្ទាល់ ព្រោះសកម្មភាពនេះ គឺបានបង្កើតនូវកាតព្វកិច្ចចំពោះអនីតិជន ដូចនេះ អនីតិជនត្រូវតែជាអ្នកផ្តល់ការយល់ព្រម។

[14] មាត្រា ២៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[15] មាត្រា ៦៥ នៃច្បាប់ ស្តីពី ការងារ

[16] មាត្រា ១៧៧ នៃច្បាប់ស្តីពីការងារ

គួរកត់សម្គាល់ថា ទោះបីជាអនីតិជនមានសិទ្ធិក្នុងការបង្កើតកិច្ចសន្យាការងារក៏ដោយ ក៏ត្រូវទទួលបានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ទើបកិច្ចសន្យាការងារមានប្រសិទ្ធិភាព។

## ២.២ សិទ្ធិអនីតិជនដែលទទួលបានដោយអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន

ដោយសារតែអនីតិជន គឺជាជនត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព ដោយហេតុផលកង្វះសមត្ថភាពក្នុងការវិនិច្ឆ័យ ដូចនេះ ជារឿយៗ តែងតែផ្ដល់នូវផលលំបាកទៅដល់អនីតិជនផ្ទាល់។ ដើម្បីសម្រួលឱ្យអនីតិជនអាចធ្វើសកម្មភាពផ្សេងៗមួយចំនួនបាន ក្រមរដ្ឋប្បវេណីបានចែងឱ្យ អនីតិជនអាចធ្វើសកម្មភាពបាន ក្នុងករណីដែលអនីតិជននោះត្រូវបានទទួលការអនុញ្ញាតពីសំណាក់អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលរបស់អនីតិជន ព្រោះអ្នកទាំងនេះ គឺជាអ្នកមានកាតព្វកិច្ចមើលថែការពារអនីតិជន ដូចនេះ ត្រូវបានជឿជាក់ថានឹងផ្ដល់នូវសេចក្ដីយល់ព្រមលើសកម្មភាពណា ដែលខ្លួនគិតថាអនីតិជននឹងមិនបាត់បង់ផលប្រយោជន៍។

សិទ្ធិដែលអនីតិជនទទួលបានពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវបានបែងចែកជា៣ គឺ **សិទ្ធិចាត់ចែងទ្រព្យសម្បត្តិដោយកំណត់គោលបំណង (២.២.១) សិទ្ធិចាត់ចែងទ្រព្យសម្បត្តិដោយមិនកំណត់គោលបំណង (២.២.២)** និង**សិទ្ធិក្នុងការប្រកបអាជីវកម្ម (២.២.៣)**។

### ២.២.១ សិទ្ធិចាត់ចែងទ្រព្យសម្បត្តិដោយកំណត់គោលបំណង

ដូចបានលើកឡើងថា អនីតិជនត្រូវបានកម្រិតសិទ្ធិ ក្នុងការចាត់ចែងទ្រព្យសម្បត្តិ ហើយចំពោះការចាត់ចែងទ្រព្យសម្បត្តិត្រូវបានធ្លាក់ទៅលើអ្នកដែលមានសិទ្ធិតំណាង គឺអ្នកមានអំណាចមេបា និងអ្នកអាណាព្យាបាលរបស់អនីតិជន។

ប៉ុន្តែ យោងតាមមាត្រា ១៩ បានចែងថា អនីតិជនអាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែង ដោយកំណត់គោលបំណងបាន ហើយអនីតិជនអាចចាត់ចែងក្នុងទំហំនៃគោលបំណងនេះ ។[17] ក្នុងករណីនេះ អនីតិជនអាចនឹងបង្កើតនូវកិច្ចសន្យាដែលទាក់ទងនឹងទ្រព្យសម្បត្តិរបស់ខ្លួន មានន័យថា ក្នុងករណីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានផ្ដល់ទ្រព្យសម្បត្តិ ដូចជាប្រាក់ជាដើមដល់អនីតិជន ដោយកំណត់គោលបំណងក្នុងការប្រើប្រាស់ នោះ អនីតិជនមានសិទ្ធិក្នុងការធ្វើសកម្មភាពចាត់ចែងទ្រព្យនោះ ទៅតាមគោលបំណងដែលបានអនុញ្ញាត។

[17] មាត្រា ១៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ឧទាហរណ៍** ដាលីន មានអាយុ ១៧ ឆ្នាំ បានសុំលុយពីឪពុកម្ដាយ ដើម្បីទៅទិញទូរស័ព្ទដៃ ចំនួន ៥០០ ដុល្លា ហើយឪពុកម្ដាយក៏បានយល់ព្រម ដោយធ្វើប្រទានកម្មលុយចំនួន ៥០០ ដុល្លារ។ ក្នុងករណីនេះ ដាលីន អាចយកលុយនោះ ទៅធ្វើសកម្មភាពបង្កើតកិច្ចសន្យាទិញលក់ទូរស័ព្ទដូចអ្វីដែលបានសុំបាន ដោយហេតុថា បានទទួលនូវការយល់ព្រមពីសំណាក់ឪពុកម្ដាយ ហើយគោលបំណងនៃការប្រើប្រាស់ទ្រព្យនោះ ក៏ត្រូវបានកំណត់ជាក់លាក់ គឺសម្រាប់ទិញទូរស័ព្ទ។

### ២.២.២ សិទ្ធិចាត់ចែងទ្រព្យសម្បត្តិដោយមិនកំណត់គោលបំណង

ទោះជាមានការផ្ដល់សិទ្ធិទៅលើអនីតិជនក្នុងការចាត់ចែងទ្រព្យសម្បត្តិដោយមានការកំណត់គោលបំណងក៏ដោយ អនីតិជននៅតែមានភាពលំបាកក្នុងការអនុវត្ត ឬ ធ្វើសកម្មភាពសម្រាប់ជីវភាពរបស់ខ្លួន ដោយហេតុការប្រើប្រាស់ទ្រព្យសម្បត្តិម្ដងត្រូវតែកំណត់នូវគោលបំណងច្បាស់លាស់ ប៉ុន្តែនៅក្នុងសង្គមផ្ទាល់ ពេលខ្លះអនីតិជនចាំបាច់ត្រូវការប្រើប្រាស់ទ្រព្យដែលខ្លួនរកបាន ឬ ទទួលបានប្រទានកម្មនោះ សម្រាប់សកម្មភាពតូចតាចដែលខ្លួនចាំបាច់ភ្លាមៗ។

ដូចនេះ ក្រៅពីសិទ្ធិចាត់ចែងទ្រព្យសម្បត្តិដោយកំណត់គោលបំណង អនីតិជនក៏អាចចាត់ចែងនូវទ្រព្យសម្បត្តិ ដែលខ្លួនទទួលពីការអនុញាតពីសំណាក់ អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយមិនមានការកំណត់គោលបំណងដែរ។ ការលើកឡើងនេះគឺដោយផ្អែកទៅលើមាត្រា ១៩ ដែលបានចែងថា អនីតិជនក៏អាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន បានអនុញ្ញាតឱ្យចាត់ចែងដោយមិនបានកំណត់គោលបំណងបានដែរ។ បញ្ញត្តិក្នុងមាត្រានេះ ទទួលស្គាល់ថាអនីតិជនមានសិទ្ធិក្នុងការចាត់ចែងទ្រព្យសម្បត្តិ ឬ ការចាយវាយកំប៉ិកកំប៉ុក ដោយមិនបានកំណត់គោលដៅប្រើប្រាស់ ដោយការធ្វើសកម្មភាពនោះស្ថិតនៅក្នុងទំហំនូវអ្វីដែលបានទទួលការអនុញ្ញាតរបស់អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ហើយកិច្ចសន្យាដែលកើតឡើងពីសកម្មភាពរបស់អនីតិជននេះ នឹងមានសុពលភាពពេញលេញ។[18]

**ឧទាហរណ៍** ក្មេងម្នាក់អាយុ ១៥ ឆ្នាំ ត្រូវបានឪពុកម្ដាយផ្ដល់ប្រាក់ចាយវាយប្រចាំថ្ងៃ ចំនួន ១០០០០រៀល។ កូននោះអាចប្រើប្រាស់លុយនោះ ទៅទិញតុក្កតា ដែលមានតម្លៃស្ថិតនៅក្នុងចំនួនទឹកប្រាក់ដែលឪពុកម្ដាយបានអនុញ្ញាតនោះបាន។

### ២.២.៣ សិទ្ធិក្នុងការប្រកបអាជីវកម្ម

សិទ្ធិមួយទៀត ដែលអនីតិជនអាចនឹងធ្វើសកម្មភាពបាន ដោយមានការអនុញ្ញាតពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន គឺសិទ្ធិក្នុងការប្រកបអាជីវកម្ម។ ដើម្បីឱ្យ

[18] សេចក្តីកំណត់មាត្រា ១៩ នៃក្រមរដ្ឋប្បវេណី

អនីតិជនមានជម្រើសក្នុងការធ្វើឱ្យជីវភាពរបស់ខ្លួន មានភាពប្រសើរឡើង អនីតិជនត្រូវបានផ្តល់នូវសិទ្ធិក្នុងការប្រកបអាជីវកម្មមួយ ឬ ច្រើនប្រភេទ ប៉ុន្តែការអនុញ្ញាតនេះ ត្រូវចាំបាច់មានការទទួលស្គាល់ពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន។

មាត្រា ២០ បានចែងថា អនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទ ពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថភាពដូចនីតិជន ចំពោះមុខជំនួញ[19]។ បញ្ញត្តិនេះ បានអនុញ្ញាតឱ្យអនីតិជនធ្វើអាជីវកម្មបានបើសិនមានការទទួលស្គាល់ពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ហើយក្រោយពីទទួលបានការយល់ព្រមនោះហើយ អនីតិជននឹងមានឯករាជ្យភាពចំពោះប្រតិបត្តិការក្នុងកិច្ចប្រកបអាជីវកម្ម ដូចនីតិជន។ ការកំណត់បែបនេះ មានគោលបំណងសម្រួលទៅដល់ប្រតិបត្តិការជំនួញរបស់អនីតិជន ព្រោះថា បើគ្រប់ប្រតិបត្តិការទាំងអស់មុននឹងអាចដំណើរការបានទាល់តែមានការយល់ព្រមពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ការប្រកបអាជីវកម្មនឹងមានសភាពរាំងស្ទះ ធ្វើឱ្យខាតប្រយោជន៍ដល់អាជីវកម្ម និងធ្វើឱ្យអាជីវកម្មនេះហាក់មិនសូវមានន័យ។ ឧទាហរណ៍ បើអនីតិជនបានប្រកបនូវអាជីវកម្ម លក់ផ្លែឈើ ការនាំចូលផ្លែឈើ ក៏ត្រូវចាំមានការយល់ព្រមពីឪពុកម្តាយ ការលក់ផ្លែឈើដល់អតិថិជន ក៏ត្រូវចាំឱ្យឪពុកម្តាយផ្តល់ការយល់ព្រមនោះ អាជីវកម្មនោះ នឹងពុំអាចប្រព្រឹត្តទៅដោយទទួលផលប្រយោជន៍ឡើយ។

ដូចនេះ ក្រោយពីមានការយល់ព្រមហើយ អនីតិជន អាចនឹងមានសមត្ថភាពធ្វើសកម្មភាពក្នុងការធ្វើកិច្ចសន្យាចាំបាច់សម្រាប់អាជីវកម្មនោះ។ ពោល គឺមានសិទ្ធិក្នុងការធ្វើកិច្ចសន្យាចាំបាច់ផ្សេងៗសម្រាប់អាជីវកម្មនោះ ប៉ុន្តែអនីតិជននោះពុំមានសមត្ថភាពបង្កើតកិច្ចសន្យាណាផ្សេង ដែលហួសពីទំហំនៃភាពចាំបាច់សម្រាប់អាជីវកម្មខ្លួនឡើយ លុះត្រាតែមានការយល់ព្រមផ្សេង ពីសំណាក់អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន គោរពទៅតាមបញ្ញត្តិដែលបានចែង។

បន្ថែមពីនេះដែរ អនីតិជនដែលបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម បែរជាយកដើមទុនសម្រាប់រកទទួលទាន ទៅលេងល្បែងស៊ីសង ឬ ទិញតែទំនិញដែលលក់មិនដាច់ ជាដើម ដែលខុសពីអ្វីដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនគិតនោះ អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតដែលខ្លួនបានផ្តល់រួចហើយ ដោយផ្អែកតាម កថាខណ្ឌទី២ នៃមាត្រា ២០។ ប៉ុន្តែបើករណីគ្រាន់តែការផ្លាស់ប្តូរគំនិតរបស់អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អានីតិជននោះទេ ការលុបចោល ឬ កម្រិតការអនុញ្ញាតមិនអាចប្រព្រឹត្តបានឡើង។ បើអនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម

[19] មាត្រា ២០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ត្រូវបានលុបចោលនូវការអនុញ្ញាត សមត្ថភាពក្នុងការធ្វើសកម្មភាពរបស់អនីតិជននោះ ត្រូវត្រលប់ទៅស្ថានភាពដើមដូចអនីតិជនធម្មតា[20]។

## ២.៣ ការលុបចោល និងការរំលាយកិច្ចសន្យារបស់អនីតិជន

អនីតិជន គឺស្ថិតនៅក្នុងចំណោមជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព ក្នុងនោះមានបុគ្គលផ្សេងទៀតគឺ ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ។ អនីតិជន ដូចបានបកស្រាយខាងលើនេះស្រាប់ គឺជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ដោយហេតុអនីតិជន ត្រូវបានចាត់ទុកថាជាជននៅខ្វះសមត្ថភាព ក្នុងការវិនិច្ឆ័យខុស និងត្រូវ។ ដូចនេះ ដើម្បីការពារផលប្រយោជន៍អនីតិជន ក្រមរដ្ឋប្បវេណីបានបញ្ញត្តនូវគោលការណ៍នៃការលុបចោលនូវសកម្មភាព និងរំលាយកិច្ចសន្យា ដែលបានធ្វើឡើងដោយអនីតិជន លើកលែងតែ ចំពោះសកម្មភាពដែលទទួលបានសិទ្ធិ ឬ ឱ្យរួចផុតពីកាតព្វកិច្ច ឬ សកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ[21] ដូចអ្វីដែលបានលើកឡើងនូវក្នុងចំណុច **២.១ (ស្វ័យភាពនៃសិទ្ធិអនីតិជន)** ឬ ទទួលបាននូវការយល់ព្រមពីសំណាក់អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ដូចនឹងការបកស្រាយក្នុងចំណុច **២.២ (សិទ្ធិដែលអនីតិជនទទួលបានពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន)**។

ប៉ុន្តែ ដោយឃើញថា បើឱ្យតែសកម្មភាពរបស់អនីតិជនត្រូវតែលុបចោល ឬ រំលាយនោះ ការអនុវត្តសម្រាប់ជីវភាពប្រចាំថ្ងៃ គឺពិតជាមានផលលំបាក ហើយអ្នកធ្វើជំនួញនានា នឹងអាចមានភាពខ្លាចក្រែង ក្នុងការប្រកបអាជីវកម្មរបស់ខ្លួន ដោយហេតុតែ អាជីវករអាចនឹងពុំដឹងនូវបុគ្គលភាពរបស់ភ្ញៀវខ្លួន។ ដូចនេះដើម្បីសម្រួលទៅដល់សកម្មភាពចាំបាច់សម្រាប់ជីវភាពបុគ្គលនីមួយៗ ក្រមរដ្ឋប្បវេណីក៏បានចែងដូចគ្នានូវបញ្ញត្តិសម្រាប់ការពារទៅដល់ភាគីម្ខាងទៀត ដែលបានធ្វើទំនាក់ទំនងជាមួយចំពោះអនីតិជន ក៏ដូចជាការពារកុំឱ្យមានជនខិលខូចមួយចំនួនដែលអាចនឹងយកគោលការណ៍ការពារទៅដល់អនីតិជន មកប្រព្រឹត្តនូវអំពើទុច្ចរិតផ្សេងៗ ជាពិសេសគឺការឆបោក។

នៅក្នុងចំណុច ២.៣ នេះ លក្ខខណ្ឌផ្សេងៗ ដែលទាក់ទងនឹងការលុបចោល និងការរំលាយកិច្ចសន្យារបស់អនីតិជន នឹងត្រូវបានលើកមកបកស្រាយ ដើម្បីឱ្យមានការយល់ច្បាស់ពីអ្វីខ្លះដែលអាចជាកិច្ចការពារភាគីនៃសកម្មភាព។ លក្ខខណ្ឌទាំងនោះមានដូចជា **ការលុបចោលកិច្ចសន្យារបស់អនីតិជន (២.៣.១) ការរំលាយកិច្ចសន្យាការងាររបស់អនីតិជន (២.៣.២)** និង**ការការពារភាគីម្ខាងទៀតចំពោះអនីតិជន (២.៣.៣)**។

[20] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី មាត្រា ២០

[21] មាត្រា ១៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ២.៣.១ ការលុបចោលកិច្ចសន្យារបស់អនីតិជន

ចំពោះអនីតិជន ការបង្កើតកិច្ចសន្យាអាចកើតឡើងក្នុងករណី ដែលអនីតិជននោះបានទទួលនូវការយល់ព្រមពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ហើយបើកិច្ចសន្យានោះពុំមានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកនោះទេ កិច្ចសន្យានោះនឹងត្រូវមានវិការៈ ដែលជាលក្ខខណ្ឌមួយនៅក្នុងការលុបកិច្ចសន្យា។[22]

ការលុបចោល គឺសំដៅទៅលើការបដិសេធសុពលភាពនៃសកម្មភាពគតិយុត្ត។ ដូចនេះបានន័យថា កិច្ចសន្យាដែលបង្កើតឡើងដោយអនីតិជន នឹងត្រូវអាចបដិសេធនូវសុពលភាពរបស់កិច្ចសន្យានោះបាន។ អ្នកដែលមានសិទ្ធិលុបកិច្ចសន្យារបស់អនីតិជន ដែលអាចហៅម្យ៉ាងទៀតបានថា បុគ្គលមានសិទ្ធិលុបចោលសកម្មភាពរបស់អនីតិជន មានដូចជា អនីតិជនសាមីខ្លួន អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន។[23]

**ឧទាហរណ៍** និមល បានទិញម៉ូតូពី សិលា ក្នុងតម្លៃ ១០០០ដុល្លារ។ និមល មានអាយុត្រឹមតែ ១៩ ឆ្នាំ ហើយការទិញម៉ូតូនេះ គឺដោយពុំមានការអនុញ្ញាតពីឪពុកម្តាយឡើយ។ ក្នុងករណីនេះ ឪពុកម្តាយរបស់ និមល ដែលជាអ្នកមានអំណាចមេបា មានសិទ្ធិក្នុងការលុបចោលកិច្ចសន្យាទិញលក់ម៉ូតូនេះ។ ដូចនេះ សិលា ត្រូវប្រគល់លុយឱ្យទៅ និមល ឬ ឪពុកម្តាយរបស់ និមល វិញ ហើយខាងនិមលក៏ត្រូវប្រគល់ម៉ូតូឱ្យទៅភាគី សិលា វិញដែរ។

ទោះបីជា កិច្ចសន្យាដែលគ្មានការយល់ព្រមពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចនឹងលុបចោលបានក៏ដោយ ក៏កិច្ចសន្យានេះអាចនឹងមានសុពលភាពពេញលេញ ក្នុងលក្ខខណ្ឌដែល អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន បានផ្តល់នូវសច្ចានុមតិចំពោះសកម្មភាពរបស់អនីតិជននោះ។

សច្ចានុមតិ គឺជាសកម្មភាពដែលបុគ្គលមានសិទ្ធិលុបចោល បង្ហាញជាស្ថាពរថាខ្លួនមិនអនុវត្តសិទ្ធិលុបចោល ដោយផ្អែកលើបុរេលក្ខខណ្ឌ ដែលបានដឹងថាសកម្មភាពរបស់ខ្លួនអាចលុបចោលបាន។[24] ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោលបានផ្តល់សច្ចានុមតិ ទៅលើសកម្មភាពដែលអាចលុបចោលហើយ សិទ្ធិលុបចោលរបស់បុគ្គលនោះនឹងត្រូវបានរលត់ ដូចនេះ សកម្មភាពនោះនឹងមិនអាចលុបចោលនៅពេលក្រោយបានឡើយ។ ការធ្វើសច្ចានុមតិ និងការលុបចោល គឺអាចធ្វើឡើងនៅក្រៅតុលាការបាន។

**ឧទាហរណ៍** ដូច និមល និងសិលា ដែលបានធ្វើកិច្ចសន្យាទិញលក់ម៉ូតូខាងលើអញ្ចឹង បើ

---

[22] មេរៀនស្តីពី ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ២ កិច្ចការក្រុមការងារក្រសួងយុត្តិធម៌ ទំព័រ៦

[23] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ទំព័រ២៥

[24] មេរៀនស្តីពី ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ២ កិច្ចការក្រុមការងារក្រសួងយុត្តិធម៌ ទំព័រ៦

ឪពុកម្ដាយរបស់ និមល បានដឹងលឺ និងយល់ព្រមក្រោយពីកិច្ចសន្យាបានបង្កើតហើយនោះ ឪពុកម្ដាយរបស់និមល បានផ្ដល់សច្ចានុមតិ ហើយនឹងអស់សិទ្ធិក្នុងការលុបចោលការទិញម៉ូតូនេះនៅពេលក្រោយដែរ។

រួមមកវិញ ការផ្ដល់សច្ចានុមតិទៅលើសកម្មភាពរបស់អនីតិជន អាចធ្វើឡើងតាមរយៈលក្ខខណ្ឌចំនួនបី គឺ

១. អនីតិជនអាចធ្វើសច្ចានុមតិ ក្រោយពីពេលដែលស្ថានភាព ដែលជាមូលហេតុនៃការលុបចោលត្រូវរលត់[25]។ ក្នុងករណីនេះ គឺសំដៅទៅលើពេលដែល អនីតិជនបានទទួលនូវស្ថានភាពដែលសិទ្ធិលុបចោលរបស់ខ្លួនត្រូវរលត់ ដោយហេតុទទួលបានអគ្គាធីនភាព ឬ ដល់នីតិភាព។ ដូចនេះ ក្រោយពី ទទួលបានអគ្គាធីនភាព ឬ បានដល់នីតិភាពហើយនោះ ជននោះអាចធ្វើសច្ចានុមតិនឹងធ្វើឱ្យកិច្ចសន្យាដែលបានបង្កើតឡើងនូវពេលខ្លួននៅជាអនីតិជន មានសុពលភាពពេញលេញ។

២. ការធ្វើសច្ចានុមតិតាមមធ្យោបាយម្យ៉ាងទៀត គឺជាការធ្វើសច្ចានុមតិ ដោយអ្នកតំណាងដែលច្បាប់បានកំណត់។ អ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជននេះ គឺសំដៅលើអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន។ អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចធ្វើសច្ចានុមតិទៅលើសកម្មភាពរបស់អនីតិជន ដែលស្ថិតនៅក្រោមការមើលថៃរបស់ខ្លួនបាន។

៣. មធ្យោបាយម្យ៉ាងទៀតនៃការផ្ដល់សច្ចានុមតិទៅលើសកម្មភាពរបស់អនីតិជន គឺតាមការអនុញ្ញាតយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់។ អនីតិជនផ្ទាល់អាចនឹងធ្វើសច្ចានុមតិទៅលើសកម្មភាពរបស់ខ្លួនផ្ទាល់បាន បើសិនជាខ្លួនបានទទួលការយល់ព្រមពីសំណាក់ អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន។

### ២.៣.២ ការរំលាយកិច្ចសន្យាការងាររបស់អនីតិជន

ចំពោះកិច្ចសន្យាការងារវិញ លក្ខខណ្ឌនៅក្នុងការបង្កើត និងរំលាយ មានភាពខុសគ្នាទៅបង្កើត និងលុបចោល កិច្ចសន្យា ឬ សកម្មភាពធម្មតារបស់អនីតិជន។ ដូចបានពន្យល់នៅក្នុងចំណុច ២.១.៣ (**សិទ្ធិក្នុងកិច្ចសន្យាការងារ**) ហើយថា កិច្ចសន្យាការងាររបស់អនីតិជន អាចកើតឡើង បានដោយអនីតិជនផ្ទាល់តែប៉ុណ្ណោះដោយមានការយល់ព្រមពីសំណាក់អ្នកមានអំណាចមេបា និងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយហេតុតែកិច្ចសន្យាការងារ គឺជាគោលការណ៍ដាក់បន្ទុកទៅដល់អនីតិជន ដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចនឹងកេងប្រវ័ញ្ចបាន។ រីឯ ការរំលាយកិច្ចសន្យាការងាររបស់អនីតិជន បុគ្គលដែលអាចធ្វើការរំលាយកិច្ចសន្យា

[25] មាត្រា ៣៦១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

នេះបាន គឺមាន អ្នកអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ស្ថាប័នរដ្ឋបាល។[26] ការធ្វើបែបនេះ គឺក្នុងគោលបំណងការពារទៅលើប្រយោជន៍របស់អនីតិជន ពីព្រោះ នៅពេលដែលកិច្ចសន្យាការងាររបស់អនីតិជនបានកើតឡើងពេញលេញហើយ (ដោយមានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់) តែដោយហេតុមានការផ្លាស់ប្តូរបរិស្ថានការងារ ឬ ស្ថានភាពសេដ្ឋកិច្ចណាមួយ អាចនឹងធ្វើឱ្យអនីតិជនខូចផលប្រយោជន៍ ។ ក្នុងនាមជាអ្នកមានកាតព្វកិច្ច មើលថែបីបាច់រក្សា និងអប់រំអនីតិជន ដូចនេះត្រូវតែមានសិទ្ធិទៅដល់ការរំលាយកិច្ចសន្យា ដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន គិតថាធ្វើឱ្យខូចប្រយោជន៍អនីតិជន។

នៅក្នុងនោះ អ្នកមានសិទ្ធិរំលាយកិច្ចសន្យាការងារ ក៏មានស្ថាប័នរដ្ឋបាលដែរ។ ការបញ្ចូលស្ថាប័នរដ្ឋបាលឱ្យមានសិទ្ធិក្នុងការរំលាយកិច្ចសន្យាការងារនេះ ដោយសារពេលខ្លះមានលក្ខខណ្ឌចាំបាច់ ដែលស្ថាប័នរដ្ឋបាល គួរមានសិទ្ធិក្នុងការរំលាយកិច្ចសន្យា ដើម្បីការពារនូវការកេងប្រវ័ញ្ចពលកម្មកុមារ ឬ ក្នុងករណីដែលអនីតិជនពុំមានអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ជាអាទិ៍។ ចំពោះព្រះរាជាណាចក្រកម្ពុជា ស្ថាប័នរដ្ឋបាលនេះ គឺស្ថិតនៅក្រោមគោលនយោបាយរបស់រាជរដ្ឋាភិបាលផ្ទាល់ ដែលពុំមានចែងនៅក្នុងក្រមរដ្ឋប្បវេណីឡើយ។

### ២.៣.៣ ការការពារភាគីម្ខាងទៀតនៃអនីតិជន

ដោយសារតែ ភាគីម្ខាងទៀត ដែលបានធ្វើសកម្មភាពជាមួយនឹងអនីតិជន អាចនឹងទទួលនូវការខូចប្រយោជន៍ និងធ្វើឱ្យប៉ះពាល់ទៅលើប្រតិបត្តិការ និងសុវត្ថិភាពនៃការជួញដូរទូទៅរបស់ខ្លួន ដោយហេតុដូចអ្វីដែលបានបកស្រាយចំពោះការលុបចោលនូវសកម្មភាពរបស់អនីតិជននោះ។ យើងអាចយកអាជីវកម្មលក់ដូរម៉ូតូមកធ្វើជាឧទាហរណ៍បាន។ បើអាជីវករលក់ដូរម៉ូតូ ត្រូវបានលុបចោលកិច្ចសន្យាទិញលក់រហូតនោះ ការធ្វើអាជីវកម្មរបស់បុគ្គលនោះ ពិតជាគ្មានន័យឡើយ។ ដូចនេះ ដើម្បីឱ្យមានតុល្យភាពក្នុងសង្គម និងជំនួញនោះ ក្រមរដ្ឋប្បវេណីបានបញ្ញត្តនូវការការពារភាគីម្ខាងទៀតនៃជនដែលត្រូវកម្រិតសមត្ថភាព ក្នុងករណីនេះផ្ទាល់ គឺផ្តោតទៅលើតែអនីតិជនតែប៉ុណ្ណោះ (ជនដែលត្រូវបានកម្រិតសមត្ថភាពមានដូចជា អនីតិជន ជននៅក្រោមហិតូបត្ថម្ភ និងជននៅក្រោមអាណាព្យាបាលទូទៅ)[27]។ ការការពារភាគីម្ខាងទៀតនៃអនីតិជនមានពីរមធ្យោបាយ គឺសិទ្ធិដាស់តឿន (ចំណុច**ក**) និងការការពារការឆបោកពីអនីតិជន (ចំណុច**ខ**)[28]។

#### ក. សិទ្ធិដាស់តឿន

សិទ្ធិដាស់តឿន គឺសំដៅដល់សិទ្ធិរបស់ភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព

[26] មាត្រា ២៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[27] មាត្រា ១៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[28] មេត្រា ៣២ និងមាត្រា ៣៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ដោយអនុញ្ញាតឱ្យភាគីនោះ អាចធ្វើការដាស់តឿនចំពោះជនដែលត្រូវបានកម្រិតសមត្ថភាព និងអ្នកថែរក្សាជននោះឱ្យធ្វើការឆ្លើយតបថាផ្តល់សច្ចានុមតិ ឬ មិនផ្តល់សច្ចានុមតិនូវសកម្មភាព ដែលអាចលុបចោលបានក្នុងអំឡុងពេលកំណត់មួយ[29]។ អនីតិជន ដែលជាជនមួយក្នុងចំណោមជនដែលត្រូវបានកម្រិតសមត្ថភាព អាចត្រូវភាគីម្ខាងទៀតអនុវត្តសិទ្ធិដាស់តឿន ចំពោះខ្លួនបាន ឬ អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន។ ការដាស់តឿន នឹងត្រូវធ្វើឱ្យសិទ្ធិលុបចោលអស់សុពលភាព បើសិនជាអ្នកមានសិទ្ធិលុបចោលចំពោះសកម្មភាពអនីតិជន មិនបានឆ្លើយតប ក្នុងអំឡុងពេលដែលបានកំណត់ទេ ដោយគេចាត់ទុកថាអ្នកមានសិទ្ធិលុបចោលបានធ្វើសច្ចានុមតិទៅលើសកម្មភាពរបស់អនីតិជន។

ចំពោះករណីដែលភាគីម្ខាងទៀតអាចដាស់តឿនអនីតិជនបាន គឺនៅពេលដែលអនីតិជននោះបានក្លាយជាសមត្ថជនវិញ (តាមរយៈអត្តាធីនភាព ឬ ដល់អាយុទទួលនីតិភាព)។ មាត្រា ៣២ បានកំណត់ថាការដាស់តឿនត្រូវបានកំណត់អំឡុងពេលលើស ១ (មួយ) ខែ។ ដូចនេះ ភាគីម្ខាងទៀត អាចកំណត់រយៈពេលឱ្យអនីតិជនដែលក្លាយជាសមត្ថជន ឆ្លើយតបចំពោះសកម្មភាពរបស់ជននោះ យ៉ាងតិចមួយខែ ដែលការកំណត់ពេលយ៉ាងតិចមួយខែនេះ គឺដើម្បីផ្តល់ពេលវេលាសមរម្យដល់អនីតិជនដែលក្លាយជាសមត្ថជន ឱ្យពិចារណាថា យល់ព្រម ឬ មិនយល់ព្រមផ្តល់សច្ចានុមតិទៅដល់សកម្មភាពរបស់ខ្លួន។ បើមិនមានការឆ្លើយតបក្នុងអំឡុងពេលដែលបានកំណត់ទេ នោះសកម្មភាពនោះនឹងត្រូវបានចាត់ទុកថាបានផ្តល់សច្ចានុមតិ។

**ឧទាហរណ៍** ឡុង បានទិញខ្សែកពេជ្រពី ប៊ុនលី ក្នុងតម្លៃ ១០០០០ (មួយម៉ឺន) ដុល្លារ ហើយ ប៊ុនលី មានអាយុ ១៧ ឆ្នាំ។ ក្រោយពីធ្វើការជួញដូររួច ទើប ឡុង ដឹងថា ប៊ុនលី ជាអនីតិជន។ តែ ប៊ុនលី កំពុងតែត្រៀមខ្លួនរៀបអាពាហ៍ពិពាហ៍។ ដូចនេះក្រោយពេល ប៊ុនលី រៀបអាពាហ៍ពិពាហ៍ស្របច្បាប់ហើយ ឡុង មានសិទ្ធិផ្តល់ដំណឹងទៅ ប៊ុនលី ដើម្បីឱ្យធ្វើសច្ចានុមតិ យល់ព្រមទទួលស្គាល់សកម្មភាពរបស់ខ្លួន នៅពេលដែលខ្លួនកំពុងស្ថិតនៅក្នុងអនីតិភាព ដោយកំណត់ថា ឡុង នឹងរង់ចាំចម្លើយពី ប៊ុនលី រយៈពេល ៤០ថ្ងៃ។ ៤០ថ្ងៃក្រោយមក ប៊ុនលី នៅតែពុំបានឆ្លើយតបមក ឡុង ទេ។ ដូចនេះ កិច្ចសន្យាទិញលក់នេះ ត្រូវបានចាត់ទុកថាបានផ្តល់សច្ចានុមតិ ហើយ ប៊ុនលី ពុំមានសិទ្ធិមកអះអាងសុំលុបចោលកិច្ចសន្យា ក្រោយពី ៤០ថ្ងៃនោះឡើយ។

ប៉ុន្តែបើ អនីតិជននោះពុំទាន់បានក្លាយជាសមត្ថជននោះទេ ភាគីម្ខាងទៀតអាចធ្វើការដាស់តឿន ទៅអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយកំណត់អំឡុង

[29] មេរៀន ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ ក្រុមការងារ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទំព័រ ១៧

ពេលលើសពី ១ (មួយ) ខែ។ ការអនុវត្តបញ្ញត្តិនេះ គឺដូចគ្នានឹងទៅការបកស្រាយខាងលើ ដោយហេតុថា ប្រសិន បើអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនបានឆ្លើយតបថា យល់ព្រម ឬ មិនយល់ព្រមផ្តល់សច្ចានុមតិទេក្នុងអំឡុងពេលដែលបានកំណត់យ៉ាងតិចមួយខែ នោះត្រូវចាត់ទុកថាអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន បានផ្តល់សច្ចានុមតិទៅលើសកម្មភាពរបស់អនីតិជនដែលស្ថិតនៅក្រោមការមើលថែរបស់ខ្លួន។

**ខ. ការការពារការឆបោកពីអនីតិជន**

នៅពេលដែលបុគ្គលទទួលបានសិទ្ធិអ្វីមួយជារឿយៗ មានមនុស្សមួយចំនួនតែងតែ ប្រើសិទ្ធិនោះធ្វើឱ្យខូចប្រយោជន៍ដល់អ្នកដទៃ។ ដូចគ្នាដែរ ចំពោះសិទ្ធិលុបចោលសកម្មភាពរបស់អនីតិជនក៏ត្រូវបានជនមួយចំនួនយកមកប្រើប្រាស់ ដើម្បីកេងប្រវ័ញ្ចដោយទុច្ចរិតទៅលើភាគីម្ខាងទៀត ដែលធ្វើសកម្មភាពជាមួយនឹងអនីតិជន តាមរយៈការឆបោក។ ការឆបោកនេះ គឺកើតឡើងដោយការធ្វើឱ្យភាគីម្ខាងទៀតយល់ច្រឡំថា ភាគីម្ខាងនោះកំពុងធ្វើសកម្មភាពជាមួយនីតិជន ដោយអនីតិជននោះ បានប្រើប្រាស់ពាក្យសម្តីផ្តល់ពត៌មានមិនពិតថាខ្លួនជានីតិជន ឬ ការកុហកថាខ្លួនបានទទួលការយល់ព្រមពីជនដែលមានសិទ្ធិផ្តល់ការយល់ព្រមពីជនដែលមានសិទ្ធិផ្តល់ការយល់ព្រម ហើយបានបង្ហាញលិខិតយល់ព្រមក្លែងក្លាយដល់ភាគីម្ខាងទៀត[30]។ ដោយហេតុនេះ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តការពារភាគីម្ខាងទៀតពីការឆបោកបែបនេះ ដោយមិនអនុញ្ញាតឱ្យលុបចោលសកម្មភាពដែលកើតឡើងពីការឆបោកពីអនីតិជនឡើយ[31]។

ប៉ុន្តែការចាត់ទុកថាសកម្មភាពណាមួយជាការឆបោក អាចនឹងមានភាពមិនច្បាស់លាស់។ ដូចជាការនៅស្ងៀមស្ងាត់មិនប្រាប់ពីអាយុ មិនត្រូវបានចាត់ទុកជាការឆបោកទេ។ ដូចនេះ ដើម្បីបញ្ជាក់ថាសកម្មភាពណាមួយជាការឆបោកនោះ ត្រូវតែគោរពតាមនូវលក្ខខណ្ឌ៤ គឺ មធ្យោបាយឆបោក (១) មធ្យោបាយឆបោកត្រូវប្រើដោយទាក់ទងនឹង "សមត្ថភាពក្នុងការធ្វើសកម្មភាព" (២) ជនដែលត្រូវបានកម្រិតសមត្ថភាព បានប្រើមធ្យោបាយនោះ ដោយ "ចេតនា" (៣) និងភាគីម្ខាងទៀត ត្រូវបានធ្វើឱ្យជឿជាក់ថា ជនត្រូវបានកម្រិតសមត្ថភាព គឺជាជនដែលមានសមត្ថភាពពេញលេញ (៤)[32]។

(១) មធ្យោបាយឆបោក គឺជាវិធីបោកបញ្ឆោតដើម្បីឱ្យភាគីម្ខាងទៀតជឿថា ជនដែលត្រូវបានកម្រិតសមត្ថភាពនោះ មានសមត្ថភាពក្នុងការធ្វើសកម្មភាព ចំពោះករណីសិក្សាពីសិទ្ធិអនីតិជននេះ គឺសំដៅសកម្មភាពណាដែលធ្វើឱ្យអនីតិជន ត្រូវបានចាត់ទុកជានីតិជន។ មធ្យោបាយឆបោក

---

30 សេចក្តីកំណត់មេត្រា ៣៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

31 មាត្រា ៣៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

32 សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ ១ ទំព័រ ២៦

អាចមាន ដូចជា ការភូតកុហកពីអាយុ ឬ ការប្រើឯកសារក្លែងក្លាយដែលបង្ហាញពីការយល់ព្រមរបស់អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន។

(២) មធ្យោបាយឆបោកត្រូវប្រើដោយទាក់ទងនឹង "សមត្ថភាពក្នុងការធ្វើសកម្មភាព" នេះ សំដៅទៅលើលក្ខណៈនៃការឆបោក ដោយប្រើប្រាស់នូវវិធីណាមួយ ដែលធ្វើឱ្យភាគីម្ខាងគិតថា អនីតិជននោះពិតជាមានសមត្ថភាពក្នុងការធ្វើសកម្មភាព។

**ឧទាហរណ៍** អនីតិជននិយាយថាខ្លួនមានអាយុ ១៩ ឆ្នាំ និងបានប្រើប្រាស់នូវអត្តសញ្ញាណប័ណ្ណក្លែងក្លាយដើម្បីបញ្ជាក់ពីអាយុនោះ ដែលជាលក្ខខណ្ឌទាក់ទងនឹងសមត្ថភាពនៅក្នុងការធ្វើសកម្មភាពរបស់អនីតិជន ទើបត្រូវបានចាត់ទុកជាការឆបោក។ តែបើថា ជននោះបានបង្ហាញថា ខ្លួនមានលុយគ្រប់គ្រាន់ ដោយបង្ហាញពីសៀវភៅគណនីរបស់ឪពុកគាត់ នោះសកម្មភាពនេះមិនមែនជាមធ្យោបាយឆបោក ដែលទាក់ទងនឹងសមត្ថភាពក្នុងការធ្វើសកម្មភាពទេ។

(៣) ជនដែលត្រូវបានកម្រិតសមត្ថភាព បានប្រើមធ្យោបាយនោះដោយ "ចេតនា" ។ មានន័យថា ក្រោយពីបានធ្វើសកម្មភាព ក្នុងការធ្វើឱ្យភាគីម្ខាងទៀតគិតទុកថាអនីតិជន ជាសមត្ថជន គឺជាឆន្ទៈរបស់អនីតិជន ដោយអនីតិជនដឹងថាខ្លួនធ្វើការបោកប្រាស់បន្លំអាយុខ្លួន។

(៤) ភាគីម្ខាងទៀត ត្រូវបានធ្វើឱ្យជឿជាក់ថា ជនត្រូវបានកម្រិតសមត្ថភាព គឺជាជនដែលមានសមត្ថភាពពេញលេញ។ ចំពោះលក្ខខណ្ឌនេះ ជាលក្ខខណ្ឌទំនាក់ទំនងហេតុ និងផល ដែលថាក្រោយពីមានមធ្យោបាយឆបោក ដោយមានឆន្ទៈឱ្យយល់ថាជននោះជាសមត្ថជន តែទាល់តែភាគីម្ខាងទៀតបានជឿជាក់ថានឹងត្រូវបានគេឆបោកបានសម្រេច។ មានន័យថា បើភាគីម្ខាងទៀតមិនជឿទេ ឬ ក៏បានដឹងថាជននោះមិនមែនជាសមត្ថជនទេ នោះសកម្មភាពនោះ មិនត្រូវបានចាត់ទុកជាការឆបោកទេ ដូចនេះ សិទ្ធិលុបចោលសកម្មភាពអនីតិជននៅតែមាន។

# ជំពូកទី ៣
# សិទ្ធិអនីតិជននៅក្នុងអំពើអនីត្យានុកូល

## ៣.១ ករណីអំពើអនីត្យានុកូលបង្កឡើងដោយអនីតិជន

អំពើអនីត្យានុកូល គឺជាអំពើដែលបំពានដោយខុសច្បាប់ទៅលើសិទ្ធិ ឬ ផលប្រយោជន៍អ្នកដទៃដោយកំហុសចេតនា ឬ កំហុសអចេតនា។ ដូចនេះ បុគ្គលដែលត្រូវបានបំពាននូវសិទ្ធិ និងផលប្រយោជន៍ មានសិទ្ធិទាមទារនូវសំណងនៃការខូចខាតនេះពីបុគ្គលដែលបានបង្កការខូចខាតនេះ។

លក្ខខណ្ឌនៃការទទួលខុសត្រូវលើអំពើអនីត្យានុកូល គឺជាលក្ខខណ្ឌ ឬ ធាតុផ្សំដែលត្រូវតែបំពេញឱ្យគ្រប់ចំនួនកំណត់ ដើម្បីអាចធ្វើការទាមទារ ការទទួលខុសត្រូវលើកំហុសចេតនា ឬ កំហុសអចេតនាដែលបានបង្កឡើងដោយចារី។ បើយោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៧៤៣ យើងនឹងឃើញធាតុនីត្យានុកូលនៃអំពើអនីត្យានុកូល មានដូចជា៖

ក. ភាពផ្ទុយច្បាប់

ខ. កំហុស គឺវាអាចជាកំហុសចេតនា ឬកំហុសអចេតនា

គ. សមត្ថភាពទទួលខុសត្រូវ

ឃ. ការខូចខាត ឬព្យសនកម្ម

ង. ទំនាក់ទំនងហេតុ និងផល ។

**ក. ភាពផ្ទុយច្បាប់**[33]

បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬ ផលប្រយោជន៍របស់ជនដទៃ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ត្រូវទទួលខុសត្រូវ ក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ ។ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការខូចខាតបានកើតឡើងដោយសារមានករណីយកិច្ច ធ្វើអំពើណាមួយ តែមិនបានធ្វើអំពើនោះ។ អំពើខុសច្បាប់ ឬ អំពើដែលបំពានដោយខុសច្បាប់ គឺចង់សំដៅទៅលើការធ្វើសកម្មភាព ឬ ការអនុវត្តនូវសិទ្ធិរបស់បុគ្គល ដែលហួសពីព្រំដែនកំណត់របស់ច្បាប់ មានន័យថាអ្នកប្រព្រឹត្តបានអនុវត្តសិទ្ធិ ឬ កាតព្វកិច្ចរបស់ខ្លួន ហួសពីអ្វីដែលមានចែងក្នុងច្បាប់ ហើយធ្វើឱ្យប៉ះពាល់ ឬ បង្កឱ្យមានព្យសនកម្មដល់ជនរងគ្រោះ។

**ខ. កំហុស**[34]

ដើម្បីកំណត់អំពីការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល គឺ ទាមទារឱ្យមានកំហុសនៅពេលមានព្យសនកម្មកើតមានឡើង ហើយកំហុសគឺជាស្ថានភាពផ្លូវចិត្តរបស់បុគ្គលម្នាក់ៗ ដោយ

---

[33] សាស្ត្រាចារ្យ ខាំ សុមករា <អំពើអនីត្យានុកូល> (ថ្ងៃសុក្រ ទី៥ ខែកក្កដា ឆ្នាំ២០១៣)

[34] អ៊ីវ ប៉ូលី, <នីតិរដ្ឋប្បវេណី> (មេរៀនសង្ខេបសម្រាប់សមាជិកគណៈមេធាវី, គណៈមេធាវី, ២១ ធ្នូ ២០១១), ៣១

ខ្លួនអាចយល់ដឹងអំពីអំពើនោះ និងលទ្ធផលដែលកើតចេញពីអំពើរបស់ខ្លួន។ ក្នុងនោះកំហុសមានពីរប្រភេទ គឺកំហុសចេតនា និងកំហុសអចេតនា ដោយកំហុសចេតនា គឺជាការប្រព្រឹត្តអំពើណាមួយដោយបុគ្គលនោះអាចយល់ដឹង ឬ ព្យាករណ៍ទុកជាមុនបាន អំពីលទ្ធផលនៃអំពើរបស់ខ្លួន ថានឹងអន្តរាយដល់អ្នកដទៃ ចំណែកឯ កំហុសចេតនា គឺជាការបំពានករណីយកិច្ចប្រុងប្រយ័ត្ន មិនយកចិត្តទុកដាក់ចំពោះកាតព្វកិច្ចដែលច្បាប់កំណត់។

ជាគោលការណ៍ជនដែលបំពានលើសិទ្ធិ ឬ ផលប្រយោជន៍របស់អ្នកដទៃ ទោះបីជាសំភារៈ ឬ ស្មារតី បុគ្គលនោះត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាត ដោយសារកំហុសរបស់ខ្លួន ប៉ុន្តែមានករណីខ្លះ គឺជាអញ្ញត្រកម្មដោយមិនចំណុះឱ្យកំហុសនោះទេ ដូចជាអំពើអនីត្យានុកូលដែលកើតពីគ្រោះថ្នាក់ចរាចរណ៍ បរិស្ថាន ឬ ផលិតកម្ម ជាអាទ៍។កាតព្វកិច្ចបញ្ជាក់អំពីកំហុសជាបន្ទុករបស់ដើមចោទ នៅក្នុងករណីដែលកំហុសអាចមើលឃើញច្បាស់នៅក្នុងហេតុការណ៍នោះ (ជនរងគ្រោះ) ប៉ុន្តែនៅក្នុងរណីខ្លះ កាតព្វកិច្ចក្នុងការបញ្ជាក់កំហុសនេះ ត្រូវធ្លាក់លើចារីវិញ ដោយហេតុថា ជនរងគ្រោះ ពុំមានកាតព្វកិច្ចក្នុងការបញ្ជាក់នោះឡើយ។

**គ. ទទួលខុសត្រូវតាមសមត្ថភាព**[35]

សមត្ថភាពទទួលខុសត្រូវ គឺជាលក្ខខណ្ឌមួយទៀត ក្នុងការឱ្យបុគ្គលណាម្នាក់ទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ហើយបុគ្គលដែលច្បាប់ទទួលស្គាល់ថាមានសមត្ថភាពទទួលខុសត្រូវ គឺជាបុគ្គលដែលមានសមត្ថភាពយល់ដឹង និងមានសេរីភាពក្នុងការប្រព្រឹត្តអំពើនោះ ដោយហេតុថាជនដែលមានអាយុក្រោម១៤ (ដប់បួន) ឆ្នាំ ជនជនដែលមានស្ថានភាព មិនអាចយល់ដឹងបាន និងវិនិច្ឆ័យចំពោះអំពើរបស់ខ្លួន ដោយសារវិបត្តិស្មារតី ឬ មូលហេតុផ្សេងៗទៀត មិនទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលនោះឡើយ។

**ឃ. ការខូចខាត**[36]

ព្យសនកម្មគឺ ការខូចខាតដែលបង្កឡើងដោយអំពើរបស់បុគ្គលណាមួយ ឬ ដោយវត្ថុ សត្វចិញ្ចឹមហើយព្យសនកម្មនោះកើតឡើងលើទ្រព្យសម្បត្តិ រូបរាងកាយ និងផ្លូវចិត្ត។ ព្យសនកម្មត្រូវតែកើតឡើងដូចខាងក្រោមនេះ។

ព្យសនកម្មត្រូវតែកើតឡើងផ្ទាល់ ជាគោលការណ៍ ព្យសនកម្មត្រូវតែកើតឡើង ដោយផ្ទាល់ទៅលើជនរងគ្រោះ ហើយត្រូវកើតឡើងនៅក្នុងពេលបច្ចុប្បន្នទៀតផង ។ ក្នុងន័យនេះ ព្យសកម្មមិនអាចកើតទៅលើក្រុមគ្រួសារ ឬ សាច់ញាតិរបស់ជនរងគ្រោះបានឡើយ ។

[35] មាត្រា៧៤៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[36] សាស្ត្រាចារ្យ ខាំ សុមករា, <អំពើអនីត្យានុកូល>, (ថ្ងៃសុក្រ ទី៥ ខែកក្កដា ឆ្នាំ២០១៣)

- ស្ថិតនៅក្នុងពេលបច្ចុប្បន្ន នៅពេលដែលមានអំពើបង្ក ហើយបណ្តាលអោយមានការខូចខាតកើតឡើង ការខូចខាតនេះត្រូវតែមាននៅពេលដែលអំពើនេះបានកើតឡើងភ្លាមៗពោលគឺនៅពេលបច្ចុប្បន្ន។ តែក៏មានព្យសនកម្មមួយចំនួន អាចកើតឡើងនៅពេលអនាគតផងដែរ ហើយដែលព្យសនកម្មនេះ វាជាបច្ច័យចេញពីអំពើនោះដោយផ្ទាល់ ហើយព្យសនកម្មប្រភេទនេះត្រូវ បានច្បាប់ទទួលស្គាល់ផងដែរថាជាព្យសនកម្ម ហើយក្នុងករណីនេះបន្ទុកក្នុងការបង្ហាញភស្តុតាងវាត្រូវធ្លាក់ទៅលើជនរងគ្រោះ។

**ង. ទំនាក់ទំនងហេតុ និងផល**[37]

ទំនាក់ទំនង និងហេតុផលនៃការកើតឡើងនូវការខូចខាតចំពោះជនរងគ្រោះ និងចេតនា ឬកំហុសរបស់ចារី។ ក្នុងន័យនេះមានន័យថា ព្យសនកម្ម ត្រូវកើតឡើងដោយមានភាពស៊ីសង្វាក់គ្នារវាងហេតុ និងចេតនា ឬ កំហុស ដូចជា បើការខូចខាតដោយអំពើរបស់វត្ថុត្រូវកើតឡើងបណ្តាលមកពីវត្ថុ ពុំមែនបង្កឡើងដោយមនុស្សទេនោះ ពុំអាចចាប់បង្ខំបុគ្គលនោះ ឱ្យទទួលខុសត្រូវនូវព្យសនកម្មដែលពុំមានទំនាក់ទំនងរវាងហេតុ និងបច្ច័យនោះបានឡើយ។

- ព្យសនកម្មត្រូវកើតឡើងដោយផ្ទាល់ពីកំហុស៖ បើគ្មានអំពើបង្កឡើងឱ្យមានការខូចខាតកើតឡើងទេ ក៏កំហុសពុំកើតមានដែរ ដូចនេះចាត់ទុកថាជាកំហុសបាន ត្រូវមានច្បាប់ចែងទុកជាមុនច្បាស់លាស់ទើបអាចចាប់បង្ខំបុគ្គលណាមួយ ទទួលខុសត្រូវនូវកំហុសនោះបាន។
- ព្យសនកម្មត្រូវកើតឡើងដោយផ្ទាល់៖ ការខូចខាតត្រូវតែស៊ីសង្វាក់គ្នាជាមួយនឹងអំពើប្រព្រឹត្តផ្ទាល់ ក្នុងករណីពុំអាចរកឃើញអំពើផ្ទាល់ទេ គឺគ្មានភស្តុតាងក្នុងការដាក់បន្ទុកដើម្បីចាប់បង្ខំឱ្យមានការទទួលខុសត្រូវឡើយ។

ហើយនៅពេលដែលមានមូលដ្ឋានសំអាងពិសេស ដោយផ្អែកទៅលើចរិកលក្ខណៈ និងផលប្រយោជន៍ដែលទទួលរងនូវអំពើបំពាន រួមទាំងផលប្រយោជន៍ដែលត្រូវបានការពារ នាំឱ្យបុគ្គលដែលធ្វើសកម្មភាពអាចរួចផុតពីការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលបាន បើការបំពាននោះមានលក្ខណៈខុសច្បាប់ ដូចជាកិច្ចការពារជាធម្មានរូបស្ថានភាពចាំបាច់ និងមូលហេតុផ្សេងទៀត។

- កិច្ចការពារជាធម្មានុរូប[38]៖ គឺជាអំពើរំលោភបំពាន ដែលមិនអាចជៀសវាងបានដើម្បីការពារខ្លួន ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះអំពើបំពានដោយមិនត្រឹមត្រូវ ស្ថិតនៅក្នុងករណីដែលអំពើបំពាន និងអំពើរំលោភនោះស្ថិតជិតគ្នា និងមានកម្រិតតុល្យភាពគ្នារវាង ការការពារ និងការបំពាន។ កិច្ចការពារជាធម្មានុរូប ពុំត្រូវបានចាត់ទុកថាជាអំពើបំពាន

[37] សាស្ត្រាចារ្យ ខាំ សុមករា, <អំពើអនីត្យានុកូល>, (ថ្ងៃសុក្រ ទី៥ ខែកក្កដា ឆ្នាំ២០១៣)
[38] មាត្រា៧៥៦ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ដោយខុសច្បាប់ឡើយ ដោយហេតុថា បុគ្គលដែលបានប្រព្រឹត្តអំពើនោះ ត្រូវបានច្បាប់អនុញ្ញាតដើម្បីកុំឱ្យមានព្យសនកម្មធ្ងន់ធ្ងរកើតមានឡើង។

- ស្ថានភាពចាំបាច់[39]៖ សំដៅទៅលើអំពើរំលោភបំពាន ដែលមិនអាចជៀសវាងបាន ហើយដើម្បីការពារខ្លួន ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ដែលស្ថិតនៅក្នុងករណីដែលមានតុល្យភាពរវាងវិធីការពារ និងកម្រិតគ្រោះថ្នាក់នោះ។
- មូលហេតុផ្សេងទៀត៖ អំពើដែលបង្កឱ្យមានការអន្តរាយក្នុងករណី ដែលមានការយល់ព្រមពីសំណាក់ជនរងគ្រោះ[40] លើកលែងតែ ការយល់ព្រមរបស់ជនរងគ្រោះនោះ មិនត្រូវបាន សង្គមទទួលស្គាល់។ អំពើរបស់មន្ត្រីរាជការ ដែលទទួលនូវការអនុវត្តសិទ្ធិអំណាចសាធារណៈរបស់រដ្ឋ ដែលបង្កឱ្យមានការខូចខាតដល់អ្នកដទៃ ដោយគ្មានកំហុសក្នុងការអនុវត្តភារកិច្ច មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលឡើយ ដូចជាការអនុវត្តសាលក្រម ជាអាទិ៍។

ជាទូទៅនៅគ្រប់អំពើអនីត្យានុកូលមិនមែនសុទ្ធតែបុគ្គលដែលជាអ្នកបង្ក ឬ ចារីនោះជាអ្នកទទួលខុសត្រូវចំពោះអំពើនោះទេ ហើយអាចជាអ្នកផ្សេងទៅវិញ ដែលជាអ្នកត្រូវទទួលខុសត្រូវ។ ក្នុងករណីនេះហៅថាជាការទទួលខុសត្រូវលើអំពើអ្នកដទៃ ដែលនៅក្នុងនេះ យើងនឹងធ្វើការសិក្សាទៅលើការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលដែលបង្កឡើងដោយអនីតិជន។

នៅក្នុងគោលការណ៍នៃការទទួលខុសត្រូវចំពោះឆន្ទៈ បុគ្គលដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យដោយសារមានបញ្ហាផ្នែកបញ្ញាស្មារតី ឬ ដោយសារអាយុរបស់បុគ្គលនោះ នាំឱ្យបុគ្គលនោះមិនទទួលខុសត្រូវទៅលើអំពើដែលខ្លួនបានបង្កឡើងឡើយ។ យោងតាមមាត្រា ៧៤៥ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បុគ្គលដែលគ្មានការទទួលខុសត្រូវលើអំពើផ្ទាល់ខ្លួនគឺ អសមត្ថជន ឬជនអសមត្ថភាព។ អសមត្ថជន គឺជាជនដែលមានសមត្ថភាពពិចារណាមិនគ្រប់គ្រាន់ចំពោះអំពើ និងព្យសនកម្ម ដែលបានកើតឡើងពីអំពើរបស់ខ្លួនផ្ទាល់ ដែលក្នុងទីនេះសំដៅដល់ **អនីតិជនក្រោមអាយុ១៤ឆ្នាំ (៣.១.១)** និង**អនីតិជនចាប់ពីអាយុ១៤ឆ្នាំឡើងទៅ (៣.១.២)**។

### ៣.១.១ អនីតជនក្រោមអាយុ ១៤ឆ្នាំ

ការរស់នៅក្នុងសង្គមសម័យទំនើបនេះ កុមារកាន់តែមានការលូតលាស់ខាងផ្នែកបញ្ញាស្មារតីក្នុងការដឹងខុសដឹងត្រូវទៅលើសកម្មភាពដែលគួរធ្វើ និងមិនគួរធ្វើ។ ការលូតលាស់ខាងផ្នែកបញ្ញាស្មារតី គឺអាស្រ័យទៅតាមបុគ្គលម្នាក់ៗ ហេតុនេះហើយ សមត្ថភាពអាចត្រូវបានគេកំណត់ទៅតាម

[39] មាត្រា៧៥៦ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[40] មាត្រា៧៥៦ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ករណីនីមួយៗ។ មានន័យថា ទោះបីជាក្មេងដែលមានអាយុត្រឹមតែ១៣ឆ្នាំក៏ដោយ ក៏អាចមានប្រាជ្ញាគ្រប់គ្រាន់ ដើម្បីទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលបានដែរ ហើយជនដែលមានអាយុ២១ឆ្នាំ ក៏នៅតែអាចទទួលបានការការពារដោយច្បាប់ដែរ ដោយសារតែខ្វះសមត្ថភាព ប៉ុន្តែដើម្បីធ្វើការបញ្ជាក់អំពីលក្ខណៈនៃការវិនិច្ឆ័យឱ្យបានច្បាស់លាស់ ច្បាប់បានបញ្ញត្តនូវលក្ខណៈនៃការវិនិច្ឆ័យ ដោយកំណត់ពីអាយុក្នុងការទទួលខុសត្រូវ។ បើតាមបញ្ញត្តិមាត្រា៧៤៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានចែងថា ជនដែលមានអាយុក្រោម១៤ឆ្នាំ មិនទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលទេ។ ហេតុនេះ ជនរងគ្រោះមិនអាចធ្វើការអះអាងបានទេថា អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ ត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលនោះ ទោះបីជាអនីតិជននោះមានប្រាជ្ញាខ្ពស់យ៉ាងណាក៏ដោយ។

**ឧទាហរណ៍** គ្រួសារអ្នកមានមួយ មានកូនស្រីដ៏វៃឆ្លាតអាយុ១៣ឆ្នាំម្នាក់ ឈ្មោះ គីមស្រ៊ី។ គ្រួសារនេះបានបញ្ជូន គីមស្រ៊ី ទៅសាលារៀនមួយ ដែលមានការអប់រំខ្ពស់ ហើយមានការទទួលស្គាល់ដល់ថ្នាក់អន្តរជាតិ។ គីមស្រ៊ី គឺសិស្សដែលឆ្លាតជាងគេនៅក្នុងសាលា ថ្ងៃមួយនៅពេលដែលគ្រួសារនាងទៅលេងខេត្តសៀមរាប។ នៅពេលដែលឪពុកម្តាយនាងមិនបានប្រុងប្រយ័ត្ន គីមស្រ៊ី បានយកដុំថ្មទៅគប់ឡានទំនើបមួយគ្រឿង បណ្តាលឱ្យបែកកញ្ចក់។ តាមករណីនេះ ជនរងគ្រោះដែលជាម្ចាស់ឡាន មិនអាចធ្វើការអះអាងទៅលើភាពឆ្លាតវៃ ឬ ទៅលើការអប់រំរបស់ គីមស្រ៊ី ដើម្បីឱ្យ គីមស្រ៊ី ទទួលខុសត្រូវលើការខូចខាតនោះបានទេ។

### ៣.១.២ អនីតជនចាប់ពី ១៤ឆ្នាំ

តាមមាត្រា៧៤៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បុគ្គលដែលមានករណីកិច្ចត្រួតពិនិត្យអនីតិជនចាប់ពីអាយុ១៤ឆ្នាំឡើងទៅ ត្រូវមានការទទួលខុសត្រូវដោយសាមគ្គីភាពជាមួយអនីតិជននោះ។ មានន័យថា នៅពេលដែលអនីតិជនបានបង្កឱ្យមាននូវការបំពានណាមួយ ដែលបណ្តាលឱ្យមានការប៉ះពាល់ដល់អ្នកដទៃ ពេលនោះ អនីតិជន ត្រូវតែធ្វើការជួសជុលនូវការខូចខាត តាមរយៈសំណងសម្រាប់ជនរងគ្រោះ ប៉ុន្តែប្រសិនបើអនីតិជននោះពុំអាចធ្វើការទូទាត់នូវសំណងនោះបានទេ ពេលនោះហើយទើបការទទួលខុសត្រូវ ត្រូវធ្លាក់ទៅលើអ្នកដែលមានករណីយកិច្ចត្រួតពិនិត្យក្នុងការចេញនូវសំណងជំនួសអនីតិជននោះ ឬ ជួយបំពេញបន្ថែមទៅលើអ្វីដែលអនីតិជននោះពុំមានលទ្ធភាព។

**ឧទាហរណ៍១** បូរ៉ា មានអាយុ១៥ឆ្នាំ ដែលបច្ចុប្បន្នរស់នៅជាមួយឪពុកម្តាយ។ ថ្ងៃមួយ បូរ៉ា បានទៅលេងផ្ទះមិត្តភក្តិរបស់នាង ហើយងបានធ្វើឱ្យកញ្ចក់ទូរនៅក្នុងផ្ទះមិត្តភក្តិនោះបែក។ ក្នុងករណីនេះ ឪពុកម្តាយរបស់បូរ៉ា ត្រូវតែទទួលខុសត្រូវសងការខូចខាត ដែលបណ្តាលមកពីកំហុស

របស់ បូរ៉ា ពីព្រោះ បូរ៉ា ពុំមានលទ្ធភាពក្នុងការទទួលខុសត្រូវសងការខូចខាតដោយខ្លួនឯងផ្ទាល់បាន។

**ឧទាហរណ៍២** តាមឧទាហរណ៍ខាងលើដដែល ឥឡូវនេះ បូរ៉ា មានអាយុ១៧ឆ្នាំហើយ តែនាងនៅតែរស់នៅជាមួយឪពុកម្តាយនាងដដែល។ ដោយ បូរ៉ា ជាក្មេងពូកែខាងគិតលេខ ដូចនេះ បូរ៉ា បានចូលជាអ្នកគិតលុយនៅហាងដូរលុយមួយកន្លែង ហើយទទួលបានប្រាក់ខែ ២០០ (ពីរយ) ដុល្លារអាមេរិក ក្នុងមួយខែ។ ថ្ងៃមួយពេលដែល បូរ៉ា ជិះម៉ូតូទៅធ្វើការ នាងបានជិះទៅប៉ះនឹងឡានមួយគ្រឿង។

ក្នុងករណីនេះ បូរ៉ា ត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតដោយខ្លួនឯងផ្ទាល់ ប៉ុន្តែប្រសិនបើនាងពុំមានលទ្ធភាព ក្នុងការសងសំណងតែម្នាក់ឯងទេនោះ ឪពុកម្តាយរបស់នាងត្រូវមានករណីយកិច្ចដោយសាមគ្គីជាមួយនាង ដើម្បីទូទាត់សំណងនៃការខូចខាតនោះ។ ប៉ុន្តែបើតាមមាត្រា៧៤៦ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បុគ្គលដែលមានករណីយកិច្ចត្រួតពិនិត្យ មិនចាំបាច់ទទួលខុសត្រូវ លើសកម្មភាពនៃការបំពានរបស់អនីតិជននៅក្រោមការត្រួតពិនិត្យនោះទេ ប្រសិនបើបុគ្គលនោះបានបង្ហាញថា ការបំពានបានកើតឡើង គឺមិនមែនដោយសារតែកំហុសរបស់ខ្លួនក្នុងការត្រួតពិនិត្យនោះទេ ផ្ទុយទៅវិញ អ្នកត្រួតពិនិត្យបានបំពេញករណីយកិច្ចត្រួតពិនិត្យជាប្រក្រតី ដូចនេះ អ្នកត្រួតពិនិត្យនឹងមិនទទួលខុសត្រូវទៅលើសកម្មភាពនៃការបំពានរបស់អនីតិជននោះទេ។ ដើម្បីឱ្យអ្នកមានករណីយកិច្ចត្រួតពិនិត្យអនីតិជនចាប់ពីអាយុ១៨ឆ្នាំ អាចរួចផុតពីការទទួលខុសត្រូវលើអំពើបំពានរបស់អនីតិជននោះ កាលណាបំពេញលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- អ្នកមានករណីយកិច្ចត្រួតពិនិត្យមិនបានប្រព្រឹត្តកំហុសខាងថែទាំ ឃ្លាំមើល ឬអប់រំទេ។
- អ្នកមានករណីយកិច្ចត្រួតពិនិត្យមិនបានរស់នៅជាមួយអនីតិជននោះ។
- អ្នកមានករណីយកិច្ចត្រួតពិនិត្យបង្ហាញថា បានបំពេញករណីយកិច្ចត្រួតពិនិត្យជាប្រក្រតី។

## ៣.២ ករណីអនីតិជនជាជនរងគ្រោះនៃអំពោះអនីត្យានុកូល

រាល់ការខូចខាតដែលកើតឡើងដោយសារអំពើបំពានដោយខុសច្បាប់នូវសិទ្ធិ និងផលប្រយោជន៍ ត្រូវជាបន្ទុករបស់អ្នកប្រព្រឹត្តអំពើអនីត្យានុកូល ដែលជាគោលការណ៍សំណងនៃការខូចខាត ត្រូវសងជាប្រាក់[41] ដើម្បីឱ្យមានភាពងាយស្រួល ក្នុងការកំណត់អំពីរបៀបសង។ ប៉ុន្តែ នៅក្នុងស្ថានភាពខ្លះ ការសងជា ប្រាក់តែមួយមុខគត់ មិនអាចធ្វើឱ្យជនរងគ្រោះទទួលយកបាននោះទេ គឺ

[41] មាត្រា៧៥៧ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

តម្រូវឱ្យធ្វើបដិទាន ឬ ហាមឃាត់មិនឱ្យធ្វើសកម្មភាពណាមួយ[42] ដើម្បីស្តារកិត្តិយសដែលត្រូវបានខូចខាតនោះ ហើយចំពោះការបរិហាកេរ្តិ៍ ក្រៅពីសំណងនៃការខូចខាត ជនរងគ្រោះអាចទាមទារវិធានការស្តារកិត្តិយសឡើងវិញ តាមរយៈការផ្សាយសេចក្តីសុំអភ័យទោសជាសាធារណៈ ជាអាទិ៍[43]។ មួយវិញទៀត កម្មវត្ថុនៃការខូចខាត អាចជាទ្រព្យសម្បត្តិ ឬ សតិអារម្មណ៍ ហេតុនេះ អាចមានសំណងនៃការខូចខាតសំភារៈ និងសំណងនៃការខូចខាតផ្លូវចិត្តផងដែរ[44]។

ប៉ុន្តែនៅក្នុងករណីដែលអំពើអនីត្យានុកូលបានកើតចំពោះអនីតិជន ដែលជាជនត្រូវបានកម្រិតនូវសមត្ថភាពនោះ ការទាមទារពុំអាចធ្វើបានឡើយតាមផ្លូវតុលាការ ដោយហេតុការកម្រិតសកម្មភាពចាំបាច់ទាមទារឱ្យមាននូវអ្នកតំណាងសម្រាប់អនីតិជននោះ ក្នុងការធ្វើជាអ្នកតំណាងតាមផ្លូវបណ្តឹង ដើម្បីការពារសិទ្ធិឱ្យអនីតិជននោះ ចៀសវាងការបាត់ផលប្រយោជន៍ណាមួយដោយពុំសមហេតុផល។

### ៣.២.១ អ្នកតំណាងសម្រាប់អនីតិជន

ក្នុងចំណោមជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព[45] អនីតិជន ជាគោលការណ៍ ពុំមានសមត្ថភាពក្នុងការធ្វើបណ្តឹងទេ ហើយអាចធ្វើសកម្មភាពបណ្តឹងសុពលបាន លុះត្រាតែ ត្រូវបានធ្វើតាមអ្នកតំណាងដែលច្បាប់បានកំណត់[46]។ សកម្មភាពបណ្តឹងដែលអនីតិជនបានធ្វើ មិនត្រឹមតែអាចលុបចោលទេ គឺសកម្មភាពនោះមោឃៈជាដាច់ខាត[47]។ ទោះជាមានការយល់ព្រមពីជនដែលមានសិទ្ធិអំណាចមេបា ឬ ពីអ្នកអាណាព្យាបាលក៏ដោយ ក៏មោឃៈដែរ។ ដូចនេះហើយ ដើម្បីអាចធ្វើការទាមទារសំណងពីអំពើអនីត្យានុកូលបាន លុះត្រាតែមានអ្នកតំណាង (ចំណុច**ក**) និងការជ្រើសរើសអ្នកតំណាងពីសេស (ចំណុច**ខ**) ក្នុងករណីគ្មានអ្នកតំណាងដែលច្បាប់បានកំណត់។

#### ក. ការទាមទារសំណងសម្រាប់អនីតិជនតាមរយៈការតំណាង

ក្នុងករណីដែលអនីតិជនជាជនរងគ្រោះនៃអំពើអនីត្យានុកូល អ្នកតំណាងដែលបានកំណត់តាមច្បាប់សារធាតុ ដូចជាអ្នកមានសិទ្ធិអំណាចមេបាលើអនីតិជន ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន (អ្នកតំណាងតាមច្បាប់សារធាតុ) ជាដើម ក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់ តាមផ្លូវនីតិវិធីបណ្តឹង សម្រាប់អនីតិជននោះ។ ដូចនេះ នៅក្នុងករណីដែលអនីតិជនបានទទួលរងនូវអំពើ

[42] មាត្រា៧៥៧ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
[43] មាត្រា៧៥៧ កថាខណ្ឌ៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
[44] មាត្រា៧៦១ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
[45] មាត្រា១៧នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
[46] មាត្រា៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦
[47] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ <នីតិវិធីបណ្តឹង> ក្រសួងយុត្តិធម៌ ឆ្នាំ២០០៨ ២៦ ,

អនីត្យានុកូល ឪពុកម្តាយ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ផ្សេងទៀត អាចដាក់ពាក្យបណ្តឹងដើម្បីធ្វើការទាមទារនូវសំណងការខូចខាតនានាបាន។

**ខ. ការទាមទារសំណងតាមរយៈការជ្រើសរើសអ្នកតំណាងពិសេស**

ក្នុងករណីដែលមានអំពើអនីត្យានុកូលចំពោះអនីតិជន ហើយអនីតិជននោះគ្មានអ្នកតំណាងដែលច្បាប់កំណត់តាមផ្លូវច្បាប់សារធាតុ ឬ ប្រសិនបើអ្នកតំណាងដែលច្បាប់បាន កំណត់ពុំអាចអនុវត្តសិទ្ធិតំណាងរបស់ខ្លួនបានតុលាការ អាចជ្រើសតាំងអ្នកតំណាងពិសេស ដែលការជ្រើសរើសត្រូវបានសម្រេចឡើងតាមការពិចារណារបស់តុលាការ ដើម្បីជាប្រយោជន៍សម្រាប់អនីតិជននោះដែលអាចជាមេភូមិ ចៅសង្កាត់ ឬ ជាគោលការណ៍គឺព្រះរាជអាជ្ញា ក្នុងការធ្វើជាអ្នកតំណាងក្នុងការដាក់ពាក្យបណ្តឹង[48] ដោយផ្អែកលើពាក្យសុំរបស់អនីតិជននោះ ។

**៣.២.២ អនីតជនដែលទទួលបានអត្តាធីនភាព និងការដល់នីតភាព**

ទោះបីជាអនីតិជនក៏ដោយ ក៏ក្នុងករណីដែលជននោះត្រូវបានចាត់ទុកថាបានដល់នីតិភាពដោយសារអាពាហ៍ពិពាហ៍ (ក្រមរដ្ឋប្បវេណី មាត្រា ៩៦៨) ជននោះមានសមត្ថភាពក្នុងការធ្វើបណ្តឹងជាទូទៅ។ ម្យ៉ាងទៀត ក្នុងករណីដែលអនីតិជនត្រូវបានអនុញ្ញាតឱ្យចាត់ចែងចំពោះទ្រព្យសម្បត្តិជាក់លាក់ពិសេស ឬ ត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម ហើយមានសមត្ថភាពក្នុងការធ្វើសកម្មភាពត្រឹមទំហំនោះ (ក្រមរដ្ឋប្បវេណី មាត្រា ១៩ និងមាត្រា ២០) ជនមានសមត្ថភាពក្នុងការធ្វើបណ្តឹង ចំពោះបណ្តឹងដែលទាក់ទងនឹងទ្រព្យសម្បត្តិនោះ ឬ អាជីវកម្មនោះ។ ដូចនេះហើយសំណងអាចធ្វើការទាមទារបានតាមរយៈអនីតិជនដែលទទួលបានអត្តាធីនភាព (ចំណុច**ក**) និងក្រោយអនីតិជននោះបានដល់នូវនីតិភាព (ចំណុច**ខ**)។

**ក. ការទាមទារសំណងដោយអនីតិជនដែលទទួលបានអត្តាធីនភាព**

ដូចដែលបានធ្វើការលើកឡើងនៅក្នុងជំពូក១ហើយ អត្តាធីនភាព គឺជាស្ថានភាពមួយដែលផ្តល់ឱ្យអនីតិជនបានរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ រួចផុតពីអំណាចមេបា និងមានសមត្ថភាពដូចជានីតិជនដែរ។

អនីតិជនដែលទទួលបានអត្តាធីនភាព គឺសំដៅទៅលើករណីដែលអនីតិជនដល់អាយុ ១៦ ឆ្នាំ ហើយអាចទ្រទ្រង់ជីវភាពខ្លួនឯងបានដោយឯករាជ្យ នោះតុលាការអាចប្រកាសអត្តាធីនភាពឱ្យអនីតិជនបាន តាមរយៈពាក្យសុំរបស់អនីតិជននោះ នៅពេលដែលតុលាការយល់ថាអត្តាធីនភាពស្របតាមផលប្រយោជន៍របស់អនីតិជន និងត្រូវមានការសួរយោបល់ពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលរបស់អនីតិជនផងដែរ។ ដូចនេះ អនីតិជនដែលទទួលបានអត្តាធីនភាព គឺមាន

[48] មាត្រា៣៦ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

សមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាពនានាស្របតាមច្បាប់សារធាតុ និងអាចធ្វើសកម្មភាពបណ្ដឹងដែលកំណត់ដោយក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ មានន័យថា នៅក្នុងករណីដែលមានអំពើអនីត្យានុកូលបានកើតឡើងដល់អនីតិជនដែលទទួលអត្តាធីនភាព អនីតិជននោះអាចដាក់ពាក្យបណ្ដឹងដើម្បីទាមទារនូវសំណងការខូចខាត ដែលជនដទៃណាមួយបានធ្វើមកលើខ្លួនដោយឯកឯង ឬ ដោយឯករាជ្យ ដោយពុំចាំបាច់មានការអនុញ្ញាតពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនឡើយ។

**ឧទាហរណ៍** ស្រីចិន ជាអនីតិជនដែលទទួលបានអត្តាធីនភាព។ ថ្ងៃមួយ នាងបានជិះម៉ូតូទៅសាលារៀន ខណៈនោះ លោកវណ្ណឌី បានជិះម៉ូតូយ៉ាងលឿនមកប៉ះម៉ូតូរបស់នាង ហើយបានធ្វើឱ្យនាងដួលរងរបួស និង ខូចខាតម៉ូតូខ្ទិចខ្ទី។ ក្នុងករណីនេះ ស្រីចិន អាចដាក់ពាក្យបណ្ដឹងទៅតុលាការ ដើម្បីទាមទារឱ្យលោក វណ្ណឌី ធ្វើការសងសំណងការខូចនានា ដែលនាងបានទទួលរងពីសកម្មភាពរបស់លោក វណ្ណឌី នោះ។

**ខ. ការដល់នីតិភាពក្រោយអំពើអនីត្យានុកូល**

សិទ្ធិទាមទារសំណងនៃការខូចខាត ដោយសារអំពើអនីត្យានុកូល ត្រូវរលត់ដោយអាជ្ញាយុកាល នៅក្នុងអំឡុងពេល ៣ (បី) ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះ បានដឹងថាអាចទាមទារសំណងនៃការខូចខាត ចំពោះអ្នកប្រព្រឹត្តអំពើបំពាន ឬ បើអំឡុងពេល១០ (ដប់) ឆ្នាំ បានកន្លងហួស បន្ទាប់ពីអំពើអនីត្យានុកូលនោះបានកើតឡើង។[49]

ចំពោះអំពើអនីត្យានុកូលបានកើតឡើងទៅលើជនរងគ្រោះជាអនីតិជន អ្នកតំណាងដែលច្បាប់កំណត់ គឺជាអ្នកតំណាងក្នុងការទាមទារសំណងការខូចខាត ប៉ុន្តែក្នុងករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ពុំបានធ្វើការទាមទារ ហើយអាយុកាលនៃសិទ្ធិទាមទារសំណងចំពោះអំពើអនីត្យានុកូលពុំទាន់ផុតរលត់ទេនោះ នៅពេលដែលអនីតិជននោះបានដល់នីតិភាព អនីតិជនអាចធ្វើការទាមទារសំណងចំពោះការខូចខាត ដែលបានកើតពីអំពើអនីត្យានុកូលនោះ ដោយឯករាជ្យខ្លួនឯងបាន។ មានន័យថា ជននោះបានក្លាយទៅជាបុគ្គលដែលមានលក្ខណៈសម្បត្តិពេញលេញក្នុងការធ្វើសកម្មភាពនានាដែលច្បាប់កំណត់បានហើយ។

**ឧទាហរណ៍** អំពើអនីត្យានុកូលមួយបានកើតឡើងចំពោះ កុមារី ឈ្មោះម៉ារ៉ាពី នៅពេលដែលនាងមានអាយុ១៧ឆ្នាំ ១ឆ្នាំក្រោយមក ក្រោយពេលដែល ម៉ារ៉ាពី មានអាយុ១៨ឆ្នាំ នាងអាចធ្វើការទាមទារសំណងការខូចខាតនានាដោយខ្លួនឯង ចំពោះជនដែលបង្កនូវអំពើអនីត្យានុកូលនោះ។

---

[49] មាត្រា៧៦៥នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

# ជំពូកទី ៤

# សិទ្ធិអនីតិជននៅក្នុងសន្តតកម្ម

## ៤.១ លក្ខណៈសម្បត្តិនៃសន្តតិជន

### ៤.១.១ លក្ខខណ្ឌទូទៅ

សន្តតិជនជាអ្នកដែលទទួលបន្ត ឬ ទទួលស្នងនូវសិទ្ធិ និងករណីយកិច្ចពីមតកជន ម៉្យាងវិញទៀត ទោះបីជាបុគ្គលនោះត្រូវបានសន្មតថាជាសន្តតិជនក៏ដោយ ក៏បុគ្គលនោះត្រូវតែគោរពនូវលក្ខខណ្ឌមួយចំនួនទៀត ដូចជាមានជីវិតរស់នៅនាពេលចាប់ផ្តើមសន្តតិកម្ម មិនមែនជាអភ័ព្វបុគ្គល ឬ ត្រូវបានផ្តាច់ចេញមតិក មានសញ្ជាតិខ្មែរ ជាអាទិ៍ ចំពោះមតិកជាដីធ្លី ឬ អចលនវត្ថុ។ ចំពោះលក្ខណៈសម្បត្តិជនដែលសន្មតថាជាសន្តតិជន គឺជនដែលមានជីវិតរស់នៅ ឬ ទារកក្នុងគភ៌នាពេលចាប់ផ្តើមសន្តតិកម្ម។ ជារួមមកសន្តតិជន ត្រូវបានកំណត់ដោយលក្ខខណ្ឌមួយចំនួនដូចជា លក្ខខណ្ឌកំណើត (ចំណុច**ក**) លក្ខខណ្ឌទាក់ទងនឹងញាតិ (ចំណុច**ខ**) និងលក្ខខណ្ឌទាក់ទងនឹងលំដាប់នៃសន្តតិជន (ចំណុច**គ**)។

**ក. លក្ខខណ្ឌកំណើត**

បុគ្គលដែលត្រូវចាត់ទុកថាជាសន្តតិជន គឺបុគ្គលគ្រប់រូបដែលរស់រានមានជីវិត ហើយទទួលបាននូវចំណែករបស់មតកជន ដែលទាក់ទងទៅនឹងសកម្មភាពខាងអាស្រ័យផលៈ

- ទារកក្នុងគភ៌ៈ ចំពោះទារកក្នុងគភ៌ ក៏អាចចាត់ទុកថាជាសន្តតិជនទទួលបានចំណែកមរតក ពីមតកជនបានដែរប្រសិនបើទារកនោះ បានចាប់កំណើតមកហើយរស់រានមានជីវិតបាននៅក្រោយពេលចាប់ផ្តើមសន្តតិកម្ម ទោះបីជាសន្តតិកម្មតាមច្បាប់ក្តី ឬ តាមមតកសាសន៍ក្តី។ ដោយហេតុថានៅពេលដែលទារកចាប់កំណើត ទារកគឺក្លាយជារូបវន្តបុគ្គលពោលគឺទទួលបានបុគ្គលភាពគតិយុត្តរួមមានសិទ្ធិ និងកាតព្វកិច្ចទាំងឡាយ ដែលខ្លួននឹងមាន និងអាចមាន។ ផ្ទុយទៅវិញបើទារកនៅក្នុងគភ៌នោះ កើតមកហើយប៉ុន្តែបានបាត់បង់ជីវិតទៅវិញ មានន័យថា ទារកមិនអាចក្លាយជាសន្តតិជនទទួលបានចំណែកមតិកដែលមាននៅពេលដែលសន្តតិកម្មចាប់ផ្តើម គឺមិនគិតនាថ្ងៃពេលដែលទារកចាប់កំណើតនោះទេ។
- អនីតិជនៈ សំដៅលើជនដែលមានអាយុក្រោម១៨ឆ្នាំ[50] ។ ថ្វីត្បិតតែអនីតិជនដែលត្រូវបានច្បាប់កម្រិតសមត្ថភាព ក្នុងការធ្វើសកម្មភាពក៏ដោយ ក៏មិនមែនមានន័យថា អនីតិជនមិនអាចទទួលបាននូវសិទ្ធិសន្តតិកម្មពីមតកជនបានដែរ។ ជាគោលការណ៍ រាល់សកម្មភាព

[50]មាត្រា១៧នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

របស់អនីតិជនដែលបានធ្វើទាក់ទងនឹងទ្រព្យសម្បត្តិ អ្នកមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជន ត្រូវធ្វើក្នុងនាមជាអ្នកតំណាងឱ្យអនីតិជនដែលពាក់ព័ន្ធនឹងការធ្វើសកម្មភាពទាំងអស់នោះ[51]។ ក្នុងករណីប្រសិនបើអនីតិជនទទួលបានសន្តតិកម្មពីមតកជនដែលជាសកម្មភាពឯកតោភាគីរបស់មតកជន ដោយបានធ្វើចំពោះសហាព័ទ្ធដែលនៅរស់ហើយជាអ្នកមានអំណាចមេបា ឬ ប្រសិនបើគ្មានសហាព័ទ្ធរបស់មតកជននៅរស់ទេ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវធ្វើការយល់ព្រម ឬ បោះបង់សន្តតិកម្ម ក្នុងនាមជាអ្នកតំណាងឱ្យអនីតិជនដើម្បីការពារផលប្រយោជន៍អនីតិជន។ ចំពោះការទទួលសិទ្ធិ ឬ ការរួចផុតពីកាតព្វកិច្ចដែលជាសកម្មភាពផ្តល់ផលប្រយោជន៍ដល់អនីតិជនវិញ អនីតជននោះអាចធ្វើសកម្មភាពដោយពុំចាំបាច់មានការយល់ព្រមពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលនោះឡើយ។[52] ផ្ទុយទៅវិញរាល់សកម្មភាពទាក់ទងទៅនឹងកាតព្វកិច្ចរបស់អនីតិជន ចាំបាច់ត្រូវតែមានការយល់ព្រមពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះជាមុនសិន។

**ខ. លក្ខខណ្ឌទាក់ទងនឹងញាតិ**

ការកំណត់ពីញាតិក្នុងរបបសន្តតិកម្មជាចាំបាច់ត្រូវគណនា ដោយផ្អែកតាមក្រមរដ្ឋប្បវេណីបានសេចក្តីថា បុគ្គលដែលអាចទុកថាជាញាតិរបស់មតកជន និងគ្រប់លក្ខណៈសម្បត្តិក្លាយជាសន្តតិជនបាននោះ លុះត្រាតែធ្វើការបកស្រាយតាមចំណុចសំខាន់ៗមួយចំនួនរួមមានៈ

- **ការសន្មតបិតុភាព៖** ទារកក្នុងគភ៌ប្រពន្ធដែលមានក្នុងចំណងអាពាហ៍ពិពាហ៍ ត្រូវសន្មតថាជាកូនរបស់ប្តី។ កូនដែលបានកើតនៅក្រោយអំឡុងពេល១៨០ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ត្រូវបានបង្កើត ឬ អំឡុងពេល៣០០ថ្ងៃ គិតចាប់ពីថ្ងៃបានរំលាយ ឬ លុបចោលអាពាហ៍ពិពាហ៍ត្រូវបានសន្មតថាមានគភ៌ នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍នោះ តាមច្បាប់ត្រូវបានហៅថា ការកំណត់អំពីបិតុភាពតាមការសន្មត[53]។ ក្នុងករណីដែលស្ត្រីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀតផ្ទុយនឹងបទប្បញ្ញត្តិនៃមាត្រា ៩៥០ (អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត)[54]។

ម្យ៉ាងវិញទៀត ការកំណត់អំពីបិតុភាព អាចធ្វើទៅបានតាមវិធីមួយទៀតដែរ នោះគឺការកំណត់បិតុភាពតាមការទទួលស្គាល់ ដែលការកំណត់តាមការទទួលស្គាល់គឺដោយស្ម័គ្រចិត្ត ជាការ

[51] មាត្រា១០៥៣នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[52] មាត្រា១៨នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[53] មេធាវី ទេព បូផល, <បុគ្គភាព និងអំណាចមេបា> (បទបង្ហាញក្នុងសិក្ខាសាលា, ១០ ឧសភា ២០១៥)

[54] មាត្រា៩៨៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

បង្ហាញឆន្ទៈរបស់ឪពុកទទួលស្គាល់កូន ហេតុនេះ ការទទួលស្គាល់ដោយស្ម័គ្រចិត្តនេះ អាចអនុវត្តបានចំពោះតែក្នុងករណីដែលឪពុកខ្លួនឯងស្ម័គ្រចិត្តទទួលស្គាល់កូននោះតែប៉ុណ្ណោះ ហើយបើឪពុកមិនទទួលស្គាល់កូនវិញនោះ មិនអាចប្រើប្រាស់តាមវិធីទទួលស្គាល់នេះបានទេ។ តើក្នុងករណីឪពុកជាអនីតិជន ឬ ជាជននៅក្រោមអាណាព្យាបាលទូទៅអាចទទួលស្គាល់កូនបានដែរ ឬ ទេ?ក្នុងករណីនេះ ទោះបីអនីតិជន ឬ ជាជននៅក្រោមអាណាព្យាបាលទូទៅក៏ដោយ ក៏ឪពុកអាចទទួលស្គាល់កូនបានដែរ ដោយពុំចាំបាច់មានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ឡើយ[55]។ ការទទួលស្គាល់នេះលុះត្រាតែ ជននោះអាចមានស្មារតីយល់ដឹងប្រសើរជាងមុន ហេតុនេះប្រសិនបើឪពុកដែលស្ថិតនៅក្នុងស្ថានភាពមិនដឹងអ្វីសោះនោះ នឹងមិនអាចមានអានុភាពក្នុងការកំណត់បិតុភាពបានឡើយ ហើយនឹងមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីក្លាយជាសន្តតិជនលំដាប់ទី១បានដែរ[56]។ លើសពីនេះ ថ្វីត្បិតតែការទទួលស្គាល់ ផ្តោតទៅលើការបង្ហាញឆន្ទៈរបស់ឪពុកក៏ពិតមែន ប៉ុន្តែឆន្ទៈរបស់កូនក៏ជាចំណុចដែលត្រូវពិចារណាដែរ ហេតុនេះច្បាប់បានកំណត់អំពីស្ថានភាពដែលត្រូវទទួលការយល់ព្រម និងស្ថានភាពដែលត្រឹមតែការបង្ហាញឆន្ទៈរបស់ឪពុក ដែលការទទួលស្គាល់កូនជាអនីតិជន ដោយមិនចាំបាច់មានការយល់ព្រមពីកូន ឬ ពីអ្នកតំណាងដែលច្បាប់បានកំណត់នោះទេ[57] ពីព្រោះអនីតិជនមិនអាចបង្ហាញឆន្ទៈយល់ព្រមបានទេ ហើយទំនាក់ទំនងនេះ គឺជាទំនាក់ទំនងដែលផ្សាភ្ជាប់នឹងបុគ្គល ជាហេតុដែល អ្នកតំណាងដែលច្បាប់បានកំណត់ ក៏មិនអាចសម្រេចជំនួសសាមីខ្លួនបានដែរ ម្យ៉ាងវិញទៀត ការទទួលស្គាល់កូន គឺមានផលប្រយោជន៍ដល់កូននោះ ដូចនេះ ត្រឹមតែការបង្ហាញឆន្ទៈទទួលស្គាល់របស់ឪពុក គឺគ្រប់គ្រាន់ហើយ។ តាមរយៈការទទួលបិតុភាពចំពោះកូន ដែលជាជននៅក្រោមអាណាព្យាបាលទូទៅវិញ ក្រមរដ្ឋប្បវេណីពុំបានបញ្ញត្តអំពីករណីនេះឱ្យបានច្បាស់លាស់នោះទេ ប៉ុន្តែទោះបីជាក្រមរដ្ឋប្បវេណីមិនបានបញ្ញត្តអំពីករណីនេះក៏ដោយ ក៏ក្រមរដ្ឋប្បវេណីពុំបានបញ្ញត្តមាត្រាណាមួយ ហាមឃាត់ការទទួលស្គាល់កូនដែលជាជននៅក្រោមអាណាព្យាបាលទូទៅដែរ ហេតុនេះហើយ ឪពុកអាចទទួលស្គាល់កូនដែលជាជននៅក្រោមអាណាព្យាបាលទូទៅបាន ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅនោះទេ[58]។

- **មាតុភាព** ស្ត្រីដែលបានសម្រាលកូន គឺជាម្តាយរបស់កូន[59]។ ចុះក្នុងករណីដែលមានការយកមេជីវិតរបស់ប្តីប្រពន្ធ នៅដាក់បញ្ចូលក្នុងស្បូនរបស់ស្ត្រីម្នាក់ ដើម្បីឱ្យស្ត្រីនោះជួល

[55] មាត្រា៩៩៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[56] មេធាវី ទេព បូផល, <បុគ្គភាព និងអំណាចមេបា> (បទបង្ហាញក្នុងសិក្ខាសាលា, ១០ ឧសភា ២០១៥)

[57] មាត្រា៩៩៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[58] មេធាវី ទេព បូផល, <បុគ្គភាព និងអំណាចមេបា> (បទបង្ហាញក្នុងសិក្ខាសាលា, ១០ ឧសភា ២០១៥)

[59] មាត្រា៩៨៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ពពោះ និងសម្រាលកូនឱ្យ តើក្នុងករណីនេះ មាតុភាព និងបិតុភាព ត្រូវសម្រេចបែបណា? ក្នុងករណីនេះ ផ្អែកតាមក្រមរដ្ឋប្បវេណី ការទទួលស្គាល់មាតុភាព គឺទទួលតែម្តាយដែលបានបង្កើតកូននោះតែប៉ុណ្ណោះ លើកលែងតែមានច្បាប់ពិសេសមានចែងទាក់ទងនឹងការបង្កើតកូនសិប្បនិមិត្ត[60]។ ដំណោះស្រាយល្អចំពោះករណីនេះ ដើម្បីបង្កើតឱ្យមានទំនាក់ទំនងញាតិភាពជាមួយឪពុកបាន ឪពុកអាចធ្វើការទទួលស្គាល់កូនបាន ដូចដែលមានបញ្ញត្តិនៅក្នុងមាត្រា ៩៩៣ នៃក្រមរដ្ឋប្បវេណី ឬ តាមរយៈសុំកូន ប៉ុន្តែចំពោះស្ត្រីដែលផ្តល់មេជីវិត ដើម្បីបង្កើតទំនាក់ទំនងញាតិរវាងម្តាយ និងកូនអាចធ្វើបានតែតាមរយៈសុំកូនតែប៉ុណ្ណោះ។

- **ការទាមទារឱ្យទទួលស្គាល់** ក្នុងករណីឪពុកម្តាយមិនព្រមទទួលស្គាល់កូន កូនមិនអាចធ្វើការទទួលឪពុកតាមវិធីទទួលស្គាល់តាមមាត្រា ៩៩៣ នៃក្រមរដ្ឋប្បវេណីបានទេ ប៉ុន្តែក្នុងករណីនេះ កូនអាចទាមទារឱ្យឪពុកទទួលស្គាល់បាន ដោយកូននោះអាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ ប្រសិនបើកូនបានទទួលមរណភាព បច្ឆាញាតិរបស់កូននោះ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់បាន។ កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងទាមទារ ឱ្យទទួលស្គាល់ក្នុងអំឡុងពេល១ឆ្នាំ ដោយគិតចាប់ពីពេលដែលបានដឹងថាជននោះជាឪពុក[61] លើកលែងកូនដែលត្រូវបានឪពុកបដិសេធការទទួលស្គាល់ ឬ ក្នុងស្ថានភាពដែលឪពុកមិនអាចបង្ហាញឆន្ទៈទទួលស្គាល់ ជាអាទិ៍។ ផ្ទុយទៅវិញ កូនដែលធ្លាប់បានបដិសេធចំពោះការទទួលស្គាល់របស់ឪពុក កូននោះមិនអាចធ្វើបណ្តឹងទាមទារឱ្យទទួលស្គាល់បានទេ។ ម្យ៉ាងវិញទៀត បណ្តឹងទាមទារឱ្យទទួលស្គាល់នេះ ត្រូវដោះស្រាយតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ហើយត្រូវធ្វើឡើងដោយកូន ដែលយកឪពុកមកធ្វើជាចុងចម្លើយ[62] ក្នុងករណីដែលឪពុកបានទទួលមរណភាព កូនអាចធ្វើបណ្តឹងទាមទារឱ្យទទួលស្គាល់បាន ដោយយកតំណាងអយ្យការធ្វើជាចុងចម្លើយ។ បើក្នុងករណីឪពុកជាចុងចម្លើយ ហើយក្នុងបណ្តឹងទាមទារនេះ ឪពុកបានទទួលមរណភាពនៅពេលដែលតុលាការកំពុងចាត់ការបណ្តឹង តំណាងអយ្យការត្រូវទទួលបន្តនូវនីតិវិធីបណ្តឹងនោះ[63]។ ចំពោះករណី កូនដែលចង់ទាមទារការទទួលស្គាល់បិតុភាពបានទទួលមរណភាព

[60] មេធាវី ទេព បូផល, <បុគ្គភាព និងអំណាចមេបា> (បទបង្ហាញក្នុងសិក្ខាសាលា, ១០ ឧសភា ២០១៥)
[61] មាត្រា១០០១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
[62] មាត្រា៣ ចំណុច ង និងមាត្រា២៦ នៃច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល
[63] មាត្រា១០០១ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ និងមាត្រា២៦ នៃច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

អ្នកមានសិទ្ធិធ្វើបណ្តឹងជំនួស គឺបច្ឆាញាតិផ្ទាល់របស់កូននោះ។[64] ម្យ៉ាងទៀត ក្នុងករណីដែលកូនបានទទួលមរណភាព ក្រោយពីបានដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចទទួលបន្តនូវនីតិវិធីបណ្តឹងនោះ ក្នុងអំឡុងពេល ០១ ឆ្នាំ គិតចាប់ពីថ្ងៃដែលកូនបានទទួលមរណភាព[65] ហើយបើក្នុងករណីដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះជាអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់របស់កូន ឬ បច្ឆាផ្ទាល់ជាអ្នកដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ជំនួសជនទាំងនោះបាន។ ពិសេសជាងនេះទៅទៀត អនីតិជនក៏អាចធ្វើពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ដោយខ្លួនឯងបានផងដែរ ឬ ប្រសិនបើអនីតិជននោះមានសមត្ថភាពខាងឆន្ទៈពេញលេញ[66] លើសពីនេះជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ក៏អាចធ្វើបណ្តឹងដោយខ្លួនឯងបានដែរ ប្រសិនបើជននៅក្រោមអាណាព្យាបាលទូទៅនោះមានសមត្ថភាពខាងឆន្ទៈ។

**គ. លក្ខខណ្ឌទាក់ទងនឹងលំដាប់សន្តតិជន**

សន្តតិកម្មតាមបញ្ញត្តិច្បាប់បើបានធ្វើការបែងចែកសន្តតិកម្មជាពីរប្រភេទគឺ សន្តតិជនដែលជាញាតិលោហិតរបស់មតកជន និងសន្តតិជនជានិច្ច ដែលជាសហព័ទ្ធរបស់មតកជន។ នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ បានកំណត់នូវលំដាប់សន្តតិជនជាបីលំដាប់មានដូចជា៖ បច្ឆាញាតិផ្ទាល់របស់មតកជនជាសន្តតិជនលំដាប់ទី១ បុព្វញាតិផ្ទាល់របស់មតកជនជាសន្តតិជនលំដាប់ទី២ និងបងប្អូនបង្កើតរបស់មតកជនជាលំដាប់ទី៣។

- កូនរបស់មតកជនជាសន្តតិជនលំដាប់ទី១៖ បើទោះបីជាកូនរបស់មតកជននោះជាកូនបង្កើតក្តី ឬ កូនសុំក្តី ត្រូវទទួលចំណែកមត៌កស្មើៗគ្នាពីមតកជន[67]។ ត្រង់ចំណុចនេះពាក្យថាកូនរបស់ ″មតកជន″ មានន័យថា កូនមានចំណងបុត្តភាពគតិយុត្ត ដែលត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់ ដោយរាប់ទាំងកូនកើតក្រៅចំណងអាពាហ៍ពិពាហ៍(កូនឥតខាន់ស្លា)ក៏ត្រូវមានចំណែកមត៌កស្មើៗគ្នានឹងកូនដែលដែលមានចំណងអាពាហ៍ពិពាហ៍ផងដែរ[68]។ ក្នុងករណីដែលកូនកើតក្រៅចំណងអាពាហ៍ពិពាហ៍ ទោះបីជាមានទំនាក់ទំនងបិតុភាពបង្កើតក៏ដោយ ប្រសិនបើទំនាក់ទំនងនោះមិនត្រូវបានទទួលស្គាល់ទេ បុត្តភាពតាមផ្លូវច្បាប់ក៏មិនអាចទទួលស្គាល់បានដែរ ដូចនេះ កូននោះមិនអាចក្លាយជាសន្តតិជនរបស់មតកជនទេ។

[64] មាត្រា១០០១ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[65] មាត្រា ២៦ កថាខណ្ឌ ៣ នៃច្បាប់ស្តីពី បណ្តឹងទាក់ទងនឹងឋានៈបុគ្គល

[66] មាត្រា៨ កថាខណ្ឌ១ នៃច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

[67] មាត្រា១១៥៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[68] ប៊ួយ ធីតា, អ៊ុន សក្កដា, ជុំ អ៊ីម, <មូលដ្ឋានគ្រឹះនៃសន្តតិកម្ម (ផ្នែកទី១)> (បទបង្ហាញក្នុងសហសាល សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ១៨ ឧសភា ២០១៦)

- សន្តតិជនលំដាប់ទី២៖ ក្នុងករណីដែលមតកជនមិនមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនលំដាប់ទី១ទេនោះ បុព្វញាតិខ្សែផ្ទាល់របស់មតកជននឹងត្រូវក្លាយជាសន្តតិជន។ បុព្វញាតិសំដៅចំពោះ ឪពុកម្តាយ ជីដូនជីតារបស់មតកជន ជាអាទិ៍។ ឪពុកម្តាយរបស់មតកជនក្លាយជាសន្តតិជននោះ ត្រូវទទួលទ្រព្យសម្បត្តិស្មើៗគ្នា តែប្រសិនបើមតកជនមានតែឪពុក ឬ ម្តាយ ដែលនៅរស់នោះគាត់នឹងទទួលបានមតិកជនតែម្នាក់ឯង។ ម៉្យាងវិញទៀត ប្រសិនបើឪពុកម្តាយរបស់មតកជនទទួលមរណភាពមុនមតកជននោះ ឪពុកម្តាយរបស់មតកជនដែលជាជីដូនជីតារបស់មតកជនត្រូវក្លាយជាសន្តតិជន ហើយទទួលសន្តតិកម្មពីមតិកជននោះ។ ប៉ុន្តែបើបុព្វញាតិមានចំនួនច្រើននាក់សន្តតិជននីមួយៗ ត្រូវទទួលចំណែកមតិកស្មើគ្នា ទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម។[69]
- សន្តតិជនលំដាប់ទី៣៖ ប្រសិនបើមតកជនមិនមានទាំងបច្ឆាញាតិផ្ទាល់ ទាំងបុព្វញាតិដែលត្រូវក្លាយជាសន្តតិជននោះទេ បងប្អូនបង្កើតរបស់មតកជនត្រូវក្លាយជាសន្តតិជន។ បើបងប្អូនបង្កើតមានច្រើននាក់ ម្នាក់ៗត្រូវមានចំណែកមតិកស្មើៗគ្នា។ ប៉ុន្តែចំណែកមតិករបស់បងប្អូនបង្កើតដែលមានឪពុក ឬ ម្តាយតែម្ខាងដូចគ្នាទៅនឹងមតកជនត្រូវទទួលបាន ១ភាគ២ នៃចំណែកមតិករបស់បងប្អូនដែលមានឪពុក និងម្តាយទាំងសងខាង។[70]

### ៤.១.២ លក្ខណៈមិនអាចក្លាយជាសន្តតជន

យោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ញត្តទាក់ទងនឹងបុគ្គល ដែលមិនអាចក្លាយជាសន្តតិជន ក្នុងការទទួលយកចំណែកមតិកពីមតកជននាពេលចាប់ផ្តើមសន្តតិកម្មបានឡើយ ជនទាំងនោះមានដូចជា អភ័ព្វបុគ្គលនៃសន្តតិកម្ម (ចំណុច **ក**) និងការផ្តាច់មតិកពីសន្តតិជន (ចំណុច **ខ**)។

#### ក. អនីតិជនជាអភ័ព្វបុគ្គល

ជាទូទៅ សន្តិជនជាជនដែលទទួលបន្ត ឬ ស្នងនូវសិទ្ធិ និងករណីយកិច្ច របស់មតកជនតាមច្បាប់ ឬ ក៏ដោយឆន្ទៈ ប៉ុន្តែមានលក្ខខណ្ឌពីសេសមួយចំនួន ដែលមិនអាចឱ្យអនីតិជននោះគ្រប់លក្ខណៈសម្បត្តិជាសន្តតិជនបាននោះ គឺ អនីតិជននោះក្លាយជាអភ័ព្វបុគ្គល (ក.១) ឬ ត្រូវបានកាត់ផ្តាច់ពីមតិក (ក.២) ៖

#### ក.១ មូលហេតុ

យោងតាមមាត្រា ១១៥០ មែក្រមរដ្ឋប្បវេណី សន្តតិជនអាចនឹងក្លាយជាជនគ្មានលក្ខណៈសម្បត្តិក្នុងការទទួលបាននូវសន្តតិកម្មដោយហេតុ៖

---

[69] មាត្រា១១៥៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[70] មាត្រា១១៦០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

- ទទួលទោស ដោយមានចេតនាធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាតមតកជន ឬ អ្នកមានលំដាប់សន្តតិកម្មមុន ឬ ស្មើ ទោះបីប្រយោល ឬ ដោយផ្ទាល់ក្តី ដែលក្នុងន័យនេះ សន្តតិជនអាចជាបុគ្គលដែលពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ ក្រោយពីការចោទប្រកាន់ និងសាលក្រមចូលស្ថាពរ។ ជាក់ស្តែង បុគ្គលដែលបានទទួលទោស ក្រោយត្រូវបានរកឃើញថាមានចេតនាចង់សម្លាប់លើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មខ្ពស់ជាង ឬ លំដាប់ស្មើគ្នា ត្រូវចាត់ទុកសន្តតិជននេះ ជាអភ័ព្វបុគ្គលនៃរបបសន្តតិកម្ម លើសពីនេះ សន្តតិជននឹងត្រូវអាចអស់សិទ្ធិផងដែរ ក្នុងករណីដែលរកឃើញថាជាសហចារី ឬ អ្នកសមគំនិត ឬ អ្នកផ្តើមគំនិតក្នុងអំពើធ្វើឱ្យប៉ះពាល់ដល់ជីវិតមតកជនបែបនេះ។
- បុគ្គលដែលបានដឹងអំពីការសម្លាប់មតកជន ប៉ុន្តែមិនរាយការណ៍ ឬ មិនប្តឹង លើកលែងតែបុគ្គលនោះមិនអាចវិនិច្ឆ័យល្អ ឬ អាក្រក់ ឬ អ្នកសម្លាប់ជាសហព័ទ្ធ ឬ ញាតិលោហិតខ្សែផ្ទាល់ ក្នុងន័យនេះចំពោះការដឹង ហើយមិនបានរាយការណ៍អំពីការសម្លាប់មតកជន បើតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ការដឹងអំពីបទល្មើសណាមួយ បានកើតឡើង ហើយមិនបានរាយការណ៍នោះ គឺបុគ្គលនោះមានចេតនាលាក់បាំង ដែលត្រូវចាត់ទុកជាអភ័ព្វបុគ្គល ផ្ទុយទៅវិញ បើជនដែលមានការរាយការណ៍នោះ ត្រូវបានគេរកឃើញថាជាជន ដែលមានសតិបញ្ញាមិនគ្រប់គ្រាន់ និងគ្មានការគិតវិនិច្ឆ័យដឹងខុសត្រូវនោះ មិនចាត់ទុកជាអភ័ព្វបុគ្គលនោះទេ។
- បុគ្គលដែលបានរារាំងមតកជន ក្នុងការលុបចោល ឬ កែប្រែមតកសាសន៍ ដោយអំពើឆបោក ឬ គំរាមកំហែង ជាទូទៅការធ្វើមតកសាសន៍ជាសកម្មភាពឯកតោភាគី ដែលមតកជនអាចធ្វើ ឬលុបចោល ឬ អាចកែប្រែ ដោយសេរី ទៅតាមឆន្ទៈរបស់ខ្លួនដោយមិនចាំបាច់ធ្វើការសាកសួរ ឬ យល់ព្រមពីសំណាក់ជនណាម្នាក់ឡើយ ប៉ុន្តែក្នុងករណីដែលមានជនណាម្នាក់ក្នុងសន្តតិជនបានប្រព្រឹត្តអំពើមិនគប្បី ធ្វើការរារាំងមតកជនមិនឱ្យធ្វើលុបចោល ឬ កែប្រែ មតកសាសន៍ ត្រូវបានចាត់ទុកថាជាអភ័ព្វបុគ្គល។ ការរារាំងដោយការឆបោក ការគំរាមកំហែង វាជាអំពើមិនត្រឹមត្រូវ ដែលនាំឱ្យមតកជនធ្វើអ្វីដែលមិនមែនជាឆន្ទៈរបស់ខ្លួន ដោយការជឿនូវការបោកប្រាស់ ឬ ការបង្ខិតបង្ខំដោយមានការគំរាមពីជនណាម្នាក់ ដែលមានផលប្រយោជន៍នៅក្នុងសន្តតិកម្មជាហេតុធ្វើឱ្យប៉ះពាល់ផលប្រយោជន៍របស់សន្តតិជនសុចរិតផ្សេងទៀត។
- បុគ្គលដែលប្រព្រឹត្តអំពើក្លែងបន្លំ បំផ្លាញចោល ឬ លាក់ទុកមតកសាសន៍ ដោយមានចេតនាអាក្រក់ មិនព្រម មិនសុខចិត្ត ទៅនឹងការសម្រេចរបស់មតកជននៅក្នុងមតក

សាសន៍ ជាដើមនឹងត្រូវចាត់ទុកជាអភ័ព្វបុគ្គល។ លើសពីនេះ ការក្លែងបន្លំ គឺជាការផ្លាស់ប្តូរនូវមតកជនបានធ្វើ ជាមួយគ្នានេះផងដែរ ការបំផ្លាញ គឺជាការបំបាត់ចោល ឬ បំផ្លាញចោល នូវមតកសាសន៍ពិតប្រាកដដើម្បីផលប្រយោជន៍ដោយឡែករបស់បុគ្គលណាមួយទៅលើសន្តតិកម្ម។ ចំណែកឯការលាក់ទុកនូវលិខិតមតកសាសន៍ គឺជាការលាក់ទុកមិនព្រមបង្ហាញនូវលិខិតនោះ ដើម្បីបានប្រយោជន៍ណាមួយ។ សកម្មភាពបែបនេះ ក្នុងរបបសន្តតិកម្ម តាមក្រមរដ្ឋប្បវេណី សុទ្ធតែជាសកម្មភាពរបស់បុគ្គល ដែលចង់បានផលប្រយោជន៍ទុកខ្លួនឯង បុគ្គលប្រភេទនេះ ត្រូវចាត់ទុកជាអភ័ព្វបុគ្គល។

**ក.២ អានុភាព**

សន្តតិជនដែលជាអភ័ព្វបុគ្គល នឹងត្រូវអស់សិទ្ធិក្នុងការទទួលយកចំណែកមត៌ក ទោះបីជាកូនបង្កើត ឬ ជាសន្តតិជនជានិច្ចរបស់មតកជនក៏ដោយ។ លើសពីនេះ បើសន្តតិជនដែលជាអភ័ព្វបុគ្គលបានធ្វើការកាន់កាប់មត៌ក ត្រូវបានចាត់ថាសន្តតិជនកាន់កាប់មត៌កដោយទុច្ចរិត ដែលមានអានុភាពតាំងពីពេលចាប់ផ្តើមសន្តតិកម្ម[71]។ ដោយឡែក កូន ឬ ឪពុកម្តាយរបស់អភ័ព្វបុគ្គលពុំមានទោស ឬ ធ្វើខុសដូចទៅនឹងអភ័ព្វបុគ្គល ហេតុនេះអាចក្លាយជាសន្តតិជនបានដោយផ្អែកតាមសន្តតិកម្មជំនួសបាន[72]។

**ខ. ការផ្តាច់ចេញពីសន្តតិកម្ម**

ប្រសិនបើមតកជនមានឆន្ទៈមិនប្រគល់នូវទ្រព្យសម្បត្តិទៅឱ្យសន្តតិជន ដោយប្រការណាមួយនោះ ម្ចាស់ទ្រព្យអាចធ្វើការផ្តាច់មត៌កពីសន្តតិជននោះ ទី១ តាមផ្លូវតុលាការ និងទី២ តាមរយៈការកំណត់ក្នុងមតកសាសន៍។

**ខ.១ មូលហេតុ**

ផ្អែកតាមមាត្រា១១៥១ មូលហេតុដែលមតកជនសម្រេចផ្តាច់សន្តតិជនចេញពីការទទួលចំណែកមត៌ក ជាទូទៅបានប្រព្រឹត្តហើយនូវសកម្មភាពមួយចំនួនរួមមាន៖

- បើបានធ្វើបាបចំពោះមតកជន
- បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ
- បើអាចមកមើលថែទាំមតកជននៅពេលដែលមានជំងឺ ប៉ុន្តែមិនមកថែទាំ
- បើត្រូវបានទទួលសាលក្រម ឬ សាលដីកាផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត
- បើបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សម្គាល់ជាអាទិ៍។

[71] មាត្រា១១៥៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[72] Ms.MIURA YASUKO, <សន្តតិកម្ម> (បទបង្ហាញក្នុងសិក្ខាសាលា, គ្មានកាលបរិច្ឆេទ)

**ខ.២ លក្ខខណ្ឌ និងនីតិវិធី**

ក្រោយពីមតកជនសម្រេចកាត់ផ្តាច់សន្តតិជនចេញពីចំណែកមតិករួចហើយ ក្នុងរបបសន្តតិកម្ម មតកជនអាចធ្វើការផ្តាច់មតិកពីសន្តតិជនតាមពីររបៀបរួមមានៈ ការផ្តាច់មតិកពីសន្តតិជនតាមផ្លូវតុលាការ និងការផ្តាច់មតិកពីសន្តតិជនតាមមតកសាសន៍។

- ការផ្តាច់មតិកពីសន្តតិជនតាមផ្លូវតុលាការៈ បើសិនម្ចាស់នៃទ្រព្យសម្បត្តិមានឆន្ទៈផ្តាច់មតិកពីសន្តតិជនតាមផ្លូវតុលាការ ត្រូវដាក់ពាក្យសុំដីកាសម្រេចផ្តាច់មតិកទៅតុលាការដែលមានសមត្ថកិច្ច ដោយភ្ជាប់ជាមួយហេតុផលដែលអាចទទួលយក ដូចមានចែងក្នុងមាត្រា ១១៥១ នៃក្រមរដ្ឋប្បវេណី។
- ការផ្តាច់មតិកពីសន្តតិជនតាមមតកសាសន៍ៈ នៅពេលដែលមតកជនមិនបានដាក់ពាក្យសុំទៅតុលាការដើម្បីផ្តាច់មតិកចេញពីសន្តតិជន ម្ចាស់ទ្រព្យអាចអនុវត្តវិធីម្យ៉ាងទៀតដោយធ្វើការសរសេរតាមរយៈមតកសាសន៍ បានសេចក្តីថា ម្ចាស់បណ្តាំបានធ្វើមតកសាសន៍ផ្តាច់មតិកពីសន្តតិជន ពេលនោះអ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់ពាក្យសុំទៅតុលាការឱ្យផ្តាច់មតិកពីសន្តតិជននោះ ខណៈដែលមតកសាសន៍នោះបង្កើតអានុភាព។ ប៉ុន្តែមតកជន ពេលនៅរស់ក៏អាចដាក់ពាក្យសុំទៅតុលាការ ឱ្យលុបចោលនូវការផ្តាច់មតិកពីសន្តតិជនថ្លោះសិទ្ធិនៅពេលណាក៏បាន[73]។

**គ. អានុភាព**

សន្តតិជនដែលត្រូវបានកាត់ផ្តាច់ពីសន្តតិកម្មតាមវិធីណាក៏ដោយ ក៏ត្រូវបានថ្លោះសិទ្ធិក្នុងការទទួលយកចំណែកមតិកទោះបីជាកូនបង្កើត ឬ ជាសន្តតិជនរបស់មតកជនក៏ដោយ។ ម៉្យាងវិញទៀត ដូចទៅនឹងសន្តតិជនជាអភ័ព្វបុគ្គល បើសន្តតិជនដែលត្រូវកាត់ផ្តាច់ពីសន្តតិកម្មក្រោយមានអានុភាពបានធ្វើការកាន់កាប់មតិក ត្រូវបានចាត់ថាជាសន្តតិជនកាន់កាប់មតិកដោយទុច្ចរិត ដែលមានអានុភាពតាំងពីពេលចាប់ផ្តើមបសន្តតិកម្ម[74]។

## ៤.២ អ្នកតំណាងស្របច្បាប់ក្នុងរបបសន្តតកម្មរបស់អនីតជន

ជាគោលការណ៍ អនីតិជនដែលមានអាយុក្រោម១៨ឆ្នាំ និងត្រូវបានច្បាប់សន្មតថាជនទន់ខ្សោយខាងការបង្ហាញឆន្ទៈ ដូចនេះ អនីតិជនចាំបាច់ត្រូវមានការបណ្តុះបណ្តាល អប់រំ និងគ្រប់គ្រងពីសំណាក់អ្នកអាណាព្យាបាល។ ជាទូទៅ អ្នកដែលមានសិទ្ធិ អំណាចតាមផ្លូវច្បាប់ក្នុងការគ្រប់គ្រងអនីតិជន គឺជាអ្នកមានអំណាចមេបា ជាអាទិ៍ ដូចជាឪពុកម្តាយបង្កើត ឬ ឪពុកម្តាយចិញ្ចឹម។ អ្នក

[73] មាត្រា១១៥៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[74] មាត្រា១១៥៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ដែលមានអំណាចមេបាត្រូវមើលថែគ្រប់គ្រងអនីតិជនស្ថិតនៅក្នុងស្ថានភាពថែរក្សា ដូចនេះ ច្បាប់បានបង្កើតឱ្យមាននូវរបបអាណាព្យាបាលសម្រាប់អនីតិជន ដែលអនុញ្ញាតឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនមានសិទ្ធិនិងករណីយកិច្ចមួយចំនួនជំនួសអ្នកមានអំណាចមេបា។ ការបង្កើតឱ្យមានរបបអាណាព្យាបាល ត្រូវគោរពទៅតាមលក្ខខណ្ឌទម្រង់មួយចំនួន ដើម្បីធ្វើការប្រកាសរបបអាណាព្យាបាលសម្រាប់អនីតិជន ដែលត្រូវបកស្រាយដូចខាងក្រោម៖

### ៤.២.១ ការចាប់ផ្តើម និងការប្រព្រឹត្តទៅនៃរបបអាណាព្យាបាលសម្រាប់អនីតិជន

វាមិនមែនជាការចាំបាច់ក្នុងការបង្កើតរបបអាណាព្យាបាលសម្រាប់អនីតិជននៅក្នុងពេលមានអត្ថិភាពនៃអំណាចមេបានៅឡើយទេ។ ដូចនេះ របបអាណាព្យាបាលសម្រាប់អនីតិជន ត្រូវបានបង្កើតឡើងក្នុងករណីដែលមានអង្គហេតុនៃការបាត់បង់អ្នកមានអំណាច ការកាត់កាលកូនសុំជាអាទិ៍ ដែលជាមូលហេតុទាំងនេះហើយធ្វើឱ្យអំណាចមេបាត្រូវបានរលត់ហើយវានឹងធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់អនីតិជន ដែលកំពុងស្ថិតនៅក្នុងវ័យកម្រិតសមត្ថភាពឡើយនោះ។ ដើម្បីឱ្យមានការជ្រើសរើសអ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវចាំបាច់ឆ្លងតាមនីតិវិធីតុលាការដោយឈរលើគោលគំនិតការពារផលប្រយោជន៍របស់អនីតិជនផ្ទាល់។ ការដែលអនុញ្ញាតឱ្យមានការបង្កើតអាណាព្យាបាលសម្រាប់អនីតិជនក្រៅផ្លូវតុលាការ អាចជួបផលវិបាកដូចជាខូះលក្ខណៈសម្បត្តិ ខាតផលប្រយោជន៍អនីតិជន ជាពិសេសទ្រព្យសម្បត្តិរបស់អនីតិជន។

#### ក. មូលហេតុនៃការចាប់ផ្តើមរបបអាណាព្យាបាលសម្រាប់អនីតិជន

ដោយសារតែនត្ថិភាពនៃអ្នកមានអំណាចមេបា បានធ្វើឱ្យអនីតិជនស្ថិតនៅក្នុងស្ថានភាពពុំមានអ្នកគ្រប់គ្រង ដូចនេះ ជាចាំបាច់ ត្រូវបង្កើតឱ្យមានរបបសម្រាប់គ្រប់គ្រងអនីតិជន ដែលមានលក្ខណៈប្រហាក់ប្រហែលទៅនឹងអំណាចមេបាដែរ។ ប្រសិនបើអនីតិជនក្រោយពេលមរណភាពនៃឪពុកម្តាយ បានធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិមួយចំនួន ជាហេតុ វាគឺជាការប្រសើរម្យ៉ាងបើមានអ្នកតំណាងឱ្យអនីតិជន ចំពោះការចាត់ចែងទ្រព្យសម្បត្តិទាំងនោះ ជាពិសេសនៅក្នុងរបបសន្តតិកម្ម ដោយសារតែអនីតិជន ជាសន្តតិជនពុំអាចធ្វើសកម្មភាពសុពលបានឡើយ។ លើសពីនេះវាជាការសម្រេចចិត្តដ៏ល្អផងដែរ របស់អ្នកមានអំណាចមេបាចុងក្រោយមុនពេលមរណភាពបានផ្តាំផ្ញើឱ្យអ្នកអាណាព្យាបាលសម្រាប់នីតិជនមើលថែរក្សាអនីតិជនឱ្យបានល្អតាមរយៈមតកសាសន៍។

#### ខ. លក្ខខណ្ឌនៃការប្រកាសរបបអាណាព្យាបាលសម្រាប់នីតិជន

របបអាណាព្យាបាលសម្រាប់អនីតិជន ត្រូវបានប្រកាសដោយដីកាសម្រេចរបស់តុលាការដោយឈរលើមូលដ្ឋាន នៃច្បាប់ស្តីពី នីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង យោងតាម

ឧបសម្ព័ន្ធទី៤ ចំណុច២៨។ តុលាការដែលមានសមត្ថកិច្ចក្នុងការចេញដីកាសម្រេចប្រកាសចាប់ផ្តើមអាណាព្យាបាលសម្រាប់អនីតិជន គឺតុលាការនៃលំនៅឋានរបស់អនីតិជនក្រោយអាណាព្យាបាល។

ការប្រកាសរបបអាណាព្យាបាលសម្រាប់អនីតិជន តុលាការអាចប្រកាសបានដោយឈរលើមូលដ្ឋានរួមមាន (ខ.១) តាមឆន្ទៈរបស់មតកជនដែលជាអ្នកមានអំណាចមេបាចុងក្រោយ និង (ខ.២) ពាក្យស្នើសុំរបស់បុគ្គលមួយចំនួន។

### ខ.១ ការប្រកាសផ្អែកលើមតកសាសន៍

មតកជនកាលនៅរស់ដែលត្រូវជាអ្នកមានអំណាចមេបាចំពោះអនីតិជន អាចកំណត់យកអ្នកអាណាព្យាបាលសម្រាប់អនីតិជននៅក្នុងមតកសាសន៍បាន។ ករណីនេះតុលាការត្រូវសម្រេចតាមឆន្ទៈរបស់មតកជនជាចម្បង ផ្ទុយទៅវិញចំពោះអ្នកមានអំណាចមេបាដែលត្រូវបានតុលាការសម្រេចដកហូត ឬ ព្យួរពុំមានសិទ្ធិកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជនឡើយ។ ទោះបីជានៅក្នុងមតកសាសន៍បានកំណត់អំពីអ្នកអាណាព្យាបាលសម្រាប់អនីតិជនក៏ដោយ ក៏ពុំអាចបង្កើតអានុភាពគតិយុត្តនោះទេ ដរាបណាពុំមានដីកាសម្រេចស្ថាពរពីតុលាការមានសមត្ថកិច្ច។

### ខ.២ ការប្រកាសផ្អែកលើពាក្យសុំ

ប្រសិនបើបានរកមិនឃើញថាការបង្ហាញឆន្ទៈកំណត់ជ្រើសតាំងអ្នកអាណាព្យាបានសម្រាប់អនីតិជននៅក្នុងមតកសាសន៍ទេនោះ តុលាការអាចសម្រេចតាមពាក្យសុំរបស់ញាតិក្នុង៤ថ្នាក់របស់អនីតិជន មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជន នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន[75]។

ចំពោះមូលដ្ឋានក្នុងការសម្រេចសេចក្តី តុលាការត្រូវពិចារណាលើ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត និងស្ថានភាពជីវភាព និងទ្រព្យសម្បត្តិរបស់អនីតិជន វិជ្ជាជីវៈ និងប្រវត្តិរូបរបស់អ្នកដែលត្រូវធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអត្ថិភាព ឬ នត្ថិភាព នៃទំនាក់ទំនងផលប្រយោជន៍រវាងអ្នកធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន យោបល់របស់អនីតិជន និងស្ថានភាពផ្សេងទៀត ជាដាច់ខាត។ ក្នុងករណីដែលមានអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានលាឈប់ ឬ របបអាណាព្យាបាលសម្រាប់អនីតិជនត្រូវបានលុបចោល តុលាការត្រូវធ្វើការជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនថ្មី តាមបញ្ញត្តិមាត្រា ១០៦៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។ ដោយឡែក ដើម្បីធានាការអនុវត្តករណីយកិច្ចរបស់អ្នកអាណាព្យាបាលទូទៅបានពេលលេញ ច្បាប់បានបង្កើតឡើងឱ្យមាននូវប្រព័ន្ធត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមនីតិវិធីជ្រើសតាំងដូចខាងលើ។

[75] មាត្រា១១៦៨ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ៤.២.២ ករណីយកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

ក្រោយពីមានការទទួលស្គាល់ដោយច្បាប់ជាធរមាន ថាគ្រប់លក្ខណៈសម្បត្តិជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនរួចនោះ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ នឹងត្រូវមានសិទ្ធិ និងករណីយកិច្ចមួយចំនួន ដែលត្រូវតែធ្វើដើម្បីជាប្រយោជន៍សម្រាប់អនីតិជនក្នុងរបបសន្តតិកម្ម ហើយ ករណីយកិច្ចទាំងនោះរួមមាន ករណីយកិច្ចគ្រប់គ្រងថែរក្សាអនីតិជន (ចំណុច**ក**) ការគ្រប់គ្រងទ្រព្យសម្បត្តិ និងការតំណាង (ចំណុច**ខ**) និងករណីយកិច្ចគ្រប់គ្រងដោយប្រុងប្រយ័ត្ន (ចំណុច**គ**)។

**ក. ករណីយកិច្ចគ្រប់គ្រងថែរក្សាអនីតិជន**

យោងតាមមាត្រា១០៧៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី អ្នកអាណាព្យាបាលសម្រាប់អនីតិជនមានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងអ្នកមានអំណាចមេបាដែរ។ ការថែងដូចគ្នានេះ មិនមានន័យថាអ្នកអាណាព្យាបាលសម្រាប់អនីតិជនមានអំណាចមេបាចំពោះអនីតិជនឡើយ គឺគាត់គ្រាន់តែអនុវត្តសិទ្ធិ និងករណីយកិច្ចដូចគ្នាទៅនឹងអ្នកមានអំណាចមេបាដូចនេះដែរ។ ចំពោះកិច្ចការមួយចំនួនដែលពាក់ព័ន្ធទៅនឹងការអប់រំ ការផ្តល់ទីសំណាក់ ការដាក់ទណ្ឌកម្ម និងការអនុញ្ញាតឱ្យប្រកបអាជីវកម្ម ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល ចាំបាច់ត្រូវមានការអនុញ្ញាតពីគាត់សិន។ ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន អនុវត្តសិទ្ធិលើសពីទំហំនៃការកម្រិតសិទ្ធិតំណាងនោះ សកម្មភាពដែលបានធ្វើនឹងអាចជាមូលហេតុនៃការលុបចោល នៃរបបអាណាព្យាបាលនោះ[76]។

**ខ. ការគ្រប់គ្រងទ្រព្យសម្បត្តិ និងការតំណាង**

អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានករណីយកិច្ចតំណាងឱ្យអនីតិជននៅក្នុងសកម្មភាពនានា ដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់អនីតិជនដែលទទួលបានដូចជា ការចុះកិច្ចសន្យាលក់ទិញ ការដាក់ពាក្យបណ្តឹងទាមទារ ជាអាទិ៍ ដោយសារតែអនីតិជន គឺជាអសមត្ថជននៅក្នុងការធ្វើសកម្មភាព ដូចនេះមានតែអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះទេ ដែលអាចការពារផលប្រយោជន៍របស់អនីតិជន នៅក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ និងការតំណាងក្នុងការធ្វើសកម្មភាពផ្សេងៗ។ ដើម្បីជៀសវាងវិវាទផលប្រយោជន៍ ក្រោយពេលចាប់ផ្តើមអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវ ចាប់ផ្តើមស្រាវជ្រាវទ្រព្យសម្បត្តិរបស់អនីតិជន ឱ្យបានឆាប់រហ័សក្នុងអំឡុងពេល៣ខែ គិតចាប់ពីដីកាសម្រេចប្រកាសអាណាព្យាបាលសម្រាប់អនីតិជនចូលជាស្ថាពរ និងត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិនោះ ប្រសិនបើពុំដូចនេះទេ អនីតិជនដែលជាជនទន់ខ្សោយនៅតែមានបង់ផលប្រយោជន៍ ដោយសារខ្លួនពុំមានលទ្ធភាពអាចយល់ដឹង

[76] មាត្រា១១៩១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

អំពីអត្ថិភាពនៃទ្រព្យរបស់ខ្លួន ជាហេតុនាំឱ្យអ្នកអាណាព្យាបាល អាចឆ្លៀតឱកាសកេងចំណេញផលប្រយោជន៍របស់អនីតិជន។ ម្យ៉ាងវិញទៀត ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនមានសិទ្ធិលើបំណុលចំពោះអនីតិជន អ្នកអាណាព្យាបាល នោះត្រូវរាយការណ៍ជូនអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន។ ប្រសិនបើមានការខកខានការអនុវត្តករណីយកិច្ចនេះ សិទ្ធិលើបំណុលរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវរលត់ ហើយគាត់មិនអាចទាមទារនៅពេលក្រោយដោយផ្អែកលើអាជ្ញាយុកាលនៃសិទ្ធិលើបំណុលធម្មតាបានឡើយ។ មួយវិញទៀត ករណីនៅក្នុងពេលអនុវត្តសិទ្ធិ និងករណីយកិច្ចរបស់ខ្លួន អាចកើតមានភាពផ្ទុយគ្នារវាងផលប្រយោជន៍អ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមពាក្យសុំដែលធ្វើឡើងតាម ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង ផ្អែកតាមឧបសម្ព័ន្ធផ្នែកទី៤ ចំណុចទី២៦ ក្នុងគោលបំណងមិនចង់ឱ្យការអនុវត្តសិទ្ធិរបស់ខ្លួន ធ្វើឱ្យកើតផលប្រយោជន៍សម្រាប់ខ្លួនតែម្ខាង ដោយសារតែអ្នកអាណាព្យាបាលសម្រាប់អនីតិជន គឺជាករណីយកិច្ចដែលត្រូវបានតែងតាំង ដូចនេះរាល់ការចំណាយជាទូទៅក្នុងការអនុវត្តសិទ្ធិ និងករណីយកិច្ចរបស់ខ្លួនដូចជាការផ្គត់ផ្គង់ជីវភាពរស់នៅ ការចំណាយសម្រាប់ការព្យាបាលត្រូវជាបន្ទុកនៃទ្រព្យសម្បត្តិរបស់អនីតិជន។ ម្យ៉ាងទៀតចំពោះតម្លៃតបនឹងការងារមើលថែរក្សាអនីតិជន ច្បាប់បានអនុញ្ញាតឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ទទួលបាននូវកម្រៃដែលសម្រេចពីតុលាការនៅពេលប្រកាសចាប់ផ្តើមរបប។

**គ. ករណីយកិច្ចគ្រប់គ្រងដោយប្រុងប្រយ័ត្ន**

អ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវអនុវត្តសិទ្ធិ និងករណីយកិច្ចរបស់ខ្លួនក្នុងនាមអ្នកគ្រប់គ្រងដោយសុច្ចរិត។ ក្នុងករណីមានវិវាទប៉ះពាល់ផលប្រយោជន៍រវាងអ្នកអាណាព្យាបាលសម្រាប់អនីតិជនជាមួយនឹងអនីតិជន កាលបើអាណាព្យាបាលសម្រាប់អនីតិជនពុំបានសុំទៅតុលាការ មានការតែងតាំងអ្នកតំណាងពិសេសទេនោះ វាគឺជាការអនុវត្តករណីយកិច្ចដោយទុច្ចរិត ដោយក្នុងស្ថានភាពបែបនេះ អនីតិជនអាចទាមទារសំណងការខូចខាត ដោយធ្វើសកម្មភាពឯករាជ្យ (ប្តឹងផ្តល់) ដោយខ្លួនឯងបានដោយពុំចាំបាច់មានអ្នកតំណាងឡើយ។

### ៤.២.៣ ការរលត់នៃរបបអ្នកអាណាព្យាបាលសម្រាប់អនីតិជន

ដូចការបកស្រាយខាងដើម ក្រោយពីមានច្បាប់សម្រេចទទួលស្គាល់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរួចហើយ ពេលនោះ នឹងមានការកកើតរបបអ្នកអាណាព្យាបាលសម្រាប់អនីតិជន ប៉ុន្តែដើម្បីជាផលប្រយោជន៍របស់អនីតិជន របបមួយនេះនឹងអាចរលត់ទៅវិញបានផងដែរ ដោយការរលត់នេះ អាចធ្វើឡើងតាមរយៈ ការប្រកាសលុបចោល (ចំណុចក) និងអានុភាពនៃការរលត់របបអាណាព្យាបាលសម្រាប់អនីតិជន (ចំណុចខ)។

**ក. ការប្រកាសលុបចោល**

ដោយហេតុថា គោលបំណងសំខាន់បំផុតនៃអាណាព្យាបាលសម្រាប់អនីតិជន គឺជាការតំណាង និងការអនុវត្តករណីយកិច្ចដែលត្រូវមើលថែអនីតិជន ដូចនេះវានឹងរលត់នៅពេលដែលអនីតិជនក្លាយជាសមត្ថជនតាមរយៈអត្តាធីនភាព ឬ ការគ្រប់អាយុ១៨ឆ្នាំជាដើម។ ប្រសិនបើអនីតិជនមានជីវភាពឯករាជ្យ នៅពេលខ្លួនមានអាយុទើបតែ១៦ឆ្នាំ ខ្លួនអាចដាក់ពាក្យសុំទៅតុលាការ ដើម្បីឱ្យចេញដីកាសម្រេចឱ្យរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជនបានដោយសកម្មភាពឯករាជ្យ បែបនេះហើយតុលាការនឹងវិនិច្ឆ័យដោយយោងលើយោបល់របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនប្រសិនបើមាន។

**ខ. អានុភាពនៃការរលត់របបអាណាព្យាបាលសម្រាប់អនីតិជន**

អនីតិជនដែលត្រូវបានតុលាការប្រកាសឱ្យរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ស្របតាមលក្ខខណ្ឌខាងលើ អនីតិជននោះត្រូវចាត់ទុកថាដល់នីតិភាព និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាពដូចនីតិជនផងដែរ ព្រោះក្នុងរយៈពេលនៃការគ្រប់គ្រងទ្រព្យសម្បត្តិអនីតិជន បានធ្វើឱ្យផ្លាស់ប្តូរនូវចំនួននៃទ្រព្យសម្បត្តិ ដូចនេះ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ សន្តតិជនរបស់អ្នកនោះ ត្រូវធ្វើការគណនាចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិក្នុងអំឡុងពេល ៣ (បី) ខែ បន្ទាប់ពីមានដីកាសម្រេចឱ្យរួចផុតចូលជាស្ថាពរ។ ក្រោយពេលប្រកាសឱ្យរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវជូនដំណឹងដល់តតិយជនដែលមានផលប្រយោជន៍ជាមួយអនីតិជន ជាអាទិ៍ ភាគីនៃកិច្ចសន្យារបស់អនីតិជននៅពេលដែលនៅមានអាណាព្យាបាល សម្រាប់អនីតិជន ដោយបានដឹងអំពីការប្រកាសឱ្យរួចផុតនេះ ដើម្បីទុកជាលក្ខខណ្ឌនៃការតតាំង។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវ និងបកស្រាយលើប្រធានបទស្តីពី សិទ្ធិអនីតិជនតាមការកំណត់ក្នុងក្រមរដ្ឋប្បវេណី មួយរយៈកន្លងមកនេះ យើងអាចធ្វើសេចក្តីសន្និដ្ឋានបានថា សិទ្ធិអនីតិជន គឺជាផ្នែកមួយដ៏សំខាន់ របស់មនុស្សជាតិទាំងមូល ដោយហេតុថានីតិជន ដែលជាជនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាពនានា គឺដំបូងឡើយ ក៏ជាអនីតិជនដែរ ហើយចំពោះទំនាក់ទំនងក្នុងសង្គមអនីតិជន ជាជនដែលមានលក្ខណៈទន់ខ្សោយទាំងកាយសម្បទា និងបញ្ញាស្មារតី ដែលតម្រូវឱ្យមានការកំណត់ជាពិសេសនូវសិទ្ធិរបស់ពួកគេ ក្នុងគោលបំណងដើម្បីការពារការខាតបង់ប្រយោជន៍ណាមួយដែលមិនសមស្រប។

ការកំណត់នូវវិធានជាពិសេស គឺជាមធ្យោបាយដ៏សំខាន់ក្នុងការបង្ការទុកជាមុនចំពោះការបង្កើតនូវកិច្ចសន្យាណាមួយដោយអនីតិជន ដែលអាចនឹងធ្វើឱ្យអនីតិជននោះជាប់កាតព្វកិច្ច ឬ ជាប់បន្ទុកដោយពុំសមហេតុផល ការលើកលែង ឬ បន្ថយនូវការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលដែលបានបង្កឡើងដោយអនីតិជននោះ ដោយអាស្រ័យលើសមត្ថភាពនៃការទទួលខុសត្រូវ។ ការទាមទារជាចាំបាច់នូវរបបអ្នកតំណាងសម្រាប់អនីតិជន ចំពោះការទាមទារសំណងការខូចខាតផ្សេងៗ ដែលបានកើតឡើងពីអំពើអនីត្យានុកូល ក៏ដូចជាការការពារភាគីម្ខាងទៀត ដែលទទួលរងនូវព្យសនកម្មដែលកើតពីអំពើអនីត្យានុកូលនោះ។ សិទ្ធិទទួលស្នងនូវសន្តតិកម្មនានា ដែលបន្សល់ទុកពីមតកជន ទោះជាតាមបណ្តាំ ឬតាមច្បាប់កំណត់ ដែលជាការបញ្ជាក់នូវសិទ្ធិមួយដែលអនីតិជនគួរតែទទួលបាន ។

លើសពីនេះទៅទៀត ដើម្បីជាការការពារទំនាក់ទំនងនៃចំណងគតិយុត្តដែលបានបង្កើតឡើងរវាងអនីតិជន និងនីតិជនសុចរិតនោះ ក្រមរដ្ឋប្បវេណីនេះក៏បានកំណត់ផងដែរពីការផ្តល់នូវសិទ្ធិដាស់តឿនរបស់ភាគីម្ខាងទៀតនៃអនីតិជន ទៅអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឱ្យធ្វើការយល់ព្រម ឬ មិនយល់ព្រមពីសុពលភាពនៃកិច្ចសន្យាដែលបានបង្កើតឡើងជាមួយអនីតិជននោះ។ ការផ្តល់សិទ្ធិនេះជាការបង្ហាញឱ្យពីតុល្យភាពនៃកិច្ចសន្យា ដើម្បីកុំឱ្យមានការខាតបង់ចំពោះអនីតិជន និងឱ្យមានដំណើរការទៅនៃកិច្ចសន្យាដែលនីតិជនដែលជាជនសុចរិតបានបង្កើតឡើងជាមួយអនីតិជននោះ។ ជារួមមកការសិក្សាពីសិទ្ធិរបស់អនីតិជនតាមការកំណត់ក្នុងក្រមរដ្ឋប្បវេណី ជាការបង្ហាញនូវអត្ថប្រយោជន៍នានា ដែលក្រមរដ្ឋប្បវេណីបានផ្តល់ឱ្យចំពោះអនីតិជន ដើម្បីឱ្យអនីតិជនអាចរួចផុតពីការរំលោភបំពានពីសមត្ថជនទុច្ចរិត និងអាចជួយសម្រួលជីវភាពរស់នៅរបស់អនីតិជនរហូតដល់នីតិភាពរបស់អនីតិជននោះ។

# អនុសាសន៍

យោងតាមការសិក្សាស្រាវជ្រាវ បកស្រាយ និងការធ្វើសេចក្តីសន្និដ្ឋាន លើប្រធានបទស្តីពីសិទ្ធិអនីតិជនតាមការកំណត់ក្នុងក្រមរដ្ឋប្បវេណីមក ក្រុមយើងខ្ញុំសង្កេតឃើញថាក្រមរដ្ឋប្បវេណីបានផ្តល់នូវការការពារដ៏ល្អសម្រាប់អនីតិជន ប៉ុន្តែទោះជាមានច្បាប់កំណត់ច្បាស់ពីសិទ្ធិទាំងអស់នេះក៏ដោយ ក៏ការអនុវត្តនៅក្នុងសង្គមជាក់ស្តែងនៅមានចន្លោះខ្វះខាតជាច្រើនទាក់ទងនឹងការអនុវត្តសិទ្ធិទាំងអស់នេះដែរ។ កង្វះខាតទាំងនោះមានដូចជា៖

- បញ្ហាជីវភាពរបស់ប្រជាពលរដ្ឋខ្មែរ ដែលជាបញ្ហាដ៏សំខាន់មួយនាំឱ្យការយកចិត្តទុកដាក់ទៅលើសិទ្ធិរបស់អនីតិជនពុំបានគ្រប់គ្រាន់ពេញលេញដូចជាទាក់ទងនឹងការកេងប្រវ័ញ្ចកម្លាំងពលកម្មលើកុមារ ដែលយើងអាចមើលឃើញជាទូទៅក្នុងសង្គមកម្ពុជា ដោយសារតែជីវភាពនៃប្រជាពលរដ្ឋមានភាពខ្វះខាត ដែលតម្រូវឱ្យអនីតិជន ត្រូវធ្វើការទាំងដែលពុំទាន់គ្រប់អាយុ ហើយទទួលបានកម្រៃពលកម្មតិចតួច។
- កត្តាដែលសំខាន់ផ្សេងៗទៀតនោះ គឺការយល់ដឹងអំពីច្បាប់របស់ប្រជាពលរដ្ឋខ្មែរនៅមានកម្រិតទាប និងការផ្សព្វផ្សាយពាក់ព័ន្ធនឹងច្បាប់ទៅដល់ប្រជាពលរដ្ឋ ក៏នៅមិនទាន់ទូលំទូលាយនៅឡើយ ដែលនាំឱ្យការអនុវត្តច្បាប់មានភាពលំបាក។

ការកំណត់ដូចបានរៀបរាប់ខាងលើនេះ គឺជាភាពចាំបាច់មួយដើម្បីស្វែងរកបញ្ហាក្នុង ការដោះស្រាយ និងស្វែងរកច្រកចេញ ឱ្យទាន់ពេលវេលា និងបានឆាប់រហ័ស ដើម្បីស្តារនូវ កង្វះខាតខាងលើ។ ហើយបញ្ហាទាំងនេះគឺជាក្តីកង្វល់មួយរបស់សង្គម ដោយហេតុថានេះគឺជាបញ្ហាដែលទាក់ទងទៅនឹងកុមារដែលជាអនាគត និងក្តីសង្ឃឹមរបស់សង្គមជាតិរបស់យើង។ ខាងក្រោមនេះគឺជាអនុសាសន៍ ដែលឆ្លើយតបទៅនឹងបញ្ហាប្រឈមខាងលើ ដែលកំពុងនឹងជួបប្រទះក្នុងពេលបច្ចុប្បន្នចំពោះកុមារ ដើម្បីធានាឱ្យមានការការពារ កុំមានការបំពានចំពោះបុគ្គលដែលត្រូវបានគេកម្រិតសមត្ថភាពទាំងនោះ ៖

១. សូមស្នើដល់ស្ថាប័នដែលពាក់ព័ន្ធទាំងអស់មេត្តាបង្កើនការយកចិត្តទុកដាក់ចំពោះកុមារប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ ជៀសវាងការរើសអើងចំពោះបុគ្គលនោះ។

២. សូមស្នើឱ្យមានការពង្រីកការចែករំលែកផ្នែកច្បាប់ ទៅប្រជាពលរដ្ឋនៅតាមតំបន់ឱ្យកាន់តែមានភាពទូលំទូលាយជាងមុន។

៣. សូមឱ្យមានការលុបបំបាត់នូវរាល់ការរើសអើង និងឱ្យកុមារទាំងអស់នៅព្រះរាជាណាចក្រកម្ពុជាទទួលបាននូវការអប់រំស្របទៅតាមរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា។

៤ សូមឱ្យស្ថាប័នអនុវត្តច្បាប់មេត្តាយកចិត្តទុកដាក់ចំពោះបញ្ហានេះ និងមានការចែករំលែកទៅកាន់ប្រជាជនបានជ្រាប និងយល់ដឹងកាន់តែច្បាស់៕

# ឯកសារយោង

## ឯកសារច្បាប់

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣
- ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម ០៧០៦/០២១ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦
- ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៧
- ច្បាប់ស្តីពីការងារ លេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៧
- ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និងសេចក្តីកំណត់ចំពោះមាត្រានីមួយៗ លេខនស/រកម/០០៨ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០

## សៀវភៅមេរៀន

- សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ភាគ១ គន្ថីទី១-៣, ភាគ២ គន្ថីទី៤, ភាគ៣ គន្ថីទី៥, ភាគ៥ គន្ថីទី៧, ភាគ៦ គន្ថីទី ៨-៩ រៀបចំដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី ធ្វើនៅភ្នំពេញ ឆ្នាំ២០១០
- ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១, សមិទ្ធផលរបស់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ, ក្រសួងយុត្តិធម៌, បោះពុម្ពលើកទី១ ខែធ្នូ ២០១៥
- ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២,សមិទ្ធផលរបស់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធ និងតុលាការ, ក្រសួងយុត្តិធម៌ បោះពុម្ពលើកទី១ ខែធ្នូ ២០១៦
- ចាំង ស៊ីណាត, ឆ្នាំ២០១៦-២០១៨, ញាតិ និងសន្តតិកម្ម, មេរៀនសង្ខេប, បោះពុម្ពលើទី៥ ភ្នំពេញ
- សាស្ត្រាចារ្យ ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ, ឆ្នាំ ២០១១, សេចក្តីផ្តើមនីតិរដ្ឋប្បវេណី, មេរៀនសង្ខេប, បោះពុម្ពលើកទី៥ ភ្នំពេញ
- ញឹក វុទ្ធី, គ្មានកាលបរិច្ឆេទ, នីតិកាតព្វកិច្ច ភាគ១, មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី២, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- អ៊ីវ ប៉ូលី, ឆ្នាំ ២០១០, សន្តតិកម្ម, មេរៀនសង្ខេបសម្រាប់សមាជិកគណៈមេធាវី, គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- ហេង បូរ៉ា, ឆ្នាំ ២០១៥-២០១៦, នីតិកាតព្វកិច្ច និងនីតិកិច្ចសន្យា, មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣

**ឯកសារស្រាវជ្រាវ**


- ឆៃ វ៉ាន់នូ និងហ៊ា លីហួត, ឆ្នាំ ២០១៤, ការទទួលខុសត្រូវលើអំពើអ្នកដទៃ, សារណាបញ្ចប់ការសិក្សា, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ម៉ៅ សេរីវឌ្ឍណា និងហុង សុវណ្ណគិរី, ឆ្នាំ ២០១៤, សន្តតិកម្ម, សារណាបញ្ចប់ការសិក្សា, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- រ៉ែន នរិទ្ធ និងយូ ម៉ានិត, ឆ្នាំ ២០១៦, វត្តមានតំណាងអយ្យការក្នុងរឿងរដ្ឋប្បវេណី, សារណាបញ្ចប់ការសិក្សា, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ម៉ាលី រីយ៉ា និងហួង សុធារៈ, ឆ្នាំ ២០១៨, របបអាណាព្យាបាល, សារណាបញ្ចប់ការសិក្សា, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- គង់ ស៊ីម៉េង និងវ៉ាន់ សម្ផស្ស, ឆ្នាំ ២០១៨, សន្តតិកម្មសម្រាប់អនីតិជន, សារណាបញ្ចប់ការសិក្សា, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច


**ឯកសារធ្វើបទបង្ហាញ**


- ក្រុមការងារគណៈមេធាវី, "សន្តតិកម្ម" (បទបង្ហាញក្នុងសិក្ខាសាលាគណៈមេធាវីលើកទី២ ២០មីនា ២០១៣)
- មេធាវី ទេព បូផល, "បុគ្គភាព និងអំណាចមេបា" (បទបង្ហាញក្នុងសិក្ខាសាលា ១០ ឧសភា ២០១៥)
- ប៊ួយ ធីតា, អ៊ុន សក្កដា, ដុំ អ៊ីម "មូលដ្ឋានគ្រឹះនៃសន្តតិកម្ម" (ផ្នែក១) (បទបង្ហាញក្នុងសហសាលG1, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ២៩ មិថុនា ២០១៦)
- ហាប់ ផល្លី, ប៉ូលី បញ្ញា, គង់ សុភ័ក្រ្ត, "មូលដ្ឋានគ្រឹះនៃសន្តតិកម្ម" (ផ្នែក២) (បទបង្ហាញក្នុងសហសាល សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)


**វចនាក្រម**


- វចនានុក្រមសម្តេចសង្ឃជួនណាត
- សទ្ទានុក្រមផ្នែករដ្ឋប្បវេណី, រៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី, ឆ្នាំ២០០៧
- វចនានុក្រមច្បាប់តាមបទដ្ឋានគតិយុត្តខ្មែរ, សមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ, បោះពុម្ពលើកទី២, ឆ្នាំ២០១៦

# ឧបសម្ព័ន្ធទី១

ខាត ដោយអ្នកដែលបានទទួលរងនូវការរំលោភផលប្រយោជន៍ទាក់ទងនឹងលក្ខណបុគ្គល នោះ ដោយយោងទៅតាមបញ្ញត្តិស្ដីពីអំពើអនីត្យានុកូលបានឡើយ ។

## ផ្នែកទី ៣
## សមត្ថភាពខាងឆន្ទៈ

**មាត្រា ១៤.-** ការខ្វះសមត្ថភាពខាងឆន្ទៈ

សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន ។

**មាត្រា ១៥.-** និយមន័យនៃសកម្មភាព

ពាក្យ "សកម្មភាព" ដែលត្រូវបានប្រើនៅក្នុងផ្នែកទី ៣ (សមត្ថភាពខាងឆន្ទៈ) ផ្នែកទី ៤ (សមត្ថភាពក្នុងការធ្វើសកម្មភាព) និង ផ្នែកទី ៦ (ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និង ការប្រកាសអំពីការបាត់ខ្លួន) នៃជំពូកទី ១ នេះ សំដៅទៅលើកិច្ចសន្យា និង សកម្មភាពឯកតោភាគី ។

## ផ្នែកទី ៤
## សមត្ថភាពក្នុងការធ្វើសកម្មភាព

**មាត្រា ១៦.-** អត្ថន័យនៃជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

ជនដែលត្រូវបានកម្រិតសមត្ថភាព សំដៅទៅលើអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ ។

### កថាភាគទី ១
### អនីតិជន

**មាត្រា ១៧.-** អត្ថន័យនៃអនីតិជន

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

**មាត្រា ១៨.–** សិទ្ធិលុបចោលសកម្មភាព

សកម្មភាពដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលុបចោលបាន ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលទទួលសិទ្ធិ ឬ ឱ្យរួចផុតពីកាតព្វកិច្ច ឬ សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

**មាត្រា ១៩.–** ការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណា-ព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យចាត់ចែង

អនីតិជនអាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណា-ព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែង ដោយកំណត់គោលបំណង ក្នុងទំហំនៃគោលបំណងនេះបាន ។ ម្យ៉ាងទៀត អនីតិជនក៏អាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែងដោយមិនបានកំណត់គោលបំណងបានដែរ ។

**មាត្រា ២០.–** អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម

១-អនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទ ពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថ-ភាពដូចនីតិជន ចំពោះមុខជំនួញនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើបានដឹងច្បាស់ថា អនីតិជននោះមិនអាចបំពេញកិច្ចការអាជីវកម្មនោះបាន អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតនៃការប្រកបអាជីវកម្មនោះបាន ។

**មាត្រា ២១.–** ល័ក្ខខ័ណ្ឌនៃអគ្គានីនភាព

១-ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអគ្គានីនភាពរបស់អ្នកនោះបាន

តាមពាក្យសុំរបស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថា អត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជននោះ ។ ក្នុងករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា ។

២-អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាព ដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ទោះបីភាគីលែងលះគ្នាក៏ដោយ ក៏អានុភាពនៃអត្តាធីនភាព មិនត្រូវរលត់ឡើយ ។

**មាត្រា ២២.–** អានុភាពនៃអត្តាធីនភាព

អនីតិជនដែលទទួលអត្តាធីនភាព ត្រូវបានចាត់ទុកថា បានដល់នីតិភាព ។

**មាត្រា ២៣.–** កិច្ចសន្យាការងាររបស់អនីតិជន

១-ទោះបីជាមានបញ្ញត្តិនៃមាត្រា ១០៥៣ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) និង មាត្រា ១០៨០ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) នៃក្រមនេះក៏ដោយ ក៏អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនអាចធ្វើកិច្ចសន្យាការងារជំនួសអនីតិជនបានដែរ ។

២-កិច្ចសន្យាដែលផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនមានអានុភាពចំពោះសាមីអនីតិជនឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលសាមីអនីតិជនផ្តល់សច្ចានុមតិលើកិច្ចសន្យានោះ ។

៣-ក្នុងករណីដែលយល់ឃើញថា កិច្ចសន្យាការងាររបស់អនីតិជនអាចធ្វើឱ្យខូចផលប្រយោជន៍ដល់អនីតិជននោះ អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ស្ថាប័នរដ្ឋបាល អាចរំលាយកិច្ចសន្យានោះ ឆ្ពោះទៅអនាគតបាន ។

# ឧបសម្ព័ន្ធទី២

ដែលកើតឡើងដោយសារការបដិសេធចោលនោះបាន ។

**មាត្រា ៩៤៧.-** អំឡុងពេលដាក់ពាក្យបណ្ដឹង

បណ្ដឹងដែលទាក់ទងទៅនឹងមាត្រា ៩៤៥ (ការសងជំនួន) ឬ មាត្រា ៩៤៦ (ការទទួលខុសត្រូវចំពោះការបដិសេធចោលដោយមិនត្រឹមត្រូវ) ខាងលើនេះ ត្រូវប្ដឹងនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលកិច្ចសន្យាភ្ជាប់ពាក្យនោះ បានរលាយ ។

## ជំពូកទី ៣
## អាពាហ៍ពិពាហ៍

### ផ្នែកទី ១
### ការបង្កើតអាពាហ៍ពិពាហ៍

#### កថាភាគទី ១
#### លក្ខខណ្ឌនៃអាពាហ៍ពិពាហ៍

**មាត្រា ៩៤៨.-** អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍

បុរស និង នារី ដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ ។ ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាង បានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ ។

**មាត្រា ៩៤៩.-** ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព

បុគ្គលដែលមានសហព័ទ្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ ។

**មាត្រា ៩៥០.-** អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត

១-នារីពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនបើអំឡុងពេល ១២០

**មាត្រា ៩៥៣.–** ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន

១-ក្នុងករណីដែលភាគីម្ខាងក្នុងចំណោមភាគីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ ជាអនីតិជន អនីតិជននោះចាំបាច់ត្រូវមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជននោះ ។

២-បើអ្នកដែលមានអំណាចមេបាណាម្ខាងមិនយល់ព្រមទេ គ្រាន់តែមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបាម្ខាង ជាការគ្រប់គ្រាន់ហើយ ។

៣-ក្នុងករណីដែលអ្នកមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជន បដិសេធការយល់ព្រមដោយគ្មានមូលហេតុសមរម្យ អនីតិជនដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ អាចទាមទារទៅតុលាការឱ្យសម្រេចសេចក្តីជំនួសការយល់ព្រមនោះបាន ។

**មាត្រា ៩៥៤.–** ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ

ជននៅក្រោមអាណាព្យាបាលទូទៅ អាចរៀបអាពាហ៍ពិពាហ៍បាន ក្នុងករណីដែលមានសមត្ថភាពបង្ហាញឆន្ទៈ ក្នុងកម្រិតអប្បបរិមា ដែលចាំបាច់ដើម្បីរៀបអាពាហ៍ពិពាហ៍ ។ ក្នុងករណីនេះ មិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ ។

**មាត្រា ៩៥៥.–** ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីអាពាហ៍ពិពាហ៍

១-អាពាហ៍ពិពាហ៍នឹងមានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

២-ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើដោយផ្អែកតាមនីតិវិធីដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន ។

**មាត្រា ៩៥៦.–** ការទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍

ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ពុំអាចទទួលយកបានឡើយ បើបានទទួលស្គាល់ថា

# ឧបសម្ព័ន្ធទី៣

សម្រាប់កូនណាម្នាង ។

## ផ្នែកទី ៧
## ការយកមកអនុវត្តដូចគ្នានៃជំពូកនេះ

**មាត្រា ១០៦៦.–** អ្នកជំនួសអំណាចមេបា

ចំពោះកូនរបស់អនីតិជនដែលមិនទាន់បានរៀបអាពាហ៍ពិពាហ៍ អ្នកមានអំណាចមេបារបស់អនីតិជននោះ ត្រូវអនុវត្តអំណាចមេបាជំនួស ។ ក្នុងករណីនេះ បញ្ញត្តិនៃជំពូកទី ៥ (អំណាចមេបា) នេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះអ្នកដែលអនុវត្តអំណាចមេបាជំនួស ។

## ជំពូកទី ៦
## អាណាព្យាបាល

## ផ្នែកទី ១
## អាណាព្យាបាលសម្រាប់អនីតិជន

### កថាភាគទី ១
### ការចាប់ផ្ដើមអាណាព្យាបាលសម្រាប់អនីតិជន

**មាត្រា ១០៦៧.–** មូលហេតុនៃការចាប់ផ្ដើមអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើគ្មានអ្នកអនុវត្តអំណាចមេបាចំពោះអនីតិជនទេ អាណាព្យាបាលសម្រាប់អនីតិជន ត្រូវចាប់ផ្ដើម ។

### កថាភាគទី ២
### អ្នកអាណាព្យាបាលសម្រាប់អនីតិជន

**មាត្រា ១០៦៨.–** អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ អ្នក

អាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង និង មូល-
ដ្ឋាននៃការជ្រើសតាំង

១-អ្នកដែលអនុវត្តអំណាចមេបាចុងក្រោយបង្អស់ចំពោះអនីតិជន អាចកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមមតកសាសន៍បាន ។

២-ប្រសិនបើគ្មានអ្នកត្រូវធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះទេ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមការទាមទាររបស់ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជន មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជន នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលខ្វះអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

៣-ដើម្បីជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន តុលាការត្រូវគិតពិចារណាអំពីស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត និង ស្ថានភាពជីវភាព និង ទ្រព្យសម្បត្តិរបស់អនីតិជន វិជ្ជាជីវៈ និង ប្រវត្តិរូបរបស់អ្នកដែលត្រូវធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អត្ថិភាព ឬ នត្ថិភាព នៃទំនាក់ទំនងទៅនឹងផលប្រយោជន៍ រវាងអ្នកធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជន យោបល់របស់អនីតិជន និង ស្ថានភាពផ្សេងទៀតទាំងស្រុង ។

**មាត្រា ១០៦៩.–** ករណីយកិច្ចជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើខ្វះអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ១០៥២ (ការចាប់ផ្ដើមអាណាព្យាបាលសម្រាប់អនីតិជន) នៃក្រមនេះ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនថ្មីទៀត ឱ្យបានឆាប់រហ័ស ។

**មាត្រា ១០៧០.–** ចំនួននៃអ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានតែម្នាក់ ។ ប៉ុន្តែ ចំពោះអនីតិជននៅក្រោមអាណាព្យាបាលដែលស្ថិតនៅក្នុងស្ថានភាពជានិវត្តន៍ ដែលខ្វះសមត្ថភាពក្នុងការ

យល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមាន វិបត្តិផ្នែកបញ្ញាស្មារតី បើត្រូវចាប់ផ្ដើមអាណាព្យាបាលទូទៅ តាមមាត្រា ២៤ (ការប្រកាស ការចាប់ផ្ដើមអាណាព្យាបាលទូទៅ) នៃក្រមនេះ អ្នកអាណាព្យាបាលទូទៅម្នាក់អាចត្រូវ បានជ្រើសតាំងបាន ក្រៅពីអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

២-បញ្ញត្តិស្ដីពីអាណាព្យាបាលទូទៅ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអាណាព្យាបាលទូទៅសម្រាប់អនីតិជន លើកលែងតែមាត្រា ១១២០ (ករណីដែល អ្នកអាណាព្យាបាលទូទៅ មានច្រើននាក់) ។

**មាត្រា ១០៧១.–** ការលាឈប់នៃអ្នកអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើមានមូលហេតុត្រឹមត្រូវ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលា ឈប់បាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

**មាត្រា ១០៧២.–** ករណីយកិច្ចជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានលាឈប់ តុលាការត្រូវជ្រើស តាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនថ្មីទៀត ឱ្យបានឆាប់រហ័ស ។

**មាត្រា ១០៧៣.–** ការបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានធ្វើអំពើពុំត្រឹមត្រូវ ឬ មានហេតុ ផ្សេងទៀតដែលមិនសមរម្យនឹងភារកិច្ចជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន តុលាការ អាចបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះបាន តាមការទាមទាររបស់អ្នកត្រួត ពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជន នៅក្រោមអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជននៅក្រោម អាណាព្យាបាល នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាង អយ្យការ ឬ អាចបញ្ឈប់ដោយឆន្ទានុសិទ្ធិបាន ។

**មាត្រា ១០៧៤.–** បុគ្គលដែលមិនអាចក្លាយជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន

បុគ្គលដែលកំណត់ក្នុងចំណុចខាងក្រោមនេះ ពុំអាចធ្វើជាអ្នកអាណាព្យាបាល

សម្រាប់អនីតិជនបានឡើយ ៖

ក-អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ ។

ខ-អ្នកតំណាងដែលច្បាប់បានកំណត់ និង ហិតូបត្ថម្ភកៈ ព្រមទាំងអ្នកត្រួតពិនិត្យជនទាំងនោះ ដែលធ្លាប់ត្រូវបានតុលាការដកចេញ ។

គ-ជនដែលក្ស័យធន ។

ឃ-ជនដែលគ្មានដំណឹងអំពីទីរស់នៅ ។

## កថាភាគទី ៣

## អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

**មាត្រា ១០៧៥.–** អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ និង អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង

១-អ្នកមានអំណាចមេបាដែលអាចកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចកំណត់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមមតកសាសន៍បាន ។

២-ប្រសិនបើទទួលស្គាល់ថាចាំបាច់ នៅក្នុងករណីដែលគ្មានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដែលត្រូវបានកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះទេ តុលាការអាចជ្រើសតាំងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមការទាមទាររបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជននៅក្រោមអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការ ឬ ដោយឆន្ទានុសិទ្ធិបាន ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលខ្វះអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

**មាត្រា ១០៧៦.–** បុគ្គលដែលមិនអាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជននៅក្រោមអាណាព្យាបាល ពុំអាចធ្វើជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានឡើយ ។

**មាត្រា ១០៧៧.–** តួនាទីរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន មានតួនាទីដូចកំណត់ខាងក្រោមនេះ :

ក-ត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

ខ-ទាមទារឱ្យតុលាការជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនថ្មីទៀត ដោយគ្មានការយឺតយ៉ាវ ក្នុងករណីដែលខ្វះអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

គ-ធ្វើការចាត់ចែងចាំបាច់ ចំពោះការគ្រប់គ្រងថែរក្សាអនីតិជននៅក្រោមអាណាព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននោះ ក្នុងករណីដែលមានស្ថានភាពបន្ទាន់ ។

ឃ-តំណាងឱ្យអនីតិជននៅក្រោមអាណាព្យាបាល ចំពោះសកម្មភាពដែលផលប្រយោជន៍របស់អនីតិជននៅក្រោមអាណាព្យាបាល និង អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានភាពផ្ទុយគ្នា ។

**មាត្រា ១០៧៨.–** បញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នា

បញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ១០៦៨ (អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង និងមូលដ្ឋាននៃការជ្រើសតាំង) មាត្រា ១០៧១ (ការលាឈប់នៃអ្នកអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា ១០៧៣ (ការបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា ១០៧៤ (បុគ្គលដែលមិនអាចក្លាយជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន) កថាខណ្ឌទី ២ នៃមាត្រា ១០៨៧ (គម្រោងនៃចំនួនប្រាក់ចំណាយ និង សោហ៊ុយនៃអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា ១០៨៨ (កម្រៃរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា ១០៩៣

(ករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា ១១០០ (ករណីយកិច្ចសង្គ្រោះបន្ទាន់របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ជាអាទិ៍ នៅក្រោយពេលបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជន) និង មាត្រា ១១០១ (ល័ក្ខខ័ណ្ឌតតាំងនៃការបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជន ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

## កថាភាគទី ៤

## តួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

**មាត្រា ១០៧៩.—** សិទ្ធិ និង ករណីយកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងអ្នកមានអំណាចមេបា ចំពោះចំណុចដែលបានកំណត់នៅក្នុងផ្នែកទី ៣ (សិទ្ធិ និង ករណីយកិច្ចរបស់អ្នកដែលមានអំណាចមេបា) ជំពូកទី ៥ នៃគន្ថីទី ៧ នេះ ។ ប៉ុន្តែ ដើម្បីផ្លាស់ប្តូរវិធីអប់រំ និង ទីសំណាក់ដែលត្រូវបានកំណត់ដោយអ្នកមានអំណាចមេបា ដាក់ទណ្ឌកម្មលើអនីតិជននៅក្រោមអាណាព្យាបាល អនុញ្ញាតឱ្យប្រកបអាជីវកម្ម លុបចោលការអនុញ្ញាតឱ្យប្រកបអាជីវកម្ម ឬ កម្រិតអាជីវកម្ម បើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវទទួលការយល់ព្រមពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។

២-ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវពិភាក្សាជាមួយនឹងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ចំពោះចំណុចដែលបានកំណត់នៅក្នុងមាត្រា ១០៤២ (ករណីយកិច្ចពិភាក្សាអំពីចំណុចសំខាន់ៗទាក់ទងនឹងកូន) នៃក្រមនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានភាពចាំបាច់បន្ទាន់ ។

**មាត្រា ១០៨០.–** ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ហើយត្រូវធ្វើជាតំណាងឱ្យអនីតិជននៅក្រោមអាណាព្យាបាល ចំពោះសកម្មភាពដែលទាក់ទងនឹងទ្រព្យសម្បត្តិរបស់អនីតិជននោះ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃមាត្រា ១០៥៣ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១០៨១.–** ការស្រាវជ្រាវទ្រព្យសម្បត្តិ និង ការធ្វើបញ្ជីសារពើភ័ណ្ឌ

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវចាប់ផ្តើមស្រាវជ្រាវទ្រព្យសម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ដោយគ្មានការយឺតយ៉ាវ នៅក្រោយពេលបានកាន់តំណែង ហើយត្រូវបញ្ចប់ការស្រាវជ្រាវនោះ នៅក្នុងអំឡុងពេល ៣ (បី) ខែ និងត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិនោះ ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារបាននៅតុលាការ ។

២-ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ការស្រាវ-ជ្រាវទ្រព្យសម្បត្តិ និង ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិនោះ ពុំមានអានុភាពឡើយ បើគ្មានវត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះទេ ។

**មាត្រា ១០៨២.–** សិទ្ធិអំណាចនៅមុនពេលធ្វើបញ្ជីសារពើភ័ណ្ឌ

រហូតដល់ពេលបញ្ចប់ការធ្វើបញ្ជីសារពើភ័ណ្ឌ អ្នកអាណាព្យាបាលសម្រាប់អនីតិជនមានសិទ្ធិអំណាច ចំពោះតែសកម្មភាពដែលមានភាពចាំបាច់បន្ទាន់ប៉ុណ្ណោះ ។ ប៉ុន្តែសកម្មភាពនេះមិនអាចតតាំងនឹងតតិយជនដែលសុចរិតបានឡើយ ។

**មាត្រា ១០៨៣.–** ការរាយការណ៍អំពីសិទ្ធិលើបំណុល និង កាតព្វកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ដែលមានចំពោះអនីតិជននៅក្រោមអាណាព្យាបាល

១-ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន មានសិទ្ធិលើបំណុល ឬ កាតព្វកិច្ច ចំពោះអនីតិជននៅក្រោមអាណាព្យាបាល ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវរាយការណ៍ជូនអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនអំពីសិទ្ធិលើបំណុល ឬ កាតព្វកិច្ចនោះ នៅមុនពេលចាប់ផ្តើមការស្រាវជ្រាវទ្រព្យសម្បត្តិ ។

២-ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានដឹងថាមានសិទ្ធិលើបំណុលចំពោះអនីតិជននៅក្រោមអាណាព្យាបាល តែបើមិនបានរាយការណ៍ទេ អ្នកអាណាព្យាបាលនោះ ត្រូវបាត់បង់សិទ្ធិលើបំណុលនោះ ។

**មាត្រា ១០៨៤.–** ការយកមកអនុវត្តដូចគ្នា ចំពោះករណីដែលអនីតិជននៅក្រោមអាណាព្យាបាល បានធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិសកល

បញ្ញត្តិនៃមាត្រា ១០៨១ (ការស្រាវជ្រាវទ្រព្យសម្បត្តិ និង ការធ្វើបញ្ជីសារពើភ័ណ្ឌ) មាត្រា ១០៨២ (សិទ្ធិអំណាចនៅមុនពេលធ្វើបញ្ជីសារពើភ័ណ្ឌ) និង មាត្រា ១០៨៣ (ការរាយការណ៍អំពីសិទ្ធិលើបំណុល និង កាតព្វកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ដែលមានចំពោះអនីតិជននៅក្រោមអាណាព្យាបាល) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអនីតិជននៅក្រោមអាណាព្យាបាល បានធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិសកល នៅក្រោយពេលដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានកាន់តំណែង ។

**មាត្រា ១០៨៥.–** ការអនុញ្ញាតឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ

ដើម្បីលក់ ជួល រំលាយភតិសន្យា បង្កើតហ៊ីប៉ូតែក ឬ ធ្វើការចាត់ចែងផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា នូវអចលនវត្ថុដែលប្រើជាលំនៅឋានរបស់អនីតិជន

នៅក្រោមអាណាព្យាបាល ជំនួសអនីតិជននៅក្រោមអាណាព្យាបាល អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវទទួលការអនុញ្ញាតពីតុលាការ ។

**មាត្រា ១០៨៦.–** សកម្មភាពដែលផលប្រយោជន៍របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជននៅក្រោមអាណាព្យាបាល មានភាពផ្ទុយគ្នា

បញ្ញត្តិនៃមាត្រា ១០៦៥ (ករណីដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និង កូន មានភាពផ្ទុយគ្នា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

**មាត្រា ១០៨៧.–** គម្រោងនៃចំនួនប្រាក់ចំណាយ និង សោហ៊ុយនៃអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវធ្វើគម្រោងចំនួនប្រាក់ដែលត្រូវចំណាយជារៀងរាល់ឆ្នាំ ដើម្បីគ្រប់គ្រងថែរក្សាអនីតិជននៅក្រោមអាណាព្យាបាល និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននោះ នៅជំហានដំបូងនៃពេលដែលបានចាប់ផ្តើមកាន់តំណែង ។

២-សោហ៊ុយចាំបាច់ ដើម្បីអ្នកអាណាព្យាបាលសម្រាប់អនីតិជនបំពេញតួនាទីអាណាព្យាបាលសម្រាប់អនីតិជន ត្រូវចំណាយចេញពីទ្រព្យសម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ។

**មាត្រា ១០៨៨.–** កម្រៃរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

តុលាការ អាចផ្តល់កម្រៃសមរម្យ ពីក្នុងចំណោមទ្រព្យសម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ឱ្យទៅអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយគិតពិចារណាទៅលើលទ្ធភាពទ្រព្យធនរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជននៅក្រោមអាណាព្យាបាល ព្រមទាំងស្ថានភាពផ្សេងទៀតបាន ។

**មាត្រា ១០៨៩.–** ការត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ តុលាការ អាចទាមទារឱ្យអ្នកអាណាព្យាបាលនោះ រាយការណ៍អំពីតួនាទីរបស់ខ្លួន ឬ ដាក់បញ្ជីសារពើភ័ណ្ឌ ឬ អាចស្រាវជ្រាវអំពីអនីតិជននៅក្រោមអាណាព្យាបាល ឬ ស្ថានភាពទ្រព្យសម្បត្តិរបស់អនីតិជននោះ នៅពេលណាក៏បាន ។

២-តុលាការ អាចបង្គាប់ឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ធ្វើការចាត់ចែងចាំបាច់ ដែលទាក់ទងនឹងការគ្រប់គ្រងថែរក្សាអនីតិជននៅក្រោមអាណាព្យាបាល ឬ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននោះ ឬ ការចាត់ចែងចាំបាច់ផ្សេងទៀតដែលទាក់ទងទៅនឹងអាណាព្យាបាលសម្រាប់អនីតិជន តាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណា-ព្យាបាលសម្រាប់អនីតិជន ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជននោះ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជននោះ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការ ឬ ដោយឆន្ទានុសិទ្ធិបាន ។

**មាត្រា ១០៩០.–** ការកម្រិតសិទ្ធិតំណាងដែលច្បាប់បានកំណត់ និង សិទ្ធិយល់ព្រម

ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដើម្បីធ្វើអាជីវ-កម្ម ឬ ធ្វើសកម្មភាពដែលបានកំណត់នៅក្នុងមាត្រា ៣០ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមនេះ ជំនួសអនីតិជននៅក្រោមអាណាព្យាបាល ឬ ដើម្បីយល់ព្រមឱ្យអនីតិជននៅក្រោមអាណាព្យាបាល ប្រកបអាជីវកម្ម ឬ ធ្វើសកម្មភាពនោះ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវទទួលការយល់ព្រមពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះការទទួលប្រាក់ដើម ។

**មាត្រា ១០៩១.–** អានុភាពនៃការអនុវត្តផ្ទុយនឹងមាត្រា ១០៩០

១-សកម្មភាពដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានធ្វើ ឬ សកម្មភាពដែលបានផ្ដល់ការយល់ព្រម ដោយផ្ទុយនឹងបញ្ញត្តិនៃមាត្រា ១០៩០ (ការកម្រិតសិទ្ធិតំណាងដែលច្បាប់បានកំណត់ និង សិទ្ធិយល់ព្រម) ខាងលើនេះ មានតែអនីតិជននៅក្រោមអាណាព្យាបាល ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនទេ ដែលអាចលុបចោល

បាន ។ ក្នុងករណីនេះ បញ្ញត្តិនៃមាត្រា ៣២ (សិទ្ធិដាស់តឿន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងក្នុងការអនុវត្តបញ្ញត្តិនៃមាត្រា ៣៥៨ (សកម្មភាពដែលអាចលុបចោលបាន) និង បញ្ញត្តិចាប់ពីមាត្រា ៣៦០ (វិធីនៃការលុបចោល ឬ សច្ចានុមតិ) រហូតដល់មាត្រា ៣៦៣ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល) នៃក្រមនេះឡើយ ។

**មាត្រា ១០៩២.–** ការទទួលអនុប្បទានទ្រព្យសម្បត្តិ ជាអាទិ៍ ពីអនីតិជននៅក្រោមអាណាព្យាបាល

១-ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានទទួលអនុប្បទាននូវទ្រព្យសម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ឬ សិទ្ធិរបស់តតិយជនចំពោះអនីតិជននៅក្រោមអាណាព្យាបាល អនីតិជននៅក្រោមអាណាព្យាបាលនោះ អាចលុបចោលនូវអនុប្បទាននោះបាន ។ ក្នុងករណីនេះ បញ្ញត្តិនៃមាត្រា ៣២ (សិទ្ធិដាស់តឿន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងនូវការអនុវត្តបញ្ញត្តិនៃមាត្រា ៣៥៨ (សកម្មភាពដែលអាចលុបចោលបាន) និង បញ្ញត្តិចាប់ពីមាត្រា ៣៦០ (វិធីនៃការលុបចោល ឬ សច្ចានុមតិ) រហូតដល់មាត្រា ៣៦៣ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល) នៃក្រមនេះឡើយ ។

**មាត្រា ១០៩៣.–** ករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានករណីយកិច្ចបំពេញតួនាទីអាណាព្យាបាលសម្រាប់អនីតិជន ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានធ្វើឱ្យមានការខូចខាតដល់អនីតិជននៅក្រោមអាណាព្យាបាល ដោយធ្វើផ្ទុយនឹងករណីយកិច្ចប្រុងប្រយ័ត្ន ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អនីតិជននៅក្រោមអាណាព្យាបាល អាចទាមទារសំណងនៃការខូចខាតនោះ ពីអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះបាន ។

**មាត្រា ១០៩៤.–** ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល

១-ប្រសិនបើតតិយជនដែលបានផ្តល់ទ្រព្យសម្បត្តិឱ្យទៅអនីតិជននៅក្រោមអាណាព្យាបាល ដោយមិនគិតថ្លៃបានបង្ហាញឆន្ទៈថា មិនឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនគ្រប់គ្រងទ្រព្យសម្បត្តិនោះទេ ទ្រព្យសម្បត្តិនោះពុំត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនឡើយ ។

២-ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន ពុំបានអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើតតិយជនពុំបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិទេ តុលាការអាចជ្រើសតាំងអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះ តាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជននៅក្រោមអាណាព្យាបាល មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់អនីតិជននោះ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន ។

៣-ទោះបីជាតតិយជនបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិក៏ដោយ បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសិទ្ធិអំណាចរបស់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះ បានរលត់ ឬ មានការចាំបាច់ត្រូវផ្លាស់ប្តូរអ្នកនោះ តែតតិយជនមិនបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិផ្សេងទៀត ។

៤-បញ្ញត្តិចាប់ពីមាត្រា ៣៧ (ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) រហូតដល់មាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និងទី ៣ ខាងលើនេះ ។

## កថាភាគទី ៥

## ការរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន

**មាត្រា ១០៩៥.-** លក្ខខណ្ឌនៃការរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន

១-ក្នុងករណីដែលអនីតិជននៅក្រោមអាណាព្យាបាលដែលបានគ្រប់អាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯង ដោយឯករាជ្យបាន តុលាការអាចប្រកាសឱ្យរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន តាមពាក្យសុំរបស់អនីតិជននៅក្រោមអាណា-ព្យាបាលបាន បើយល់ឃើញថា ការរួចផុតនោះស្របនឹងផលប្រយោជន៍របស់អនីតិជននៅក្រោមអាណាព្យាបាលនោះ ។ ក្នុងករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកអាណា-ព្យាបាលសម្រាប់អនីតិជន ។ បើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន តុលាការក៏ត្រូវសួរយោបល់ពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលនោះផងដែរ ។

២-អនីតិជននៅក្រោមអាណាព្យាបាលដែលបានរៀបអាពាហ៍ពិពាហ៍ ត្រូវរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ដោយគ្មានការប្រកាសរបស់តុលាការ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ទោះបីជាភាគីបានលែងលះនៅពេលក្រោយក៏ដោយ ក៏អានុភាពនៃការរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន មិនត្រូវរលត់ឡើយ ។

**មាត្រា ១០៩៦.-** អានុភាពនៃការរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន

អនីតិជននៅក្រោមអាណាព្យាបាល ដែលបានរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ត្រូវបានចាត់ទុកថា បានដល់នីតិភាព ។

**មាត្រា ១០៩៧.-** ការគណនាទូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ វត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-ប្រសិនបើបានបញ្ចប់តួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនហើយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ សន្តតិជនរបស់អ្នកនោះ ត្រូវធ្វើការគណនាទូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពី

ថ្ងៃដែលបានបញ្ចប់តួនាទីនោះ ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារ បាន នៅតុលាការ ។

២-បើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ការគណនាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវអនុវត្តដោយមានវត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។

**មាត្រា ១០៩៨.–** ការលុបចោលកិច្ចសន្យារវាងអនីតិជននៅក្រោមអាណាព្យាបាល និង អ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អនីតិជននៅក្រោមអាណាព្យាបាល អាចលុបចោលកិច្ចសន្យាដែលខ្លួនបានធ្វើជាមួយនឹងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ សន្តតិជនរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ នៅក្រោយពេលដែលខ្លួនបានក្លាយជានីតិជនហើយ និង នៅមុនពេលបញ្ចប់ការគណនាទូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាលបាន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសកម្មភាពឯកតោភាគីដែលអនីតិជននោះបានធ្វើចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ សន្តតិជនរបស់អាណាព្យាបាលសម្រាប់អនីតិជននោះ ។

២-បញ្ញត្តិនៃមាត្រា ៣៥៨ (សកម្មភាពដែលអាចលុបចោលបាន) និង បញ្ញត្តិចាប់ពីមាត្រា ៣៦០ (វិធីនៃការលុបចោល ឬ សច្ចានុមតិ) រហូតដល់មាត្រា ៣៦៣ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១០៩៩.–** ករណីយកិច្ចបង់ការប្រាក់របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជននៅក្រោមអាណាព្យាបាល

១-ចំនួនទឹកប្រាក់ដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវសងទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល និង ចំនួនទឹកប្រាក់ដែលអនីតិជននៅក្រោមអាណាព្យាបាលត្រូវសងទៅឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវគិតការប្រាក់ ចាប់ពីពេលដែលបានបញ្ចប់ការគណនាទូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាលសម្រាប់អនីតិជនរួចហើយ ។

២-ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានប្រើប្រាស់ប្រាក់របស់អនីតិជននៅក្រោមអាណាព្យាបាល ដើម្បីខ្លួនឯងផ្ទាល់នោះ ត្រូវគិតការប្រាក់ ចាប់ពីពេលដែលបានប្រើប្រាស់ប្រាក់នោះ ។ បើមានការខូចខាត អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវទទួលខុសត្រូវសងសំណងនៃការខូចខាតនោះ ។

**មាត្រា ១១០០.–** ករណីយកិច្ចសង្គ្រោះបន្ទាន់របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនជាអាទិ៍ នៅក្រោយពេលបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជន

១-ប្រសិនបើមានស្ថានភាពបន្ទាន់ នៅក្នុងករណីដែលបានបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជនហើយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ សន្តតិជនរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវធ្វើការចាត់ចែងចាំបាច់ រហូតដល់ពេលដែលអនីតិជននៅក្រោមអាណាព្យាបាល សន្តតិជនរបស់អនីតិជននៅក្រោមអាណាព្យាបាលនោះ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ របស់អនីតិជននៅក្រោមអាណាព្យាបាលនោះអាចចាត់ការកិច្ចការនោះបាន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិដែលត្រូវបានកំណត់ ឬ ជ្រើសតាំង ដោយយោងតាមបញ្ញត្តិនៃមាត្រា ១០៩៤ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល) ។

**មាត្រា ១១០១.–** ល័ក្ខខ័ណ្ឌតតាំងនៃការបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជន ជាអាទិ៍

១-មូលហេតុនៃការបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជន ទោះបីជាមូលហេតុនោះកើតឡើងចំពោះអនីតិជននៅក្រោមអាណាព្យាបាលក៏ដោយ ឬ ចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជនក៏ដោយ ពុំអាចយកទៅតតាំងជាមួយនឹងភាគីម្ខាងទៀតបានឡើយ បើមិនបានជូនដំណឹងទៅឱ្យភាគីម្ខាងទៀត ឬ បើភាគីម្ខាងទៀត ពុំបានដឹងអំពីមូលហេតុ

នោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១០៩៤ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល) នៃក្រមនេះ ។

**មាត្រា ១១០២.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលទាក់ទងនឹងអាណាព្យាបាលសម្រាប់អនីតិជន

១-បញ្ញត្តិនៃមាត្រា ១០៦០ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលទាក់ទងទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ រវាងឪពុកម្តាយ និង កូន) នៃក្រមនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិលើបំណុលដែលបានកើតឡើង ដោយទាក់ទងនឹងអាណាព្យាបាលសម្រាប់អនីតិជន រវាងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជននៅក្រោមអាណាព្យាបាល ។

២-ក្នុងករណីដែលបានលុបចោលសកម្មភាព ដោយបញ្ញត្តិនៃមាត្រា ១០៩៨ (ការលុបចោលកិច្ចសន្យារវាងអនីតិជននៅក្រោមអាណាព្យាបាល និង អ្នកអាណាព្យាបាលសម្រាប់អនីតិជន) នៃក្រមនេះ អាជ្ញាយុកាលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលបានលុបចោលនោះ ។

## កថាភាគទី ៦

## ការយកមកអនុវត្តដូចគ្នា ចំពោះកូនរបស់អនីតិជននៅក្រោមអាណាព្យាបាល

**មាត្រា ១១០៣.–** ការអនុវត្តអំណាចមេបាជំនួសអនីតិជននៅក្រោមអាណាព្យាបាល

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវអនុវត្តអំណាចមេបា ចំពោះកូនរបស់អនីតិជននៅក្រោមអាណាព្យាបាល ជំនួសអនីតិជននៅក្រោមអាណាព្យាបាលនោះ ។

២-បញ្ញត្តិចាប់ពីមាត្រា ១០៧៩ (សិទ្ធិ និង ករណីយកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) រហូតដល់មាត្រា ១១០២ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលទាក់ទងនឹងអាណាព្យាបាលសម្រាប់អនីតិជន) ខាងលើនេះ ត្រូវយកមកអនុវត្តដូច

ផ្ទាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

## ផ្នែកទី ២

## អាណាព្យាបាលទូទៅ

### កថាភាគទី ១

### ការចាប់ផ្តើមអាណាព្យាបាលទូទៅ

**មាត្រា ១១០៤.–** ការចាប់ផ្តើមអាណាព្យាបាលទូទៅ

អាណាព្យាបាលទូទៅ ត្រូវចាប់ផ្តើម ដោយបញ្ញត្តិនៃមាត្រា ២៤ (ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

### កថាភាគទី ២

### អ្នកអាណាព្យាបាលទូទៅ

**មាត្រា ១១០៥.–** ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ

១-បើប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ ដោយឆន្ទានុសិទ្ធិ ។

២-ប្រសិនបើខ្វះអ្នកអាណាព្យាបាលទូទៅ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ តាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ជននៅក្រោមអាណាព្យាបាលទូទៅ សហព័ទ្ធរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់ជននៅក្រោមអាណាព្យាបាលទូទៅ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននៅក្រោមអាណាព្យាបាលទូទៅ តំណាងអយ្យការ ឬ បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ឬ ដោយឆន្ទានុសិទ្ធិ ។

៣-ទោះបីជាបានជ្រើសតាំងអ្នកអាណាព្យាបាលទូទៅហើយក៏ដោយ បើយល់ឃើញថាចាំបាច់ តុលាការអាចជ្រើសតាំងអ្នកអាណាព្យាបាលទូទៅថែមទៀត តាមការទាមទាររបស់បុគ្គលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ឬ អ្នកអាណាព្យាបាល

# ឧបសម្ព័ន្ធទី៤

## គន្ថីទី ៨
## សន្តតិកម្ម

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១
### ការចាប់ផ្តើមធ្វើសន្តតិកម្ម

**មាត្រា ១១៤៥.–** មូលហេតុនៃការចាប់ផ្តើមធ្វើសន្តតិកម្ម

១-សន្តតិកម្ម ត្រូវចាប់ផ្តើមដោយមរណភាពរបស់មតកជន ។

២-សន្តតិកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬ ដោយផ្អែកតាមឆន្ទៈរបស់មតកជន ។ សន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ហៅថា សន្តតិកម្មតាមច្បាប់ សន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា សន្តតិកម្មមានបណ្តាំ ។

**មាត្រា ១១៤៦.–** ទីកន្លែងចាប់ផ្តើមសន្តតិកម្ម

សន្តតិកម្ម ត្រូវចាប់ផ្តើមនៅលំនៅឋានរបស់មតកជន នាពេលទទួលមរណភាព ។

### ផ្នែកទី ២
### អានុភាពនៃសន្តតិកម្ម

**មាត្រា ១១៤៧.–** ការទទួលបន្តនូវមតិក

១-សន្តតិជន ត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចទាំងអស់ ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសិទ្ធិ និង ករណីយកិច្ចផ្ទាល់មុខទាំងស្រុងរបស់មតកជន ។

២-ចំពោះកម្មសិទ្ធិលើវត្ថុសម្រាប់ជំនឿសាសនា និង ចេតិយ ឬ ចលនវត្ថុដែលជារតនសម្បត្តិគ្រួសារនៃបុព្វជន បើមានជនដែលត្រូវទទួលបន្តកម្មសិទ្ធិទាំងនោះ ដូចជាជន

ដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជន ដោយយោងតាមការកំណត់របស់មតកជន ជននោះត្រូវទទួលបន្ត ។ បើមតកជនពុំបានកំណត់ទេ ជនដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជនត្រូវទទួលបន្តនូវកម្មសិទ្ធិទាំងនោះ ដោយយោងតាមទំនៀមទម្លាប់ ។ ប្រសិនបើទំនៀមទម្លាប់មិនច្បាស់លាស់ទេ តុលាការត្រូវកំណត់ជនដែលត្រូវទទួលបន្តនោះ ។

**មាត្រា ១១៤៨.–** ការទទួលបន្តសិទ្ធិលើទ្រព្យសម្បត្តិ ក្នុងករណីដែលមានសន្តតិជនច្រើននាក់

១-ប្រសិនបើមានសន្តតិជនច្រើននាក់ សហសន្តតិជនម្នាក់ៗ ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ច តាមសមាមាត្រនៃចំណែកមត៌កនោះ ។ ប៉ុន្តែ សិទ្ធិ ឬ ករណីយកិច្ចដែលមិនអាចបែងចែកបាន តាមលក្ខណៈនៃសិទ្ធិ ឬ ករណីយកិច្ចនោះ ត្រូវទទួលបន្ត ដោយអវិភាគីយ៍ ។

២-មត៌កនេះ នឹងត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន ។

## ផ្នែកទី ៣
## ភាពគ្រប់លក្ខណសម្បត្តិជាសន្តតិជន

**មាត្រា ១១៤៩.–** បុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន ជាអាទិ៍

១-មានតែជនដែលមានជីវិតរស់នៅ នាពេលចាប់ផ្តើមសន្តតិកម្ម ក្រៅពីបុគ្គលដែលបញ្ញត្តចាប់ពីមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) រហូតដល់មាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) ខាងក្រោមនេះទេ ទើបអាចទទួលសន្តតិកម្មបាន ។

២-ទោះមានបញ្ញត្តិដូចកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៩ (ទារកនៅក្នុងគភ៌) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះទារកដែលនៅក្នុងគភ៌ ។

**មាត្រា ១១៥០.–** អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍

បុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ ពុំអាចក្លាយជាសន្តតិជន ឬ ពុំអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បានឡើយ :

ក-បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាតលើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មមុន ឬ លំដាប់ស្មើគ្នា ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ។

ខ-បុគ្គលដែលដឹងអំពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬ មិនបានប្តឹង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះ មិនអាចវិនិច្ឆ័យអំពើល្អ ឬ អាក្រក់បាន ឬ ករណីដែលអ្នកសម្លាប់ជាសហព័ទ្ធ ឬ ញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ ។

គ-បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ឃ-បុគ្គលដែលបានឱ្យមតកជនធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ង-បុគ្គលដែលបានក្លែង កែបន្ថែ បំផ្លាញចោល ឬ លាក់ទុកនូវលិខិតមតកសាសន៍ស្តីពីសន្តតិកម្ម របស់មតកជន ។

**មាត្រា ១១៥១.–** ការផ្តាច់មត៌កពីសន្តតិជន

១-មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ មិនឱ្យទទួលសន្តតិកម្មបាន បើជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលមានភាគបម្រុង បានប្រព្រឹត្តនូវសកម្មភាពដែលបានកំណត់ខាងក្រោមនេះ :

ក-បើបានធ្វើបាបចំពោះមតកជន ។

ខ-បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ ។

គ-បើអាចមកមើលថែទាំមតកជននៅពេលដែលមានជម្ងឺ ប៉ុន្តែមិនមកថែទាំ ។

ឃ-បើត្រូវបានទទួលសាលក្រម ឬ សាលដីកាផ្តន្ទាទោសឱ្យជាប់ពន្ធនាគារមួយ

ជីវិត ។

ង-បើបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សំគាល់ ជាអាទិ៍ ។

មតកជន ក៏អាចបង្ហាញឆន្ទៈអំពីការផ្តាច់មត៌កនេះ តាមមតកសាសន៍បានដែរ ។

២-ជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលបានទទួលការទាមទារផ្តាច់មត៌កនេះ អាចធ្វើវិវាទអំពីអត្ថិភាព ឬ នត្ថិភាព នៃមូលហេតុនៃការផ្តាច់មត៌កនេះ នៅក្នុងការសម្រេចសេចក្តីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

**មាត្រា ១១៥២.-** ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍

បើមតកជនបានធ្វើមតកសាសន៍ដូចបានកំណត់នៅក្នុងមាត្រា ១១៥១ (ការផ្តាច់មត៌កពីសន្តតិជន) ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់ពាក្យសុំទៅតុលាការឱ្យផ្តាច់មត៌កពីសន្តតិជន ដោយគ្មានការយឺតយ៉ាវ នៅក្រោយពេលដែលមតកសាសន៍នោះបានបង្កើតអានុភាព ។ ក្នុងករណីនេះ ការផ្តាច់មត៌កពីសន្តតិជននោះ មានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលមតកជនបានទទួលមរណភាព ។

**មាត្រា ១១៥៣.-** ការកាន់កាប់មត៌ក ដោយអភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍

បើបុគ្គលដែលជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬ បុគ្គលដែលមិនអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បាន តាមបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្មជាអាទិ៍) ឬ បុគ្គលដែលត្រូវបានកាត់ផ្តាច់ពីសន្តតិកម្ម តាមបញ្ញត្តិនៃមាត្រា ១១៥១ (ការផ្តាច់មត៌កពីសន្តតិជន) និង មាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតក-សាសន៍) ខាងលើនេះ កំពុងកាន់កាប់មត៌ក បុគ្គលនោះត្រូវបានចាត់ទុកថាជាអ្នកកាន់កាប់ដោយទុច្ចរិត គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម ។

**មាត្រា ១១៥៤.-** ការលុបចោលនូវការផ្តាច់មត៌កពីសន្តតិជន

១-មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យលុបចោលនូវការផ្តាច់មត៌កពីជន ដែលត្រូវបានសន្មតថាជាសន្តតិជន នៅពេលណាក៏បាន ។

២-បញ្ញត្តិនៃមាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) ខាង

# ឧបសម្ព័ន្ធទី៥

# គម្រូទលិខិតបណ្តាំមត៌ក

(លិខិតបណ្តាំតាមទម្រង់លិខិតឯកជន)

មត្រា១១៧៤

## ១. អត្តសញ្ញាណរបស់ម្ចាស់បណ្តាំ (មតកជន)

ឈ្មោះ.................................................................................................. .............
..............................................................................................................................
.........................................................................................................................។

(ចំណុចនេះអាចបញ្ជាក់អំពីសមត្ថភាពរបស់បុគ្គលដែលអាចធ្វើមតកសាសន៍)

មាត្រា១១៦៨

## ២. ស្ថានភាពពេលកំពុងសរសេរមតកសាសន៍

ខ្ញុំសរសេរបណ្តាំមត៌កនេះ ក្នុងស្ថានភាពដែលខ្ញុំមានស្មារតី ល្អ ដឹងច្បាស់ពីអ្វីដែលខ្ញុំ កំពុងតែចាត់ចែង ហើយអ្វីដែលខ្ញុំសរសេរនៅក្នុងបណ្តាំមត៌កនេះ ជាគោលបំណងរបស់ខ្ញុំ នៅពេលដែលខ្ញុំទទួលមរណភាព ។

(ចំណុចនេះ បញ្ជាក់អំពីសមត្ថភាពរបស់ម្ចាស់បណ្តាំនាពេលធ្វើលិខិតបណ្តាំ)

មាត្រា១១៦៩

## ៣. បុគ្គលដែលត្រូវទទួលមត៌ក

អ្នកដែលត្រូវទទួលមត៌ករបស់ខ្ញុំ គឺ កូន... ........................(បញ្ជាក់អំពីអត្តសញ្ញាណរបស់ជនដែលត្រូវទទួលមត៌ក) ។

## ៤. បញ្ជាក់អំពីទំហំនៃទ្រព្យសម្បត្ត

ដីទី១ ដីទី២ ដីទី៣ ដីទី៤ (អត្តសញ្ញាណនៃដី) លុយ (លេខគណនី ឈ្មោះធនាគារ.....) គ្រឿងអលង្កា សិទ្ធិលើបំណុល (ថ្លៃឈ្នួល ភាគហ៊ុន...........) សុរបទាំងអស់ .....................បំណុល ...........................................................................។

## ៥. កំណាត់អំពីចំណែកមត៌ក ឬ វិធីបែងចែកមត៌ក

ដីទី១ដែលមានកំណត់នៅក្នុងចំណុចទី៤ ប្រគល់ឲ្យ កូន A

លុយចំនួន......កំណត់នៅក្នុងចំណុចទី៤ ប្រគល់ឲ្យកូន B

ធ្វើអច្ច័យទាន នូវគ្រឿងអលង្ការដែលមានកំណត់នៅក្នុងចំណុចទី៤ ឲ្យទៅកូន A

ភាគហ៊ុនដែលមានកំណត់នៅក្នុងចំណុចទី៤ ប្រគល់ឲ្យកូនA ២០ ភាគរយចំនួន កូនB ២០ភាគរយ កូនC ៦០ភាគរយ ។

ដីទី២ ដែលមានកំណត់នៅក្នុងចំណុចទី៤ ប្រគល់ឲ្យកូនD ប្រសិនបើ D រៀបការ

(មតកសាសន៍ដែលភ្ជាប់លក្ខខណ្ឌបង្អង់)

មាត្រា១១៩៤

## ៦. កំណត់អ្នកប្រតិបត្តិមតកសាសន៍

មេធាវី ..........................................ជាអ្នកប្រតិបត្តិមតកសាសន៍ ដោយទទួលបានកម្រៃ ........................................។

## ៧. ផ្តាច់មត៌ក

កូន E មិនទទួលបានចំណែកមត៌ករបស់ខ្ញុំទេ ពីព្រោះ កូន ប្រមាថមើលងាយខ្ញុំ ធ្វើឲ្យខ្ញុំពិបាកចិត្តគ្រប់ពេល

(មាត្រា១១៥២)

## ៨. អច្ច័យទាន

ដីទី៣ ដែលមានកំណត់នៅក្នុងចំណុចទី៤ ខ្ញុំប្រគល់ឲ្យG ជាក្មួយរបស់ខ្ញុំ ប៉ុន្តែដីនោះ ត្រូវគ្រប់គ្រងដោយ ប្អូនស្រីរបស់ខ្ញុំ ..................រហូតដល់ ក្មួយរបស់ខ្ញុំមាននីតិភាព ។

(មាត្រា១១៨៤)

## ៩. ចំនួន ការរក្សាទុក បើក និងប្រកាសបណ្តាំមត៌ក

បណ្តាំមត៌កច្បាប់ដើម ធ្វើឡើងចំនួន១ ច្បាប់

បណ្តាំមត៌កច្បាប់ដើម រក្សាទុកនៅការិយាល័យមេធាវី....................

បណ្តាំមត៌កនេះ អាចបើកបាន ២ខែ ក្រោយពេលខ្ញុំទទួលមរណភាព

បណ្តាំមត៌កនេះ ត្រូវប្រកាស នៅផ្ទះរបស់ខ្ញុំ ...................................................................

## ១០. បណ្តាំចុងក្រោយរបស់ម្ចាស់បណ្តាំ

ឪពុកសង្ឃឹមថាកូនចេះស្រលាញ់គ្នា មិនធ្វើបាបគ្នា មិនយកទ្រព្យជាត្រីមុខ បំភ្លេចញាតិភាព ធ្វើឲ្យគ្រួសារក្លាយជាអព្វមង្គល ក្រោយពេលឪពុកស្លាប់។

អ្វីៗដែលឪពុកធ្វើគឺដើម្បីកូន ហើយសង្ឃឹមថាកូនៗ នឹងរស់នៅប្រកបដោយ សុភមង្គល និងបានប្រើប្រាស់ទ្រព្យនេះជាដើមទុន សម្រាប់ជីវភាពទៅអនាគត តាមការចាត់ចែងរបស់ម្ដាយកូន។

(មាត្រា១១៨៧)

**ម្ចាស់បណ្ដាំ**

**ហត្ថលេខារបស់ម្ចាស់បណ្ដាំ និងចុះកាលបរិច្ឆេទ**

មាត្រា១១៧៤

# ឧបសម្ព័ន្ធទី៦

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចសន្យាការងារ

កិច្ចសន្យាការងារនេះ (តទៅនេះហៅកាត់ថា "**កិច្ចសន្យា**") ត្រូវបានធ្វើឡើងនៅរាជធានីភ្នំពេញ
នាថ្ងៃទី........ ខែ.......... ឆ្នាំ..........

**រវាង**

**និយោជក៖** [ឈ្មោះ] ដែលមានអាសយដ្ឋានផ្ទះលេខ..... ផ្លូវលេខ...... សង្កាត់....... ខណ្ឌ........ រាជធានីភ្នំពេញ តំណាងស្របច្បាប់ដោយលោក ........................ តទៅនេះហៅកាត់ថា "**និយោជក**"។

**និង**

**និយោជិត៖** លោក/លោកស្រី/កញ្ញា.................... កើតថ្ងៃទី..... ខែ...... ឆ្នាំ....... កាន់អត្តសញ្ញាណបណ្ណលេខ............. មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ.......... ផ្លូវ........ភូមិ......... ឃុំ/សង្កាត់ ..................ស្រុក/ខណ្ឌ............. ខេត្ត/រាជធានីភ្នំពេញ

តទៅនេះហៅកាត់ថា "**និយោជិត**"។

**និយោជក បានព្រមព្រៀងជួលនិយោជិត ហើយនិយោជិតបានព្រមព្រៀងធ្វើការងារជូននិយោជក សរបតាមខនិងលក្ខខណ្ឌដូចតទៅ៖**

### ប្រការ១៖ កាលបរិច្ឆេទចាប់ផ្តើមការងារ និងថេរវេលាសាកល្បង

និយោជិតត្រូវចាប់ផ្តើមការងាររបស់ខ្លួននាថ្ងៃទី..... ខែ...... ឆ្នាំ.........។ និយោជិត ត្រូវស្ថិតនៅក្នុងរយៈពេលសាកល្បងចំនួន៣(បី)ខែ។ នៅក្នុងរយៈពេលសាកល្បងនេះ ភាគីនិមួយៗ អាចបញ្ចប់កិច្ចសន្យានេះបានដោយជូនដំណឹងមុនទៅភាគីម្ខាងទៀតរយៈពេល៧ (ប្រាំពីរ) ថ្ងៃថ្ងៃធ្វើការ។

### ប្រការ២៖ មុខងារនិងទីកន្លែងការងារ

២.១. និយោជិត យល់ព្រមបំពេញការងារជា "____________" នៅ ..................... ដែលមានអាស័យដ្ឋានផ្ទះលេខ.......... ផ្លូវលេខ...... សង្កាត់...... ខណ្ឌ....... រាជធានីភ្នំពេញ។ លិខិតអធិប្បាយការងារ នឹងត្រូវផ្តល់ជូននិយោជិតដោយនិយោជក។

២.២. និយោជិត ត្រូវបំពេញការងាររបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ ស្របតាមក្រមសីលធម៌និងដើម្បីផលប្រយោជន៍ខ្ពស់របស់និយោជក។ និយោជិត ត្រូវបំពេញការងារខាងលើដោយខ្លួនឯង ដោយយកចិត្តទុកដាក់និងប្រុងប្រយ័ត្ន និងដោយស្មោះត្រង់ជានិច្ច។ នៅក្នុងរយៈពេលនៃកិច្ចសន្យានេះ និយោជិត មិនត្រូវចូលរួមធ្វើកម្មភាពផ្សេង ដូចជាសកម្មភាពពាណិជ្ជកម្ម ឬបំពេញការងារណាមួយ ទោះក្នុងនាមជានិយោជក កម្មករនិយោជិត សហការី ទីប្រឹក្សា មន្ត្រី នាយក ឬក្នុងគុណភាពណាផ្សេងទៀតក៏ដោយ ទោះជាដោយផ្ទាល់ឬដោយប្រយោល និងទោះបីជាមានឬគ្មានប្រាក់ឈ្នួលក៏ដោយ ប្រសិនបើមិនមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនពីនិយោជក។

និយោជិត យល់ព្រមតាមខ្លឹមសារនៃ "**កិច្ចព្រមព្រៀងស្តីពីការរក្សាការសម្ងាត់ និងការមិនប្រកួតប្រជែង**" ដែលជាផ្នែកនៃកិច្ចសន្យានេះ។

## ប្រការ៣៖ ប្រាក់ឈ្នួលនិងអត្ថប្រយោជន៍បន្ថែម

៣.១. ជាផលតបស្នងនៃការបំពេញការងារ និយោជក ត្រូវបង់ប្រាក់ឈ្នួលសុទ្ធសាធ ចំនួន ...... ដុល្លាសហរដ្ឋអាមេរិក ក្នុងមួយខែ ជូនទៅនិយោជិត។ និយោជិត ទទួលបានប្រាក់និងអត្ថប្រយោជន៍បន្ថែមស្របទៅតាម "**គោលនយោបាយស្តីពីប្រាក់និងអត្ថប្រយោជន៍បន្ថែម**" ដែលកំណត់ដោយនិយោជក។

៣.២. និយោជិត ជាអ្នកទទួលបន្ទុកបង់ពន្ធលើប្រាក់ខែជូនរដ្ឋ ហើយបានព្រមព្រៀងឲ្យនិយោជកកាត់ប្រាក់ពន្ធនេះចេញពីប្រាក់ឈ្នួលរបស់ខ្លួន។ ឬ និយោជក ជាអ្នកទទួលបន្ទុកបង់ពន្ធលើប្រាក់ឈ្នួលជំនួសនិយោជិត។

៣.៣. ប្រាក់ឈ្នួលសុទ្ធសាធខាងលើ ត្រូវពិនិត្យឡើងវិញបន្ទាប់ពីការបញ្ចប់ដោយជោគជ័យនៃរយៈពេលសាកល្បងខាងលើ។ របៀបបទនិងលក្ខខណ្ឌនៃការពិនិត្យឡើងវិញនេះ ត្រូវធ្វើឡើងស្របតាមគោលនយោបាយស្តីពីប្រាក់និងអត្ថប្រយោជន៍បន្ថែមខាងលើ។

៣.៤. ប្រាក់ឈ្នួលទាំងអស់ ត្រូវបើកជូននិយោជិតមួយដងក្នុងមួយខែរៀងរាល់ថ្ងៃទី០៥នៃខែបន្ទាប់ លើកលែងតែមានករណីចាំបាច់ណាមួយ។

## ប្រការ៤៖ ម៉ោងការងារ

និយោជិត ត្រូវបំពេញការងាររយៈពេល៤៨ម៉ោងក្នុងមួយសប្តាហ៍ ពីម៉ោង........ដល់ម៉ោង........ ពីថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍។ និយោជក មានសិទ្ធិក្នុងការរៀបចំឲ្យមានការប្តូរវេននៃការឈប់សម្រាកប្រចាំសប្តាហ៍ ក្រៅពីថ្ងៃអាទិត្យ និងម៉ោងការងារប្រចាំថ្ងៃ ដរាបណាម៉ោងសរុបប្រចាំសប្តាហ៍មិនលើសពី៤៨ម៉ោង។ ទោះបីជាយ៉ាងនេះក៏ដោយ និយោជិតឯកភាពថា នាពេលខ្លះ ការងារខាងលើរបស់ខ្លួនតម្រូវឲ្យនិយោជិតបំពេញការងារខុសពីម៉ោងពេលកំណត់ខាងលើ។ ក្នុងករណីបែបនេះ និយោជិត

យល់ព្រមបំពេញការងារបន្ថែមនោះ ហើយនឹងត្រូវទទួលបាននូវការតបស្នងស្របទៅតាមច្បាប់ការងារជាធរមាន។

**ប្រការ៥៖ ថេរវេលានៃការងារ**

៥.១. កិច្ចសន្យានេះ ត្រូវបានព្រមព្រៀងគ្នាសម្រាប់រយៈពេល ២ (ពីរ) ឆ្នាំ ហើយត្រូវបញ្ចប់តាមផ្លូវច្បាប់នាថ្ងៃទី..... ខែ..... ឆ្នាំ.........។ ភាគីនិមួយៗ ត្រូវជូនដំណឹងទៅភាគីម្ខាងទៀតអំពីចេតនារបស់ខ្លួនក្នុងការបញ្ចប់ឬបន្តកិច្ចសន្យានេះ យ៉ាងតិច៣០ (សាមសិប) ថ្ងៃ មុនថ្ងៃបញ្ចប់ខាងលើ។

៥.២. កិច្ចសន្យានេះ អាចបន្តសាជាថ្មី តាមការព្រមព្រៀងរបស់ភាគីទាំងពីរ។ ឬ

៥.១. កិច្ចសន្យានេះ ត្រូវបានចុះដោយគ្មានថេរវេលាកំណត់។

**ប្រការ៦៖ អត្ថប្រយោជន៍ផ្សេងៗ**

៦.១. និយោជិត ត្រូវទទួលបានសិទ្ធិនិងកាតព្វកិច្ចផ្សេងៗដូចជាការឈប់សម្រាកបុណ្យ ការឈប់សម្រាកប្រចាំឆ្នាំ ការឈប់សម្រាកពិសេស ការឈប់សម្រាកសម្រាលកូន ។ល។ ស្របទៅតាមច្បាប់និងវិធានស្តីពីការងារជាធរមាន។

៦.២. និយោជក យល់ព្រមរៀបចំឲ្យមានការបណ្តុះបណ្តាលបន្តដល់និយោជិតដោយនិយោជកជាអ្នកចេញសោហ៊ុយ។ ជាផលតបស្នង និយោជិត យល់ព្រមនៅបំពេញការងារជូននិយោជកយ៉ាងតិច៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទនៃការបណ្តុះបណ្តាលចុងក្រោយ។ ក្នុងករណីដែលមានការរំលោភបំពានដោយនិយោជិត និយោជិត យល់ព្រមសងប្រាក់ស្មើនឹង៥ (ប្រាំ) ដងនៃប្រាក់សរុបដែលនិយោជកបានចំណាយសម្រាប់ការបណ្តុះបណ្តាលទាំងអស់។

**ប្រការ៧៖ ការបញ្ចប់កិច្ចសន្យា**

៧.១. កិច្ចសន្យានេះ ត្រូវបញ្ចប់ នៅពេលដល់កាលបរិច្ឆេទបញ្ចប់ខាងលើ។

៧.២. កិច្ចសន្យានេះ អាចត្រូវបានបញ្ចប់ផងដែរ ដោយភាគីណាមួយ ដោយសារមូលហេតុផ្សេងទៀតដែលមានកំណត់នៅក្នុងច្បាប់ ឬបទបញ្ជាផ្ទៃក្នុងរបស់និយោជក។ ការបញ្ចប់កិច្ចសន្យានេះ ត្រូវធ្វើឡើងស្របតាមបែបបទនិងនីតិវិធីដែលកំណត់ដោយច្បាប់និងបទបញ្ជាផ្ទៃក្នុងរបស់និយោជក។

៧.៣. កិច្ចសន្យានេះ អាចត្រូវបានបញ្ចប់ដោយមិនមានការជូនដំណឹងមុននឹងដោយមិនមានការទូទាត់សំណងអ្វីទាំងអស់ ដោយមូលហេតុជាអាទិ៍ដូចខាងក្រោម៖

១/ ការរំលោភបំពានលើកាតព្វកិច្ចរក្សាការសម្ងាត់ដោយនិយោជិត

២/ ការលួចឬកេងបន្លំដោយនិយោជិត

៣/ ការបាត់បង់ទំនុកចិត្តពីនិយោជក

៤/ អសមត្ថភាពវិជ្ជាជីវៈ

៥/ មូលហេតុដែលមានកំណត់នៅក្នុងមាត្រា៨៣នៃច្បាប់ស្តីពីការងារ។

៧.៤. នាពេលបញ្ចប់កិច្ចសន្យានេះ និយោជិត ត្រូវប្រគល់ទ្រព្យសម្បត្តិ សម្ភារៈនិងឯកសារទាំងអស់របស់និយោជក ដែលនិយោជិតបានរក្សាទុក ឬដែលនិយោជកបានប្រគល់ឲ្យខ្លួនប្រើប្រាស់ក្នុងរយៈពេល៤៨ម៉ោង។

**ប្រការ៨៖ កម្មសិទ្ធិបញ្ញា**

និយោជិត យល់ព្រមថា រាល់គំនិត ស្នាដៃ ឬសមិទ្ធិផលការងារផ្សេងទៀតដែលមានលក្ខណៈជាស្នាដៃ ឬសិទ្ធិដែលត្រូវបានការពារដោយច្បាប់ទាំងឡាយពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា ត្រូវបានផ្ទេរនិងប្រគល់ជូននិយោជក ហើយតាមរយៈនេះ ក្លាយជាកម្មសិទ្ធិបញ្ញារបស់និយោជក។

**ប្រការ៩៖ ការកែប្រែកិច្ចសន្យា**

ខនិងលក្ខណ្ឌនៃកិច្ចសន្យានេះ អាចត្រូវបានកែប្រែតាមការឯកភាពរបស់ភាគីទាំងពីរ។

**ប្រការ១០៖ លក្ខខណ្ឌផ្សេងៗ**

និយោជិត ព្រមព្រៀងដូចតទៅ៖

១/ ធ្វើដំណើរទៅបំពេញការងារនៅទីកន្លែងផ្សេងក្រៅពីរាជធានីភ្នំពេញ ដើម្បីបំពេញការងារចាំបាច់ដែលពាក់ព័ន្ធនឹងការងាររបស់ខ្លួន។

២/ មិនធ្វើការផ្សព្វផ្សាយនូវការសម្ងាត់របស់និយោជក ទាំងនាពេលកំពុងបំពេញការងារ និងក្រោយពេលចប់កិច្ចសន្យានេះ ដូចមានកំណត់នៅក្នុង កិច្ចព្រមព្រៀងស្តីពីការរក្សាការសម្ងាត់ និងការមិនប្រកួតប្រជែង។

៣/ គោរពតាមបទបញ្ជាផ្ទៃក្នុងនិងការណែនាំរបស់និយោជក។

**ប្រការ១១៖ ភាសា**

កិច្ចសន្យានេះ ត្រូវបានតាក់តែង និងអនុវត្តជាភាសាខ្មែរ។

**ប្រការ១២៖ ច្បាប់អនុវត្តនិងការដោះស្រាយវិវាទ**

កិច្ចសន្យានេះ ត្រូវគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសច្បាប់និងបទបញ្ញត្តិទាំងអស់ស្តីពីការងារ និងបទបញ្ជាផ្ទៃក្នុងរបស់និយោជក។ រាល់វិវាទកើតឡើងទាក់ទងនឹងការអនុវត្តកិច្ចសន្យានេះ ត្រូវដោះស្រាយស្របតាមនីតិវិធីច្បាប់ ជាពិសេសនីតិវិធីដែលមានកំណត់នៅក្នុងច្បាប់ស្តីពីការងារ។

**ប្រការ១៣៖ កិច្ចព្រមព្រៀងទាំងមូល**

កិច្ចសន្យានេះ កំណត់អំពីលក្ខខណ្ឌនៃការព្រមព្រៀងគ្នារវាងភាគីទាំងពីរទាក់ទងនឹងកម្មវត្ថុខាងលើ។ ភាគីនីមួយៗ មិនទទួលខុសត្រូវ ឬជាប់កាតព្វកិច្ចដោយការធានា ការតំណាង ឬការសន្យាណាមួយ ដែលមិនមានចែងនៅក្នុងកិច្ចសន្យានេះ។ រាល់ការសន្យា ការព្រមព្រៀង ការយល់ឃើញ ការសន្មត ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ដោយជាក់លាក់ ឬដោយតុណ្ហីភាព ដែលមានមុនកាលបរិច្ឆេទនៃកិច្ចសន្យានេះ ត្រូវនិរាករណ៍ដោយបញ្ញត្តិនៃកិច្ចសន្យានេះ។

ក្នុងករណីដែលខ ឬផ្នែកណាមួយនៃកិច្ចសន្យានេះ មានលក្ខណៈផ្ទុយនឹងច្បាប់ បញ្ហានេះ នឹងមិនប៉ះពាល់ដល់សុពលភាពនៃខដទៃ ឬផ្នែកដទៃទៀតនោះទេ ហើយ ខ ឬផ្នែកដទៃទៀតនោះ នៅតែមានសុពលភាព និងចងកាតព្វកិច្ចគូភាគីដដែល។

**ប្រការ ១៤៖ សុពលភាពនៃកិច្ចសន្យា**

កិច្ចសន្យានេះ ធ្វើឡើងដោយការព្រមព្រៀងជាក់លាក់ ពិតប្រាកដ និងសេរីរបស់ភាគីទាំងពីរ។ ភាគីទាំងពីរបានអាននិងបានយល់ពីខ្លឹមសារនៃកិច្ចសន្យា ហើយយល់ព្រមផ្តិតស្នាមមេដៃរបស់ខ្លួនលើកិច្ចសន្យានេះទុកជាភស្តុតាងចំពោះមុខច្បាប់ ជាភាសាខ្មែរចំនួន២ (ពីរ) ច្បាប់។ ភាគីនិមួយៗ រក្សាទុកម្នាក់មួយច្បាប់។

ភាគីដែលរំលោភបំពានលើខនិងលក្ខខណ្ឌណាមួយនៃកិច្ចសន្យានេះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងត្រូវទទួលបន្ទុកចេញសោហ៊ុយចំណាយទាំងអស់រួមទាំងសេវាកម្មច្បាប់និងមេធាវីផងជូនទៅ
ភាគីដែលរងគ្រោះ។

**និយោជិត** **អគ្គនាយក................**

ហត្ថលេខា __________ ហត្ថលេខា __________

ឈ្មោះ ឈ្មោះ

កាលបរិច្ឆេទ កាលបរិច្ឆេទ

យើង.......................... ជាមេធាវី
សូមបញ្ជាក់ថាភាគីទាំងអស់ពិតជាបានអានខ្លឹមសារនៃកិច្ចសន្យា
ខាងលើនិងបានយល់ព្រមចុះហត្ថលេខា/ផ្តិតស្នាមមេដៃនៅចំពោះ
មុខយើង នាថ្ងៃទី...... ខែ...... ឆ្នាំ........ ពិតប្រាកដមែន។
ហត្ថលេខានិងត្រា